ទស្សនាវដ្តី

# ប្រជាជន

THE PRACHEACHUN MAGAZINE




ឆ្នាំទី១៧ លេខ ១៩៧ ខែតុលា ឆ្នាំ ២០១៧





**សម្តេចតេជោ ហ៊ុន សែន ៖**
ពេលអ្នកទម្លាក់គ្រាប់បែកនៅកម្ពុជា
តើមានគិតពីសិទ្ធិមនុស្សទេ ?
* ការអនុវត្តផ្លូវច្បាប់ប្រសើរជាងការប្រើប្រាស់....
* ទាល់តែមានការស្លាប់មនុស្សទើបហៅថា .......
* ឧទ្ទាមក្នុងទីក្រុងដោយធ្វើបដិវត្តន៍ពណ៌មិន ....

៧



សម័យប្រជុំរដ្ឋសភាពិភាក្សា និងអនុម័តសេចក្តីស្នើ
វិសោធនកម្មច្បាប់ចំនួន៤
ដើម្បី........

១១



**សម្តេចវិបុលសេនាភក្តី សាយ ឈុំ** ផ្តល់
ដំបូន្មានឲ្យយុវជនត្រូវចេះប្រើឱកាសមាស
ឱកាសពេជ្រ ដែលកម្ពុជា.......

១២



**សម្តេចក្រឡាហោម ស ខេង** សុំឲ្យលុបបំបាត់
ចោលទស្សនៈ មើលស្រាលតួនាទី
របស់ស្ត្រី

១៣

# ក្របមុខ

## សម្តេចចក្រី ហេង សំរិន ប្រធានរដ្ឋសភា
អញ្ជើញជាអធិបតីភាពដ៏ខ្ពង់ខ្ពស់ ដឹកនាំ
សម័យប្រជុំរដ្ឋសភាលើកទី៩ នីតិកាលទី ៥
(ថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៧)

# មាតិកា
# Contents


វិចារណកថា : សេចក្តីស្នើវិសោធនកម្មច្បាប់ចំនួន៤ មានគោលដៅធានាសុខសន្តិភាព និងការពារ......... ២
Editorial : The Draft Amendments on Four Laws Aimed to Guarantee Peace,........................ ២
អត្ថបទនយោបាយ : គាស់រំលើងឲ្យបរាជ័យដល់ឫសគល់ឧបាយកលនៃការធ្វើបដិវត្តន៍ពណ៌.............. ៥

- សកម្មភាពសមាជិក រដ្ឋសភា ព្រឹទ្ធសភា រាជរដ្ឋាភិបាល និងមន្ត្រីគណបក្ស ................................ ១៤
- សកម្មភាពរបស់ក្រុមការងារយុវជនគណបក្ស ............................................................ ១៧
- សមិទ្ធផលសំខាន់ៗមួយចំនួននៃវិស័យសេដ្ឋកិច្ច.......................................................... ១៩
- វិស័យប្រេងកាតនឹងរួមចំណែកពន្លឿនកំណើនសេដ្ឋកិច្ចកម្ពុជា............................................. ២០
- បង្កើនកិច្ចគាំពារបរិស្ថាន គ្រប់គ្រងធនធានធម្មជាតិ និងការអភិវឌ្ឍ............................................ ២២
- ការរីកចម្រើនថ្មីនៅក្នុងវិស័យការងារបានផ្តល់អត្ថប្រយោជន៍កាន់តែច្រើនដល់កម្មករ...................... ២៤
- ចំណេះដឹងទូទៅ : ប្រទេស៤ នឹងក្លាយទៅជាសឹង្ហបុរីទី២ នៅពេលខាងមុខ................................ ២៦
- វប្បធម៌ : ប្រវត្តិសិល្បៈ អាយ៉ៃ................................................................................ ២៨
- ទឹកដីមាតុភូមិ : ស្រុកឈូក ដែលផ្តល់នូវភាពកក់ក្តៅ និងក្តីសង្ឃឹម............................................ ២៩
- កំណាព្យ : មិត្តល្អ បួនពួក.................................សំណើច................................................ ៣១



**និពន្ធនាយក :**
**លោក តាក ស៊ុនអ៊ី**
**គណៈកម្មការនិពន្ធ**
១. លោក ខៀវ ណារី
២. លោក អ៊ឹម សុន្ទរៈ
៣. លោក វង្ស សារ៉ុធ
៤. លោក ទាវ សារៈមុនី
៥. លោក សុខ សុធន
**លេខានិពន្ធ**
១. លោក ជុំ សម្បត្តិ
២. លោក ម៉ក់ ឈិន
**អ្នកបកប្រែភាសា**
១. លោកស្រី ម៉ែន នារីសោភ័គ
**អ្នកថតរូប**
១. លោក សុផាត វីរៈមុនី
**វិចិត្រករ**
១. លោក ធា សារ៉ុធ



អាស័យដ្ឋាន :
លេខ ២០៣
មហាវិថី ព្រះនរោត្តម
ភ្នំពេញ-កម្ពុជា
ទូរស័ព្ទលេខ :
០២៣ ២១៩ ០៦៥

**Address :**
**No 203 Preah**
**Norodom Bld.**
**Phnom Penh Cambodia**
**Tel : 023 219 065**

# សូមក្រាបបង្គំទូលថ្វាយ
# ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
# ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា



## ព្រះករុណាជាអម្ចាស់ជីវិតតម្កល់លើត្បូង ជាទីសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត
## ក្នុងឱកាសដ៏មហានក្ខត្តឫក្សឧត្តុង្គឧត្តមថ្លៃថ្លាបំផុតនៃព្រះរាជពិធីច្រត់ព្រះនង្គ័លលើកទី ១៣
## នៃការគ្រងរាជសម្បត្តិរបស់ព្រះករុណា ជាអម្ចាស់

ទូលព្រះបង្គំយើងខ្ញុំសូមព្រះបរមរាជានុញ្ញាតថ្វាយព្រះរាជស័ព្ទសាធុការពរ សិរីសួស្តី ជ័យមង្គល បវរមហាប្រសើរ ថ្វាយព្រះករុណាជាអម្ចាស់ សូមព្រះអង្គមានព្រះរាជសុខភាពល្អបរិបូណ៌ ព្រះកាយពលមាំមួន ព្រះបញ្ញាញាណភ្លឺថ្លា ព្រះជន្មាយុយឺនយូរ និងសម្រេចបានព្រះមហាជោគជ័យសិរីមង្គលគ្រប់ប្រការ ប្រកបដោយព្រះតេជបារមីភ្លឺចិញ្ចាចចិញ្ចែង ដើម្បីគង់នៅជាម្លប់ដ៏ត្រជាក់ត្រជុំរបស់ប្រជារាស្ត្រកម្ពុជាគ្រប់ៗរូប ។

រយៈពេល ១៣ ឆ្នាំ នៃការឡើងគ្រងរាជសម្បត្តិរបស់ព្រះករុណាជាអម្ចាស់ជីវិតតម្កល់លើត្បូង បាននាំមកនូវភាពកក់ក្តៅ និងភាពសុខក្សេមក្សាន្ត ចម្រុងចម្រើន និងការអភិវឌ្ឍឥតឈប់ឈររបស់ប្រទេសជាតិ និងប្រជារាស្ត្រកម្ពុជាទាំងមូល ។

សូមបួងសួងដល់គុណបុណ្យព្រះរតនត្រ័យ វត្ថុស័ក្តិសិទ្ធិក្នុងលោក ទេវតាថែរក្សាព្រះមហាស្វេតច្ឆ័ត្រ និងព្រះបារមីនៃអតីតព្រះមហាក្សត្រ ព្រះមហាក្សត្រិយានីខ្មែរគ្រប់ព្រះអង្គ សូមប្រោះព្រំ ទ្រទ្រង់ថែរក្សាព្រះករុណាជាអម្ចាស់ ជីវិតតម្កល់លើត្បូង សូមមានព្រះរាជសុខភាពបរិបូណ៌ ព្រះបញ្ញាញាណភ្លឺថ្លាគង់នៅជាម្លប់ដ៏ត្រជាក់នៃប្រជារាស្ត្រខ្មែរតរៀងទៅ ។

សូមព្រះករុណាថ្លៃវិសេស ទ្រង់ព្រះរាជមេត្តាប្រោស ទទួលនូវគារវភក្តីភាពដ៏ខ្ពង់ខ្ពស់បំផុតពីទូលព្រះបង្គំយើងខ្ញុំ

**ទស្សនាវដ្តីប្រជាជន**

វិចារណកថា EDITORIAL

# សេចក្ដីស្នើវិសោធនកម្មច្បាប់ចំនួន៤ មានគោលដៅធានាសុខសន្តិភាព និងការពារសមិទ្ធផលសង្គមជាតិ

# The Draft Amendments on Four Laws Aimed to Guarantee Peace, Defend National Achievements

*បច្ចុប្បន្ននេះ ព្រះរាជាណាចក្រកម្ពុជា កំពុងស្ថិតនៅក្នុងដំណាក់កាលនៃការរីកចម្រើនយ៉ាងខ្លាំង អាស្រ័យដោយការដឹកនាំដ៏ត្រឹមត្រូវ ម៉ឺងម៉ាត់ មានគោលដៅច្បាស់លាស់ និងមានចក្ខុវិស័យវែងឆ្ងាយរបស់គណបក្សប្រជាជនកម្ពុជា និងរាជរដ្ឋាភិបាលកម្ពុជាដែលមាន**សម្ដេចអគ្គមហាសេនា-បតីតេជោ ហ៊ុន សែន** ជាប្រមុខ ។ យើងរក្សាការពារបានយ៉ាងគត់មត់នូវសុខសន្តិភាព ស្ថិរភាពនយោបាយ ការពារបាននូវសមិទ្ធផលដ៏ធំធេងត្រចះត្រចង់ ដែលយើងបង្កើតបានក្នុងរយៈពេលជិត ៣៩ឆ្នាំកន្លងទៅនេះ ធ្វើឲ្យប្រជាជនរស់នៅប្រកបដោយសុភមង្គល និងភាពសុខក្សេមក្សាន្ត ។ លទ្ធិប្រជាធិបតេយ្យ សេរីពហុបក្ស កាន់តែមានជំហានរីកលូតលាស់ និងចាក់ឫសជ្រៅនៅក្នុងសង្គមជាតិ រួមជាមួយនឹងការលើកកម្ពស់ ការពង្រឹងនីតិរដ្ឋ បានផ្ដល់នូវផលប្រយោជន៍ជាសារវន្តដល់សង្គមជាតិរបស់យើង ។*

*ប៉ុន្តែឆ្លងកាត់នូវដំណាក់កាលនៃការវិវត្តន៍ និងការរីកចម្រើនយ៉ាងឆាប់រហ័សនេះបានធ្វើឲ្យលេចឡើងនូវ ចំណុចមួយចំនួននៃច្បាប់ខ្លះដែលមិនសមស្របជាមួយនឹងសំណូមពរជាក់ស្ដែងនៃសភាពការណ៍នាពេលបច្ចុប្បន្ននេះឡើយ ។ កន្លងមកមានជនអគតិ និងគណបក្សនយោបាយខ្លះបានឆ្លៀតយកភាពខ្វះចន្លោះមួយចំនួន នៃច្បាប់ហ៊ានប្រព្រឹត្តអំពើក្បត់ជាតិ ធ្វើជាខ្ញុំកញ្ជះបរទេស បង្កជាបញ្ហាធ្វើឲ្យមានចលាចលសង្គម បំផ្លាញរាល់សមិទ្ធផលដែលជាស្នាដៃដ៏ពិសិដ្ឋរបស់ប្រជាជន ជាពិសេសបំផ្លាញសុខសន្តិភាព និងការអភិវឌ្ឍ ។ ហេតុនេះហើយទើបស្ថាប័ននីតិប្បញ្ញត្តិបានធ្វើវិសោធនកម្មជាច្រើនលើកច្រើនសារទៅលើជំពូក និងមាត្រាខ្លះនៃរដ្ឋធម្មនុញ្ញ និងច្បាប់មួយចំនួនដើម្បីធានាការពង្រឹងបានស្ថិរភាពនយោបាយ ការពង្រឹងលទ្ធិប្រជាធិបតេយ្យ សេរី ពហុបក្ស និងនីតិរដ្ឋ ធ្វើឲ្យគណបក្សនយោបាយទាំងអស់កាន់តែមានការទទួលខុសត្រូវខ្ពស់ចំពោះផលប្រយោជន៍របស់ជាតិ និងប្រជាជនយើងនៅក្នុងដំណាក់ថ្មី ។ ជាក់ស្ដែងកាលពីថ្ងៃទី៦ ខែតុលា ឆ្នាំ២០១៧ សមាជិករដ្ឋសភាមកពីគណបក្សប្រជាជនកម្ពុជាចំនួន៤៩រូប បានចុះហត្ថលេខាលើសេចក្ដីស្នើវិសោធនកម្មច្បាប់ចំនួន៤ ជូនទៅរដ្ឋសភា ដែលក្នុងនោះ រួមមានសេចក្ដីស្នើវិសោធនកម្មច្បាប់ស្ដីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ច្បាប់ស្ដីពីការបោះឆ្នោតជ្រើសតាំងព្រឹទ្ធសភា ច្បាប់ស្ដីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ និងច្បាប់ស្ដីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា ឃុំ សង្កាត់ ហើយត្រូវបានសម័យប្រជុំរដ្ឋសភាលើកទី៩ នីតិកាលទី៥ ធ្វើការពិភាក្សា និងអនុម័តយល់ព្រមនៅថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៧ ។ នៅថ្ងៃទី២០ ខែតុលា ឆ្នាំ០១៧ កិច្ចប្រជុំព្រឹទ្ធសភា នីតិកាលទី៣ បានពិនិត្យឲ្យយោបល់ និងឯកភាពទាំងស្រុងទៅលើសេចក្ដីស្នើច្បាប់ ស្ដីពីវិសោធនកម្មច្បាប់ទាំង ៤នេះ ហើយនៅថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៧ ក្រុមប្រឹក្សាធម្មនុញ្ញបានសម្រេចទទួលស្គាល់ច្បាប់នេះ គឺស្របនឹងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ។**ព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថនរោត្តម សីហមុនី ព្រះមហាក្សត្រ** នៃព្រះរាជាណាចក្រកម្ពុជា ព្រះអង្គបានឡាយព្រះហស្តលេខាលើព្រះរាជក្រម ប្រកាសឲ្យប្រើប្រាស់ច្បាប់ស្ដីពីវិសោធនកម្មច្បាប់ទាំង៤នេះ នៅថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៧ ។*

*គោលបំណងសំខាន់បំផុតក្នុងការធ្វើវិសោធនកម្មច្បាប់ទាំង ៤នេះ គឺ*

The Kingdom of Cambodia is in its stage of rapid progress thanks to the correct and unfaltering leadership of clear aims and long-term vision of the Cambodian People's Party, and the Cambodian Royal Government, headed by Samdech Akka Moha Sena Padei Techo Hun Sen. We have kept and defended peace and political stability firmly. We safeguarded brilliantly tremendous achievements scored in the past 39 years. Our people are living in happiness and peace. Democracy and liberal pluralism have advanced and deep-rooted in our society, together with enhancement of rule of law. This has provided our nation and people with essential interests.

However, going through stages of rapid evolution and progresses, we have discovered certain points in some laws that are not responsive to demands of current situations. So far, some ill-will persons and political parties have taken advantages of such loopholes to commit treasons and serve foreign countries, and cause problems that created social turmoil, destroyed sacred achievements of our people, and ruined peace, and development. It is in that sense that the legislative bodies have amended times and again chapters and articles of the Constitution and some laws to strengthen political stability, democracy, freedom, liberal pluralism, and rule of law. This obliges political parties to be more responsible before national and people interests in a new stage.

Take for instance, on 6 October 2017, 49 members of the National Assembly from the Cambodian People's Party signed a draft amendments on four laws and sent them to the National Assembly. They included proposed amendments to law on elections of the National Assembly members, (2) the law on the Senate elections, (3) the law on elections of the municipal, provincial, city, district/Khan councilors, and (4) the law on elections of the commune councilors. The ninth session of the fifth legislature of the National Assembly discussed and adopted those amendments on 16 October 2017. On 20 October 2017, the Senate, in its third legislature session, reviewed and unanimously agreed to the draft amendments of the four laws. On 24 October 2017, the Constitutional Council gave its approval that the amended laws are constitutional. On 25 2017, Preah Baat Samdech Preah Boromneath Norodom Sihamoni, King of the Kingdom of Cambodia, signed the royal decree for the amended laws to enter into force.

The most important objective of the amendments of the four laws is to ensure consistency between those laws with the law on political organizations as well as existing norms and for the sake of long lasting political stability in the Kingdom of Cambodia. It is also for further strengthening and expediting process of democracy, liberal pluralism, and firmer rule of law. Those amendments bear no aims of either destroying individual, group, and/or political party or pulling back process of democracy, liberal pluralism as are twisted by certain ill-will circles. Coherently, the amendments are also prohibiting politicians and political parties from allowing themselves to be foreign tools to

ដើម្បីធ្វើឲ្យមានសង្គតិភាពជាមួយច្បាប់ ស្តីពីគណបក្សនយោបាយ ព្រមទាំងបទដ្ឋានទាំងឡាយដែលនៅជាធរមាន និងដើម្បីធានាស្ថិរភាពនយោបាយឲ្យស្ថិតស្ថេរ យូរអង្វែង នៅព្រះរាជាណាចក្រកម្ពុជា និងដើម្បីបន្តខិតខំពង្រឹង និងពន្លឿនដំណើរការនៃលទ្ធិប្រជាធិបតេយ្យ សេរី ពហុបក្ស ទន្ទឹមនឹងការពង្រឹងនីតិរដ្ឋឲ្យកាន់តែរឹងមាំ ។ ការស្នើធ្វើវិសោធនកម្មច្បាប់នេះគ្មានគោលដៅបំផ្លិចបំផ្លាញបុគ្គលណាម្នាក់ ក្រុម ឬក៏គណបក្សនយោបាយណាមួយ ឬក៏ធ្វើឲ្យថយក្រោយនូវដំណើរការនៃលទ្ធិប្រជាធិបតេយ្យ សេរីពហុបក្ស នៅកម្ពុជាដូចការមួលបង្កាច់របស់មជ្ឈដ្ឋានអគតិមួយចំនួននោះឡើយ ។ ជាមួយគ្នានេះ ក៏ដើម្បីការពារមិនឲ្យអ្នកនយោបាយ និងគណបក្សនយោបាយណាមួយត្រូវបានប្រើប្រាស់ជាឧបករណ៍បម្រើឲ្យពួកបរទេសធ្វើសកម្ម ភាពក្បត់ជាតិ ក្បត់ប្រជាជន ផ្តួលរំលំរដ្ឋាភិបាលស្របច្បាប់ និងធ្វើឲ្យប្រទេសជាតិធ្លាក់ទៅក្នុងភ្នក់ភ្លើងសង្គ្រាមជាថ្មីទៀត ។ ជាក់ស្តែងនៅក្នុងសេចក្តីស្នើច្បាប់ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្របានសម្រេចកែប្រែមាត្រា១៣៨-ស្ទួន បានកំណត់យ៉ាងច្បាស់ថា៖ «ក្នុងនីតិកាលនៃរដ្ឋសភាប្រសិនបើមានគណបក្សនយោបាយណាមួយប្រកាសបោះបង់ចោលអាសនៈ ឬត្រូវលុបឈ្មោះចេញពីបញ្ជីគណបក្សនយោបាយ ឬត្រូវរំលាយស្របតាមច្បាប់ស្តីពីគណបក្សនយោបាយបញ្ជីបេក្ខជន និងតំណាងរាស្ត្រទាំងអស់ នៃគណបក្សនយោបាយនោះ លែងមានសុពលភាព និងលែងមានគុណសម្បត្តិតទៅទៀតហើយ ។ ក្នុងករណីខាងលើនេះ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវធ្វើការបែងចែកអាសនៈដែលនៅទំនេរនោះ ក្នុងរយៈពេលយ៉ាងយូរ៧ថ្ងៃ ទៅឱ្យគណបក្សនយោបាយនានាដែលបានចូលរួមក្នុងការបោះឆ្នោតក្នុងរាជធានី-ខេត្តជាមួយ ដោយមិនគិតបញ្ចូលគណបក្សនយោបាយដែលបោះបង់ចោលអាសនៈ ឬដែលត្រូវលុបឈ្មោះចេញពីបញ្ជីគណបក្សនយោបាយ ឬដែលត្រូវរំលាយស្របតាមច្បាប់ ស្តីពីគណបក្សនយោបាយ និងគណបក្សនយោបាយមានអាសនៈក្នុងរដ្ឋសភា ដែលដឹកនាំរាជរដ្ឋាភិបាល...» ។ នៅក្នុងវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា ឃុំ សង្កាត់ មាត្រា២០ថ្មី បានកំណត់ថា៖ «ក្នុងករណីគណបក្សនយោបាយណាមួយបោះបង់ចោលអាសនៈ ដែលខ្លួនទទួលបាន ឬត្រូវបានលុបឈ្មោះចេញពីបញ្ជីគណបក្សនយោបាយ ឬត្រូវបានរំលាយស្របតាមច្បាប់ស្តីពីគណបក្សនយោបាយបញ្ជីបេក្ខជន និងសមាជិកក្រុមប្រឹក្សា ឃុំ សង្កាត់ ទាំងអស់នៃគណបក្សនយោបាយនោះ លែងមានសុពលភាព និងលែងមានគុណសម្បត្តិតទៅទៀតហើយ ។ ករណីនេះគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវបែងចែកអាសនៈ ដែលនៅទំនេរនោះទៅឲ្យបញ្ជីបេក្ខជននៃគណបក្សនយោបាយផ្សេងទៀត ដែលបានចូលរួមក្នុងការបោះឆ្នោត ឃុំ សង្កាត់ ក្នុងអំឡុងពេលយ៉ាងយូរ១៤(ដប់បួន)ថ្ងៃ.....»។ នៅក្នុងវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ មាត្រា ១៣ស្ទួន បានកំណត់ថា៖ «ក្នុងអាណត្តិនៃក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ ប្រសិនបើមានគណបក្សនយោបាយណាមួយប្រកាស បោះបង់ចោល អាសនៈ ឬត្រូវបានលុបឈ្មោះចេញពីបញ្ជីគណបក្សនយោបាយ ឬត្រូវបានរំលាយស្របតាមច្បាប់ស្តីពីគណបក្សនយោបាយបញ្ជីបេក្ខជន និងសមាជិកក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ទាំងអស់នៃគណបក្សនយោបាយនោះលែងមានសុពលភាព និងលែងមានគុណសម្បត្តិតទៅទៀតហើយ ។ ករណីនេះគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវបែងចែកអាសនៈ ដែលនៅទំនេរនោះទៅឲ្យបញ្ជីបេក្ខជនគណបក្សនយោបាយផ្សេងទៀត ដែលបានចូលរួមបោះឆ្នោតក្នុងរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ក្នុងអំឡុងពេលយ៉ាងយូរ ១៤(ដប់បួន)ថ្ងៃ...»។

មជ្ឈដ្ឋានអគតិទាំងពួកប្រឆាំង ព្រមទាំងប្រទេសមួយចំនួនរួមទាំង

carry out treason against their people, and to overthrow legal government, bringing the country back into a new war.

The amended article 138 bis of the law on elections of members of the National Assembly defined clearly that - "… In a legislative term of the National Assembly, if any political party abandons its seats, or is removed from the political parties list, or is dissolved according to law on political parties, the party's listed candidates and members of the National Assembly are no longer valid and qualified. In such case, the National Elections Committee reallocates vacated seats within seven days at the longest to other parties contested in the elections in the same municipal and province. This will not include political parties that abandon their seats, or is removed from list of political parties, or is dissolved according to law on political party, and parties with seats in the National Assembly and leading the Royal Government."

Amendments of the law on elections of the communal councilors defined in its new article 20 that "… in case anyone political parties are abandoning their allocated seats, are removed from list of political parties, or dissolved according to law on political parties, listed candidates and commune councilors of the parties will no longer be valid and qualified. In such case, the National Elections Committee reallocates the vacated seats to listed candidates of political parties contested in the communal elections within 14 days at the longest …"

The amendments of law on elections of municipal, provincial/city, district/khan councils defined in Article 13 bis that "… in elected terms of councils of municipality, province, district/khan, if any political party abandons its seats, or is removed from the political parties list, or is dissolved according to law on political parties, the party's listed candidates and municipal, provincial, city, and district/khan councilors are no longer valid and qualified. In such case, the National Elections Committee reallocates the vacated seats to listed candidates of political parties contested in the municipal, provincial, city, and district/khan councilor elections within 14 days at the longest …"

After the amendments in place, ill-will circles that include also opposition party and some countries, the US also included, complained, and expressed their concerns on what they termed as "backwardness of democracy in Cambodia." Some foreigners boldly commented on Cambodia's Constitution and national sovereignty in violation of principle of democracy, liberal pluralism, and rule of law for demanding for release of culprits, the accused, and treacherous persons without condition. They have accused the amendments of the four laws unilateral and unconstitutional. They however should inspect clearly that whatever the Royal Government has been doing is in complete conformity with laws of the Kingdom of Cambodia.

The National Assembly has the task and obligation to make and adopt laws according to stipulations in the Constitution and internal regulations of the National Assembly. According to the Constitution and internal regulations of the National Assembly, whether the opposition parties participate or not, the 67 members of the National Assembly present, or more than half the number of its members, can carry out the session and adopt the draft amendments of the four laws with a favor of 67 over 67.

There are criticisms also from certain circles that should there be trial of leader or dissolution of the opposition party, including also the amendments of the four laws, that would be a violation of voters' wills. They forgot what the Americans and the opposition party did on Cambodian people in the decade 1970s and on the Cambodian People's Party, and the legal Royal Government of Cambodia, during the

អាមេរិកផងបានធ្វើជាត្អូញត្អែរ សោកស្ដាយ និងព្រួយបារម្ភអំពីរបស់ដែលហៅថា «ដំណើរថយក្រោយនៃលទ្ធិប្រជាធិបតេយ្យនៅកម្ពុជា» ក្រោយពេលដែលសេចក្ដីស្នើវិសោធនកម្មច្បាប់ទាំង ៤នេះចូលជាធរមាន ។ ពួកបរទេសខ្លះបានធ្វើអត្ថាធិប្បាយបំពានយ៉ាងគឃ្លើនទៅលើរដ្ឋធម្មនុញ្ញ និងអធិបតេយ្យជាតិរបស់កម្ពុជា រំលោភទៅលើគោលការណ៍ ប្រជាធិបតេយ្យសេរី ពហុបក្ស និងនីតិរដ្ឋនៅកម្ពុជាដោយបានទាមទារឲ្យដោះលែងអ្នកទោស ជនជាប់ចោទ រួមទាំងជនក្បត់ជាតិចេញពីពន្ធនាគារដោយគ្មានលក្ខខណ្ឌទៀតផង ។ ពួកគេបានចោទប្រកាន់ទៀតថា សេចក្ដីស្នើវិសោធនកម្មច្បាប់ទាំង៤នេះ ធ្វើឡើងដោយសភាឯកបក្សផ្ទុយពីរដ្ឋធម្មនុញ្ញ ។ ប៉ុន្ដែពួកគេត្រូវតែពិនិត្យឲ្យបានច្បាស់លាស់ថា អ្វីៗដែលរាជរដ្ឋាភិបាលបាន និងកំពុងធ្វើគឺ ស្របទៅតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជាទាំងស្រុង ។ រដ្ឋសភាជាតិមានភារកិច្ច និងកាតព្វកិច្ចធ្វើច្បាប់ និងអនុម័តច្បាប់ទៅតាមស្មារតីខ្លឹមសាររដ្ឋធម្មនុញ្ញ និងបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា ។ បើយោងតាមខ្លឹមសារនៃរដ្ឋធម្មនុញ្ញ និងបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា ទោះបីគណបក្សប្រឆាំងមិនចូលរួម ក៏តំណាងរាស្ដ្រ៦៧រូប ដែលបានអញ្ជើញចូលរួមក្នុងសម័យប្រជុំសភានោះគឺមានចំនួនលើសពីពាក់កណ្ដាលនៃចំនួនសមាជិករដ្ឋសភាទាំងមូលអាចប្រជុំបាន ហើយការអនុម័តទៅលើសេចក្ដីស្នើវិសោធនកម្មច្បាប់ទាំង៤នោះ បានទទួលការគាំទ្រ ៦៧លើ ៦៧សម្លេងទៅហើយ ។

មានការរិះគន់ពីមជ្ឈដ្ឋានអគតិខ្លះទៀត ដែលបានចោទប្រកាន់ទាំងទទឹងទិសថា បើមានការកាត់ទោសមេដឹកនាំបក្សប្រឆាំង ឬរំលាយបក្សប្រឆាំង រួមទាំងការធ្វើវិសោធនកម្មច្បាប់ទាំង ៤ នេះផង គឺជាការរំលោភទៅលើឆន្ទៈរបស់ប្រជារាស្ដ្រដែលជាអ្នកបោះឆ្នោត ។ ប៉ុន្ដែពួកគេបែរធ្វើជាភ្លេចនូវរឿងអតីតកាល ដែលអាមេរិកព្រមទាំងគណបក្សប្រឆាំងបានធ្វើមកលើប្រជាជនកម្ពុជាកាលពីក្នុងអំឡុងទសវត្សរ៍ឆ្នាំ ១៩៧០ និងមកលើគណបក្សប្រជាជនកម្ពុជា និងរាជរដ្ឋាភិបាលស្របច្បាប់កម្ពុជាក្នុងអំឡុងពេលបោះឆ្នោតឆ្នាំ២០១៣ ។ ទាក់ទិននឹងបញ្ហានេះកាលពីថ្ងៃ១៨ខែតុលា **សម្ដេចតេជោ ហ៊ុន សែន** បានលើកជាសំណួរចំនួន២ថា៖ **ទី១- «នៅពេលដែលអ្នកផ្ដួលរំលំទម្លាក់សម្ដេចនរោត្ដម សីហនុ អ្នកបានគាំទ្រការផ្ដួលរំលំ សម្ដេចនរោត្ដម សីហនុ តើពួកអ្នកមានបានគិតអំពីឆន្ទៈប្រជាពលរដ្ឋដែលបានបោះឆ្នោតសម្រាប់តំណែង ប្រមុខរដ្ឋរបស់សម្ដេចព្រះនរោត្ដម សីហនុ ទេ? ពួកអ្នកបានគិតអំពីឆន្ទៈរាស្ដ្រទេ? អ្នកអត់បានគិតអំពីឆន្ទៈរបស់រាស្ដ្រទេ។ អ្នកគិតតែអំពីបញ្ហាថា សម្ដេចនរោត្ដម សីហនុ ដឹកនាំផ្ដាច់ការក្នុងពេលដែលព្រះអង្គមិនបានធ្វើអ្វីខុសនោះទេ ។ ដើម្បីបម្រើឱ្យសង្គ្រាមនៅវៀតណាម អ្នកត្រូវកាន់កាប់កម្ពុជា ហើយដោយសារតែសម្ដេចនរោត្ដម សីហនុ មិនធ្វើតាមបំណងរបស់អ្នក អ្នកក៏ចាប់ផ្ដើមផ្ដួលរំលំសម្ដេចនរោត្ដម សីហនុ ដោយមិនបានគិតអំពីឆន្ទៈរបស់រាស្ដ្រ ដែលបានគាំទ្រ និងថ្វាយអំណាចចំពោះព្រះអង្គ ជាព្រះប្រមុខរដ្ឋអស់មួយជីវិតទៀតផង»** ។ **សម្ដេចតេជោ ហ៊ុន សែន** បានចោទជាសំណួរទី ២ថា៖ **«កន្លងទៅនៅកម្ពុជា នៅពេលដែលអ្នកស្រែកថា ហ៊ុន សែន អើយចុះចេញទៅ តើអ្នកមានបានគិតអំពីឆន្ទៈរាស្ដ្រ ដែលបានបោះឆ្នោតឱ្យគណបក្សប្រជាជនកម្ពុជាឱ្យ ហ៊ុន សែន ធ្វើជានាយករដ្ឋមន្ដ្រីទេ? នេះជាចំណុចដែលអ្នកត្រូវគិត ហើយសូមអ្នក កុំគេចវេសថា រឿងហ្នឹងជារឿងចាស់ ។ ប៉ុន្ដែរឿងចាស់ និងរឿងថ្មី ដូចតែគ្នាទេ ។ ម្យ៉ាងទៀត ខ្ញុំចង់ចង្អុលទៅមហាអំណាច ដែលហៅថា បិតាប្រជាធិបតេយ្យ និងសិទ្ធិមនុស្ស គឺសហរដ្ឋអាមេរិក នៅត្រង់ថា ពេលលោក និច សុន ធ្វើខុសក្នុងរឿងអាស្រូវវ៉តធើហ្គេត ពេលនោះ គេបានទម្លាក់និចសុនចេញពីតំណែងហេតុអ្វី បានជាគ្មាននរណាធ្វើ អត្ថាធិប្បាយអំពីឆន្ទៈរបស់រាស្ដ្រ ដែលបានបោះឆ្នោតឱ្យ និច សុន ធ្វើជាប្រធានាធិបតី?»** ។ ម្យ៉ាងវិញទៀតការអនុវត្តច្បាប់ គឺជាវិធានការចាំបាច់តែមួយគត់បញ្ចៀសបានការបង្ហូរឈាមគ្នា ដែលសោកនាដកម្មបែបនេះ កម្ពុជាធ្លាប់បានឆ្លងកាត់ច្រើនណាស់មកហើយ ។ នៅថ្ងៃទី ២៣ ខែតុលា ឆ្នាំ២០១៧ **សម្ដេចតេជោ ហ៊ុន សែន** បានបញ្ជាក់យ៉ាងច្បាស់លាស់ថា៖ «កុំមកចង់ផ្ដួលរំលំដោយផ្លូវកាត់ឲ្យសោះ អ្នកមិនអាចទៅរួចទេ ហើយអ្នកក៏មិនអាចគេចវេសពីសំណាញ់ច្បាប់បានដែរ ។ អំពើរបស់អ្នកត្រូវតែផ្ដន្ទាទោសហើយ ហើយការអនុវត្តផ្លូវច្បាប់ប្រសើរជាងការប្រើប្រាស់កម្លាំងប្រដាប់អាវុធ ។ យើងចេញដំណើរពីស្ថានភាពដ៏លំបាករហូតមកដល់ពេលនេះ ចាំបាច់ត្រូវតែរក្សាឲ្យបាន មិនត្រូវឲ្យជនក្បត់ក្រោមបញ្ជារបស់បរទេសណាមកបំផ្លិចបំផ្លាញបានទេ» ។

ការធ្វើវិសោធនកម្មច្បាប់ចំនួន៤នេះ បង្ហាញឲ្យឃើញនូវជំហានទៅមុខដ៏ត្រឹមត្រូវនៃដំណើរការប្រជាធិបតេយ្យ និងនីតិរដ្ឋនៅកម្ពុជា និងឆ្លុះបញ្ចាំងឲ្យឃើញច្បាស់ អំពីការទទួលខុសត្រូវរបស់គណបក្សប្រជាជនកម្ពុជាដែលបានប្រកាន់ខ្ជាប់គោលជំហរការពាររដ្ឋធម្មនុញ្ញ ការពារសុខសន្ដិភាព ការពាររាល់សមិទ្ធផលរបស់សង្គមជាតិ ដើម្បីការអភិវឌ្ឍប្រទេសជាតិយូរអង្វែងតទៅទៀត ដោយមិនអនុញ្ញាតិឲ្យគណបក្សនយោបាយណាមួយ ឬមជ្ឈដ្ឋានអគតិណាមួយបំផ្លិចបំផ្លាញបានឡើយ ៕

*ទស្សនាវដ្ដីប្រជាជន*

elections in 2013. In relation to this issue, on 18 October, Samdech Techo Hun Sen raised two questions.

"... Firstly, when they launched a coup against the head of state Preah Norodom Sihanouk, did anyone think about any voters or people's wills that voted him as head of state? Was it not against the will of the people? You did not care about it? You only brought up issue of dictatorship while he did nothing wrong. To serve your war interest in Vietnam, you needed to occupy Cambodia. As Samdech Preah Norodom Sihanouk refused to oblige your wish, you got him, ignoring his people's support as a lifetime head of state, out of power ..."

Samdech Techo in his second question asked – "... recently too, there was this chanting slogan of "Hun Sen! Step Down." Have those people thought of wills of the people who had voted overwhelmingly for the Cambodian People's Party and for Hun Sen to be Prime Minister? This is the point that everyone should think about. Yo cannot avoid it and said it is an old issue. I wantd to point to the powerful nation or father of democracy and human rights, the United States of America, I mean, when Mr. Nixon did something wrong about Watergate scandal, there was this motion in the US congress to bring him down. Nobody talked about people's wills that voted him as president in the first place ..."

After all, implementing laws to resolve issues is the only necessatry means to avoid bloodshep, such tragedy that Cambodia went through many times. On 23 October 2017, Samdech Techo Hun Sen reaffirmed clearly that "… they should not seek to bring us down in abrupt way. You would not be able to succeed. You may not escape from legal net. You are to receive punishment for what you had done. Implementing laws is better than using arms. We have put our difficult past behind. We must keep it. We will not allow treacherous persons to destroy under foreign order …"

The amendments of the four laws show a correct step forwards of democracy and rule of law in Cambodia. It also reflects responsibility taken by the Cambodian People's Party in adherence to position of defending the Constitution, peace, and national achievements for the sake of long-term national development. We allow no destructions from any political party or ill will circles./.

*THE PRACHEACHUN MAGAZINE*

# គាស់រំលើងឲ្យបរាជ័យដល់ឫសគល់ឧបាយកល នៃការធ្វើបដិវត្តន៍ពណ៌នៅកម្ពុជា

**បដិវត្តន៍ពណ៌** ជាពាក្យមួយដែលត្រូវបានគេប្រើប្រាស់ទូទាំងពិភពលោក ជាការកត់សម្គាល់ទៅលើការធ្វើចលនាបះបោរបង្កើតឲ្យមានភាពចលាចល ការបង្ហូរឈាម ហើយចុងក្រោយបំផុតវាបានផ្ដល់នូវផលវិបាកជាច្រើនហួសពីអ្វីដែលយើងនឹកស្មានមិនដល់ ។

តើបដិវត្តន៍ពណ៌ជាអ្វី? តាមនិយមន័យបដិវត្តន៍ពណ៌គឺជា វិធីសាស្ត្រក្នុងការផ្លាស់ប្ដូររបបមួយ ឬមេដឹកនាំនៃប្រទេសមួយតាមរយៈការប្រើប្រាស់កម្លាំងមហាជន ជាពិសេសយុវជនឲ្យប្រមូលផ្ដុំគ្នាធ្វើការតវ៉ាក្រោមរូបភាពអហិង្សា ឈានទៅដល់ការប្រើអំពើហិង្សា ក្រោមលេសទាមទារសិទ្ធិសេរីភាព និងយុត្តិធម៌សង្គម ។ ពាក្យថា ផ្លាស់ប្ដូរនៅក្នុងនិយមន័យ នៃបដិវត្តន៍ពណ៌គឺការផ្ដួលរំលំរដ្ឋាភិបាលស្របច្បាប់មួយដែលកើតចេញពីការបោះឆ្នោត ។ ជាទូទៅបដិវត្តន៍ពណ៌ត្រូវបានគេប្រើប្រាស់ពណ៌ផ្កា ឬវត្ថុអ្វីដែលជាក់លាក់ណាមួយមកធ្វើជានិមិត្តសញ្ញា ។

តើអ្វីទៅជាវិធីនៃការធ្វើបដិវត្តន៍ពណ៌? ដើម្បីបង្កើតឲ្យមានបដិវត្តន៍ពណ៌នៅក្នុងប្រទេសមួយ គេត្រូវរកឲ្យឃើញ ចំណុចរសើបបំផុត ឬក៏បង្កឱកាសបង្កើតឲ្យមានភាពអវិជ្ជមានណាមួយនៅក្នុងរបបនោះ បន្ទាប់មកត្រូវចំណាយពេលធ្វើការបំពាក់បំប៉នមួយជំហានម្ដងៗ ឲ្យប្រជាជនបាត់ជំនឿមកលើរដ្ឋអំណាច ឈានទៅបន្ទាបនិងបន្ទាបអំណាចរបស់រដ្ឋ ធ្វើឲ្យរដ្ឋអំណាចនោះចុះខ្សោយបាត់បង្អែក បាត់ការគាំទ្រ ទើបបំផុសមហាជនឲ្យក្រោកឡើងធ្វើការតវ៉ាបះបោរ បង្កចលាចល និងផ្ដួលរំលំតែម្ដង ។ ពួកគេក៏បានបង្កើតផងដែរនូវសម្ព័ន្ធភាពរវាងគណបក្សនយោបាយ ដែលមាននិន្នាការដូចគ្នាក្នុងការប្រឆាំងរាជរដ្ឋាភិបាលបង្កើតសម្ព័ន្ធសមាគម និងអង្គការមិនមែនរដ្ឋាភិបាលកសាងចលនាយុវជន និងបង្កើតបណ្ដាញផ្សព្វផ្សាយមាន និន្នាការប្រឆាំងដើម្បីធ្វើការឃោសនាវាយប្រហារមេដឹកនាំរដ្ឋាភិបាល និងគណបក្សកាន់អំណាច ។ វិធីធ្វើនៅមានច្រើនយ៉ាងទៀតដូចជាការប្រមូលផ្ដុំគ្នាធ្វើបាតុកម្មតាមដងផ្លូវ ដើម្បីបដិសេធលទ្ធផលនៃការបោះឆ្នោតទាមទារឲ្យមានការបោះឆ្នោត ឬការផ្ទៀងផ្ទាត់ ឬការរាប់សន្លឹកឆ្នោតឡើងវិញ រួចជំរុញប្រព័ន្ធផ្សព្វផ្សាយ និង សម្ព័ន្ធ NGOs ដែលពួកគេរៀបចំស្រេចហើយនោះឲ្យបន្ទរ និងបំពងសម្លេងធ្វើឲ្យឮខ្ទរខ្ទារឡើង ។ ពួកគេបញ្ឆេះកំហឹងបាតុករប្រឆាំងរដ្ឋាភិបាល ជំរុញឬរៀបចំឲ្យមានការប៉ះទង្គិចដោយការបង្ហូរឈាម និងទាក់ទាញ ឬទិញទឹកចិត្តកម្លាំងប្រដាប់អាវុធឲ្យឈប់គាំទ្ររដ្ឋាភិបាលជាដើម ។

តើបដិវត្តន៍ពណ៌កើតឡើងនៅប្រទេសណាខ្លះ? បដិវត្តន៍ពណ៌បានកើតឡើងក្នុងប្រទេសមួយចំនួន ដែលយើងបានធ្វើការកត់សម្គាល់ដូចជា នៅក្នុងអតីតសហភាពសូវៀត និងឧបទ្វីបបាល់កង់ក្នុងដើមទសវត្សរ៍ឆ្នាំ២០០០ បដិវត្តន៍ផ្កាការណេហ្សិន ក្នុងប្រទេសព័រទុយហ្គាល់ ឆ្នាំ១៩៧៤ បដិវត្តន៍ពណ៌លឿងនៅប្រទេសហ្វីលីពីនឆ្នាំ១៩៨៦ បដិវត្តន៍ក្រណាត់កម្ទី នៅឆេកូស្លូវ៉ាគី ខែវិច្ឆិកា ឆ្នាំ១៩៨៩ បដិវត្តន៍ ប៊ូលឌូហ្សែរ នៅប្រទេសយូហ្គោស្លាវី ឆ្នាំ២០០០ បដិវត្តន៍ផ្កាកូលាប នៅប្រទេសហ្សកហ្ស៊ី ខែវិច្ឆិកា ឆ្នាំ២០០៣ បដិវត្តន៍ពណ៌ទឹកក្រូចនៅអ៊ុយក្រែន ខែវិច្ឆិកា ឆ្នាំ២០០៤ បដិវត្តន៍ពណ៌ស្វាយ នៅអ៊ីរ៉ាក់ ខែមករា ឆ្នាំ២០០៥ បដិវត្តន៍ខោខូវប៊យនៅប្រទេសបេឡារូស ខែមិនា ឆ្នាំ២០០៦ បដិវត្តន៍រមៀត នៅប្រទេសភូមា ខែសីហា ឆ្នាំ២០០៧ បដិវត្តន៍ផ្កាម្លិះ នៅទុយណេស៊ី ខែធ្នូ ឆ្នាំ២០១០ បដិវត្តន៍ផ្កាឈូកនៅអេហ្ស៊ីប ខែមករា ឆ្នាំ២០១១ បដិវត្តន៍ផ្កាម្លិះ នៅប្រទេសចិន ខែ កុម្ភៈ ឆ្នាំ២០១១ បដិវត្តន៍ចម្រុះពណ៌នៅប្រទេសម៉ាសេដូនី ខែមេសា ឆ្នាំ២០១៦។ល។ និង។ល។

តើនៅប្រទេសកម្ពុជាមានបដិវត្តន៍ពណ៌ឬទេ? បើពិនិត្យទៅលើនិយមន័យ និងបទពិសោធន៍ ដែលបដិវត្តន៍ពណ៌បានកើតមានរួចហើយនៅលើប្រទេសមួយចំនួនក្នុងពិភពលោក ព្រមទាំងតួអង្គ





សកម្មភាពកុប្បកម្មហិង្សា ញុះញង់ដោយគណបក្សសង្គ្រោះជាតិ ដែលជាធាតុពិតនៃការធ្វើបដិវត្តន៍ពណ៌កាលពីឆ្នាំ២០១៣

ទាំងឡាយដែលត្រូវធ្វើបដិវត្តន៍ពណ៌ រួមជាមួយនឹងឯកសារជាច្រើន ដែលសមត្ថកិច្ចយើង ប្រមូលបានជាភស្តុតាងបានបង្ហាញឲ្យយើង ឃើញច្បាស់ណាស់ថា ក្នុងអំឡុងការបោះឆ្នោតឆ្នាំ២០១៣ គណបក្សប្រឆាំងដោយមានការគាំទ្រពីអាមេរិក អង្គការសង្គមស៊ីវិល និងប្រព័ន្ធឃោសនា ដែលមាននិន្នាការប្រឆាំងបានធ្វើបដិវត្តន៍ពណ៌នៅប្រទេសកម្ពុជាយើងហើយ ។ តាមរយៈការបះបោរនៅតាមដងផ្លូវ ពួកសកម្មជននៃគណបក្សប្រឆាំង បានកាន់ផ្កាឈូកនៅក្នុងដៃជាសញ្ញាសម្គាល់ដែលនោះ គឺជាបដិវត្តន៍ផ្កាឈូក ។ បដិវត្តន៍ពណ៌នៅកម្ពុជា ផ្ដើមឡើងដោយមានសេណារីយោមួយច្បាស់លាស់ ទាំងមុនពេលបោះឆ្នោត ក្នុងពេលបោះឆ្នោត និងក្រោយពេលបោះឆ្នោតនាថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០១៣ ។ មុនពេលបោះឆ្នោតគណបក្សប្រឆាំងបានប្រកាសជាមុនថា ពួកគេចូលរួមបោះឆ្នោតតែនឹងមិនទទួលស្គាល់លទ្ធផលនៃការបោះឆ្នោតទេ ដោយភ្ជាប់ជាមួយនូវការចោទប្រកាន់មួលបង្កាច់ថា គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតមិនអព្យាក្រឹត ។ ក្រោយមកពួកគេបានមួលបង្កាច់អំពីការបន្លំសន្លឹកឆ្នោត បំផុសឲ្យមានការបែកបាក់ក្នុងសង្គមជាតិ បំផុសសតិអារម្មណ៍ជាតិនិយមចង្អៀតចង្អល់ ។ ក្នុងថ្ងៃបោះឆ្នោតក្រុមប្រឆាំងបានបង្កើតឲ្យមានអំពើហិង្សាជាច្រើនកន្លែង ដូចជាការគំរាមអ្នកបោះឆ្នោតមិនឲ្យទៅបោះឆ្នោត គំរាមកំហែងមន្ត្រីរៀបចំការបោះឆ្នោតតាមការិយាល័យបោះឆ្នោត រហូតឈានទៅដល់ដុតរថយន្តរបស់សមត្ថកិច្ចថែមទៀត ។ ក្រោយថ្ងៃបោះឆ្នោតពួកគេបានខិតខំប្រមែប្រមូលអ្នកគាំទ្រខ្លួន មកទីលានប្រជាធិបតេយ្យ ហើយប្រើប្រាស់ទីលាននេះ ជាមជ្ឈមណ្ឌលសម្រាប់ប្រមូលកម្លាំង និងចាត់តាំងជាសកម្មភាពបាតុកម្មយ៉ាងអនាធិបតេយ្យតាមដងផ្លូវ ធ្វើឲ្យប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់សន្តិសុខ សណ្ដាប់ធ្នាប់សង្គម ។ ពួកគេប្រកាសមិនទទួលស្គាល់លទ្ធផលនៃការបោះឆ្នោត មិនចូលរួមកិច្ចប្រជុំរដ្ឋសភាលើកដំបូងតាមការកោះប្រជុំរបស់ព្រះមហាក្សត្រ ទាមទារឲ្យ**សម្ដេចតេជោ ហ៊ុន សែន** ចុះចេញពីតំណែង និងរៀបចំឲ្យមានការបោះឆ្នោតឡើងវិញ ។ មានអង្គការសង្គមស៊ីវិលខ្លះបានទាមទារឲ្យបង្កើតរដ្ឋាភិបាលបណ្ដោះអាសន្ន ដើម្បីដឹកនាំប្រទេសក្នុងដំណាក់កាលអន្តរកាល ហើយរៀបចំការបោះឆ្នោតឡើងវិញ។ ប្រព័ន្ធផ្សព្វផ្សាយដែលមាននិន្នាការប្រឆាំងតែងតែផ្សាយ ហើយផ្សាយទៀត នូវបទវិភាគ និងបទសម្ភាសន៍របស់ក្រុមមនុស្សដែលមានការចាត់តាំងត្រឹមត្រូវ ហើយដែលប្រកាសខ្លួនឯងជាអ្នកវិភាគឯករាជ្យនិយាយភូតកុហក បំភ្លៃបំផ្លើស ក្នុងគោលបំណងធ្វើឲ្យសាធារណមតិច្របូកច្របល់ ។

នៅខែឧសភា ឆ្នាំ២០១៦ ពួកគេបានសាកល្បងម្ដងទៀតធ្វើបដិវត្តន៍ពណ៌ខ្មៅ តាមរយៈការបំផុសប្រជាជនឲ្យស្លៀកពាក់ពណ៌ខ្មៅរៀងរាល់ថ្ងៃច័ន្ទ ។ នៅខែតុលា ឆ្នាំ២០១៧ បក្សប្រឆាំងបានសាកល្បងម្ដងទៀត ធ្វើសកម្មភាពក្នុងទម្រង់ជាបដិវត្តន៍ពណ៌ដែរនោះ គឺការបំផុសឲ្យលើកបដាដែលមានរូបជនក្បត់ជាតិ កឹម សុខា នៅតាមទីស្នាក់ការគណបក្សប្រឆាំងគ្រប់ខេត្ត រាជធានី និងតាមមូលដ្ឋាននានា ប៉ុន្តែឧបាយកលទាំងអស់នេះត្រូវបរាជ័យ ហើយបដិវត្តន៍ពណ៌នៅកម្ពុជាត្រូវបានគាស់ឫសផ្ដួលរំលំ ។ កឹម សុខា ក៏បានសារភាពជាចំហហើយថា សហរដ្ឋអាមេរិកជាអ្នកជួយគាត់ឲ្យអនុវត្តផែនការ ដើម្បីផ្ដួលរំលំរាជរដ្ឋាភិបាល ដោយយកគំរូតាមប្រទេសយូហ្គោស្លាវី និងស៊ែប៊ី ។

ទង្វើទាំងអស់នេះ គឺផ្ទុយទាំងស្រុងពីរដ្ឋធម្មនុញ្ញ ផ្ទុយពីគោលការណ៍ដ៏ត្រឹមត្រូវនៃលទ្ធិប្រជាធិបតេយ្យ នីតិរដ្ឋ និងផ្ទុយពីឆន្ទៈរបស់ប្រជាជន ប៉ុន្តែវាត្រឹមត្រូវតតខ្មោះ បើពិនិត្យអំពីសកម្មភាពទាំងនេះទៅនឹង និយមន័យ និងខ្លឹមសារនៃការធ្វើបដិវត្តន៍ពណ៌ ។ តាមរយៈភស្តុតាងជាច្រើនបានបង្ហាញថា មេដឹកនាំបក្សប្រឆាំងពិតជាបានប្រើប្រាស់ឧបាយកលយ៉ាងពិសពុល គ្រោះថ្នាក់បំផុត ក្នុងការផ្ដួលរំលំរដ្ឋអំណាចស្របច្បាប់ ខុសពីគោលការណ៍នៃលទ្ធិប្រជាធិបតេយ្យ ហើយសកម្មភាពនេះនឹងបំផ្លាញចោលនូវសមិទ្ធផលទាំងឡាយ ដែលប្រជាជនកម្ពុជាបានខិតខំប្រឹងប្រែងកសាងឡើងយ៉ាងលំបាក ក្នុងរយៈពេលជាង ៣០ឆ្នាំកន្លងមកនេះ។ តាមការសន្និដ្ឋាន និងវាយតម្លៃទៅលើព័ត៌មាន និងសកម្មភាពរបស់គណបក្សប្រឆាំង ដែលបានប្រព្រឹត្តតាំងពីមុនមកដល់ពេលនេះ ពួកគេនឹងមិនបោះបង់មហិច្ឆតាដ៏ខ្មៅកខ្វក់នេះឡើយ ទោះបីជារាជរដ្ឋាភិបាលដែលដឹកនាំដោយគណបក្សប្រជាជនកម្ពុជា និងដែលប្រសូតចេញពីការបោះឆ្នោតបាន និងកំពុងខិតខំប្រឹងប្រែងបម្រើប្រជាពលរដ្ឋ ក៏ដូចជាសង្គមយ៉ាងល្អប្រសើរយ៉ាងណាក៏ដោយ ។

រាជរដ្ឋាភិបាលកម្ពុជា ក្រោមការដឹកនាំរបស់**សម្ដេចតេជោ ហ៊ុន សែន** បានចាត់វិធានការម៉ឺងម៉ាត់តាមច្បាប់បំបាត់អំពើអនាធិបតេយ្យ បង្កភាពចលាចលក្នុងសង្គម ពង្រឹងសន្តិសុខសណ្ដាប់ធ្នាប់ឡើងវិញ ធ្វើឲ្យប្រជាជនកម្ពុជាទូទាំងប្រទេសអបអរសាទរ និងគាំទ្រយ៉ាងខ្លាំង ។ ការប៉ុនប៉ងរបស់មជ្ឈដ្ឋានអគតិ និងក្រុមប្រឆាំងដើម្បីផ្ដួលរំលំរាជរដ្ឋាភិបាលកម្ពុជា និងគណបក្សប្រជាជនកម្ពុជា តាមរយៈបដិវត្តន៍ពណ៌ត្រូវបរាជ័យ ។ ជោគជ័យនេះបានបង្ហាញឲ្យឃើញច្បាស់នូវការគាំទ្ររបស់ប្រជាជនកម្ពុជាចំពោះការដឹកនាំរបស់គណបក្សប្រជាជនកម្ពុជា និងរាជរដ្ឋាភិបាលកម្ពុជា ។ ជោគជ័យនេះក៏បង្ហាញឲ្យឃើញនូវស្មារតីអង់អាចក្លាហានរបស់កងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទ ដែលបានធ្វើសកម្មភាពដើម្បីការពាររដ្ឋធម្មនុញ្ញ ការពារជាតិ សាសនា ព្រះមហាក្សត្រ និងការពាររាជរដ្ឋាភិបាលស្របច្បាប់ ។ ទោះបីជាពួកប្រឆាំង និងមជ្ឈដ្ឋានអគតិទាំងនេះ ទទួលបរាជ័យក្នុងការប៉ុនប៉ងផ្ដួលរំលំរាជរដ្ឋាភិបាលកម្ពុជាស្របច្បាប់ តាមរយៈការធ្វើបដិវត្តន៍ពណ៌ ហើយក៏ដោយ ក៏ពួកនេះ មិនបោះបង់ចោលឧបាយកលដ៏ខ្មៅកខ្វក់នេះទេ ។ គណបក្សប្រជាជនកម្ពុជា និងរាជរដ្ឋាភិបាលកម្ពុជានៅតែប្រកាន់ខ្ជាប់គោលនយោបាយជាតិនិយមរបស់ប្រជាជន ការពារឲ្យបានដាច់ខាតឯករាជ្យ សេរីភាព ប្រជាធិបតេយ្យ បូរណភាពទឹកដី និងរដ្ឋធម្មនុញ្ញ មិនឲ្យពួកបរទេសធ្វើការជ្រៀតជ្រែក បំផ្លិចបំផ្លាញ តាមរយៈការធ្វើបដិវត្តន៍ពណ៌ ដោយចាត់តាំងជនក្បត់ជាតិឲ្យធ្វើសកម្មភាពនៅក្នុងប្រទេស កម្ពុជាយើងបានឡើយ ៕

# សម្តេចតេជោ ហ៊ុន សែន ៖ ពេលអ្នកទម្លាក់គ្រាប់បែកនៅកម្ពុជា តើមានគិតពីសិទ្ធិមនុស្សទេ?

## ✵ ការអនុវត្តផ្លូវច្បាប់ប្រសើរជាងការប្រើប្រាស់ប្រដាប់អាវុធដូចដែលមានការញុះញង់ដោយជនក្បត់ជាតិ

## ✵ ទាល់តែមានការស្លាប់មនុស្សទើបហៅថា ប្រជាធិបតេយ្យឬ?

## ✵ ឧទ្ទាមក្នុងទីក្រុងដោយធ្វើបដិវត្តន៍ពណ៌មិនត្រូវអនុញ្ញាតឲ្យមានជាដាច់ខាត



*សម្តេចតេជោ ហ៊ុន សែន អញ្ជើញជួបសំណេះសំណាលជាមួយ កម្មករ កម្មការិនីនៅសាលមហោស្រពកោះពេជ្រ*

ក្នុងខែតុលា ឆ្នាំ២០១៧ នេះ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានជួបសំណេះសំណាលជាមួយក្មួយៗចៅៗជាកម្មករកម្មការិនីនិយោជិត នៅក្នុងរាជធានីភ្នំពេញ និងបានអញ្ជើញចូលរួមក្នុងព្រឹត្តិការណ៍ធំៗមួយចំនួនទៀត។

✵ ព្រឹកថ្ងៃទី២ ខែតុលា សម្តេចតេជោបានអញ្ជើញចូលរួមជាអធិបតីភាពដ៏ខ្ពង់ខ្ពស់ក្នុងពិធីសម្ពោធសណ្ឋាគារ និងរមណីយដ្ឋានសុខាសៀមរាប។ ក្នុងឱកាសនោះ សម្តេចតេជោ បានថ្លែងបញ្ជាក់ថា យើងមិនអនុញ្ញាត និងមិនផ្តល់ឱកាសឲ្យអ្នកណាដែលបំផ្លាញដល់សន្តិសុខជាតិរបស់យើងនោះទេ ។ យើងកំពុងធ្វើសកម្មភាពបន្តទៀត ហើយមិនបញ្ចប់ត្រឹមចាប់ខ្លួនមនុស្សម្នាក់ទេ ព្រោះនេះជាការរៀបចំ និងការធ្វើសកម្មភាពជាប្រព័ន្ធតែម្តង។ ខ្ញុំនិយាយប៉ុណ្ណឹងអ្នកដទៃអាចយល់បានហើយ ។ យើងមិនអនុញ្ញាតឲ្យអ្នកឯងមកបំផ្លាញសន្តិសុខជាតិនោះទេ។ មានសន្តិភាព ទើបមានការអភិវឌ្ឍ។ មានការអភិវឌ្ឍនោះហើយទើបធានាបាននូវសន្តិភាព ។ អ្នកឯងមិនអាចធ្វើអ្វីស្រេចតែចិត្ត ហើយធ្វើជាខ្ញុំបម្រើបរទេសរួចហើយមកបំផ្លាញខ្មែរនោះទេ ។ មិនអាចអនុញ្ញាតដាច់ខាត ហើយយើងហ៊ានធ្វើ និងហ៊ានប្រឈមគ្រប់បញ្ហា ។ សម្តេចតេជោបន្តថា ទម្រាំបានសន្តិភាពដូចថ្ងៃនេះ យើងលំបាកខ្លាំងណាស់ មិនអាចឲ្យអ្នកឯងមកធ្វើឧទ្ទាមក្នុងទីក្រុងទេ។ ឧទ្ទាមក្នុងព្រៃវាជារឿងមួយ តែឧទ្ទាមក្នុងទីក្រុង ដោយធ្វើបដិវត្តន៍ពណ៌ មិនអនុញ្ញាតដាច់ខាត ។ អ្នកឯងបានធ្វើហើយក៏បានបរាជ័យ តែក៏កំពុងត្រៀមធ្វើបន្តទៀត។ សម្តេចតេជោបានបន្តថា សម្រាប់កម្ពុជាមានច្បាប់ដោយឡែករបស់កម្ពុជា ដែលកម្ពុជាខ្លួនឯងជាអ្នកកសាងនូវរដ្ឋមួយនេះ មិនអាចជំនួសដោយច្បាប់របស់ប្រទេសណាទេ ។

✵ ព្រឹកថ្ងៃទី៥ ខែតុលា សម្តេចតេជោនាយករដ្ឋមន្ត្រីកម្ពុជា បានអញ្ជើញជាអធិបតីដ៏ខ្ពង់ខ្ពស់នៅក្នុងទិវាគ្រូបង្រៀន ៥តុលា ក្រោមប្រធានបទ « គ្រូបង្រៀនជាវិស្វករព្រលឹងនៃយុវជនជំនាន់ក្រោយ » ដែលបានប្រារព្ធនៅវិទ្យាស្ថានជាតិអប់រំរាជធានីភ្នំពេញ ។

**សម្តេចតេជោ ហ៊ុន សែន** មានប្រសាសន៍ថា៖ តើមានវិធីណាដើម្បីលើកអាយុគ្រូបង្រៀនឲ្យដល់ ៦៥ឆ្នាំទេ? បច្ចុប្បន្នយើងឲ្យគ្រូចូលនិវត្តន៍នៅអាយុ ៦០ ឆ្នាំ ។ ប៉ុន្តែយើងបែរជារើសគ្រូចូលនិវត្តន៍ឲ្យមកបន្តធ្វើជាគ្រូជាប់កិច្ចសន្យា។ សម្តេចតេជោ បានគាំទ្រឲ្យមានការបន្តអាយុចូលនិវត្តន៍ដល់គ្រូបង្រៀន ព្រោះនេះជាតម្រូវការចាំបាច់របស់សង្គមដែលមួយឆ្នាំៗត្រូវឲ្យរើសគ្រូថ្មីរាប់ពាន់នាក់ ហើយការរើសនោះនៅតែមិនគ្រប់ ដែលតម្រូវឲ្យ យើងបែរជាយកគ្រូចូលនិវត្តន៍មកធ្វើជាគ្រូជាប់កិច្ចសន្យាទៅវិញ។ ដូចនេះគួរតែធ្វើការកែសម្រួលច្បាប់នោះ ដើម្បី ពន្យាអាយុចូលនិវត្តន៍របស់គ្រូបង្រៀន ។ សម្តេចតេជោសង្ឃឹមថាការពន្យានេះអាចធ្វើទៅបានអាស្រ័យលើរដ្ឋសភាតែប៉ុណ្ណោះ តែ រដ្ឋសភាប្រាកដជាគាំទ្រចំពោះសំណើនេះ ។

✵ ព្រឹកថ្ងៃទី៩ ខែតុលា សម្តេចតេជោនាយករដ្ឋមន្ត្រីកម្ពុជា បានអញ្ជើញជាអធិបតីដ៏ខ្ពង់ខ្ពស់ក្នុងពិធី ចែកសញ្ញាបត្រថ្នាក់បរិញ្ញាបត្ររង បរិញ្ញាបត្រ បរិញ្ញាបត្រជាន់ខ្ពស់ និងបណ្ឌិតនៃសាកលវិទ្យាល័យឯកទេសនៃកម្ពុជាចំនួន ៥.៨០៨នាក់នៅមជ្ឈមណ្ឌលសន្និសីទ និងពិព័រណ៍កោះពេជ្រ រាជធានីភ្នំពេញ។ក្នុងឱកាសនោះ សម្តេចតេជោបានប្រកាសថា ដោយពិនិត្យឃើញថាមន្ត្រីរាជការជាស្ត្រី និងកម្មការិនីត្រូវទទួលការគាំពារសង្គមពីរាជរដ្ឋាភិបាលក៏ប៉ុន្តែស្ត្រីដែលជាកងទ័ព និងស្ត្រីជាកងនគរបាលជាតិ ដែលសម្រាលកូន កន្លងទៅមិនបានទទួលការគាំពាសុខភាពពីរដ្ឋនៅឡើយ ។ ដូចនេះចាប់ពីខែ មករា ឆ្នាំ ២០១៨ នេះទៅស្ត្រីជាមន្ត្រីរាជការស៊ីវិល នគរបាល កងទ័ពនឹងត្រូវទទួលបានប្រាក់ឧបត្ថម្ភចំនួនប្រាំបីសែនរៀលសម្រាប់ការសម្រាលកូនមួយ, បើបានកូនភ្លោះពីរគឺទទួលបាន ១,៦លានរៀល និងបើបាន កូនភ្លោះបីគឺទទួលបាន ២,៤លានរៀល ។ សម្តេចតេជោបន្តថា បើពិនិត្យលទ្ធភាពថវិការបស់ជាតិគឺមិនមានបញ្ហាទេ ។ ព្រោះមន្ត្រីរាជការ និង កងកម្លាំងប្រដាប់អាវុធជាស្ត្រីបច្ចុប្បន្នមានចំនួន ៩២.១៩៨ នាក់ ក្នុងនោះស្ត្រីជាមន្ត្រីរាជការស៊ីវិលមានចំនួន ៨២.៥១៧នាក់, មន្ត្រីរាជការស៊ីវិលជាស្ត្រីនៅថ្នាក់កណ្តាលមានចំនួន ១៦.៥០៣ នាក់, ថ្នាក់ក្រោមជាតិមានចំនួន ៦៦.០១៤ នាក់, នគរបាលចំនួន ៣.៨៧៥ នាក់ ,កងទ័ពចំនួន ៥.៨០៦ នាក់ ។ តាមការប៉ាន់ប្រមាណស្ត្រីដែលត្រូវឆ្លងទន្លេក្នុងមួយឆ្នាំមានប្រមាណជាង ១០% ស្មើ

នឹងប្រមាណ ១០.៨៤៤ នាក់ ។ បើប៉ាន់ការចំណាយទៅលើប្រាក់គាំពារសង្គមសម្រាប់មន្ត្រី រាជការស៊ីវិលនិង កងកម្លាំងប្រដាប់អាវុធនៅពេលឆ្លងទន្លេក្នុងមួយឆ្នាំចំណាយអស់ប្រមាណ ២,១ លានដុល្លារអាមេរិក និងចំណាយទៅលើស្ត្រីជាកម្មការិនីឆ្លងទន្លេក្នុងមួយឆ្នាំប្រមាណជាង ១០ លានដុល្លារ។

❋ ព្រឹកថ្ងៃទី១០ខែតុលា សម្តេចតេជោអញ្ជើញជាអធិបតីដ៏ខ្ពង់ខ្ពស់នៅក្នុងពិធីផ្សព្វផ្សាយ និងដាក់ឲ្យអនុវត្តគោលនយោបាយជាតិស្តីពីការអប់រំបណ្តុះបណ្តាល បច្ចេកទេស និងវិជ្ជាជីវៈឆ្នាំ២០១៧-២០២៥ នៅវិមានសន្តិភាពទីស្តីការនាយករដ្ឋមន្ត្រី ។ ក្នុងឱកាសនោះ សម្តេចតេជោមានប្រសាសន៍ថា នៅក្នុងច្បាប់ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៨ រាជរដ្ឋាភិបាលកម្ពុជាបានសម្រេចបង្កើនថវិកាគាំពារសង្គម ដល់មន្ត្រីរាជការ ដែលទទួលមរណភាព និងបានបង្កើនកម្រិតដែលត្រូវយកពន្ធលើប្រាក់ខែផងដែរ។ រាជរដ្ឋាភិបាលសម្រេចបង្កើនប្រាក់មន្ត្រីរាជការស៊ីវិល ដែលទទួលមរណភាពធម្មតា (ដោយសារជំងឺ) នឹងទទួលបានប្រាក់ពីរលានរៀល។ ប៉ុន្តែសម្រាប់ មន្ត្រីរាជការស៊ីវិល ដែលទទួលមរណភាពក្នុងពេលបំពេញការងារនឹងទទួលថវិកាឧបត្ថម្ភបួនលានរៀល។

សម្តេចរំលឹកថា កន្លងទៅរាជរដ្ឋាភិបាល បានសម្រេចផ្តល់ថវិកាឧបត្ថម្ភដល់គ្រួសារសព មន្ត្រីរាជការ ១ លាន ២សែនរៀល សម្រាប់អ្នកទទួលមរណភាព ដោយសារជំងឺ និងថវិកា ១លាន ៥ សែនរៀលសម្រាប់មន្ត្រីរាជការស៊ីវិលទទួលមរណភាព ក្នុងពេលបំពេញបេសកកម្ម ។

សម្តេចតេជោមានប្រសាសន៍ថា ច្បាប់ថវិកាសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៨ ដែលត្រូវដាក់ឆ្លងនៅថ្ងៃទី២៧ ខែតុលាខាងមុខ បានដំឡើងថវិកាសម្រាប់មរណភាពរបស់មន្ត្រីរាជការស៊ីវិលស្លាប់ដោយជំងឺនិងការស្លាប់នៅក្នុងបេសសកកម្មការងារ គឺនៅមានកម្រិតទាបជាងកងកម្លាំងប្រដាប់អាវុធ ដែលពលី និងមរណភាពដោយជំងឺ ។ កម្លាំងប្រដាប់អាវុធ ដែលពលីទទួលបានថវិកា២៦ខែនៃប្រាក់បៀវត្សរ៍ចុងក្រោយ (ប្រាក់ខែពលទាហាន បច្ចុប្បន្នមានជាង ១ លានរៀល )។ សម្រាប់កងកម្លាំងប្រដាប់អាវុធ ដែលទទួលមរណភាពដោយសារជំងឺទទួលបានប្រាក់ឧបត្ថម្ភ ៧ ខែ នៃប្រាក់បៀវត្សរ៍ចុងក្រោយ។ ជាមួយនេះនៅមានប្រាក់ឧបត្ថម្ភផ្សេងៗ រួមមានប្រាក់បុណ្យសពទទួលបានមួយលើក ស្មើនឹង ១៥ ខែនៃប្រាក់ខែចុងក្រោយ និងក្រុមគ្រួសារសពទទួលបានប្រាក់ឧបត្ថម្ភមួយលើក ស្មើនឹងចំនួន ១៤ ខែ នៃបៀវត្សរ៍មូលដ្ឋានចុងក្រោយ ។

❋ ព្រឹកថ្ងៃទី១១ ខែតុលា សម្តេចតេជោនាយករដ្ឋមន្ត្រីកម្ពុជាបានបន្តជួបជាមួយកម្មករ កម្មការិនី និយោជិតជាងមួយម៉ឺននាក់នៅរោងចក្រកាត់ដេរតំបន់ផ្លូវវែងស្រែង (រោងចក្រ ISI) ខណ្ឌមានជ័យ រាជធានីភ្នំពេញ ។ នៅទីនោះសម្តេចតេជោបានផ្ញើសារនយោបាយមួយចំនួនទាក់ទងនឹងគណបក្សនយោបាយ និងគ្រាប់បែកគីមីរបស់អាមេរិកនៅខេត្តស្វាយរៀង។

សម្តេចតេជោមានប្រសាសន៍ថា៖ «បើរំលាយបក្សមួយបក្សប្រាំទៀតចូលជំនួស បានសេចក្តីថា ពីបក្សពីរឡើងទៅបក្សប្រាំមួយនៅក្នុងសភា។ នៅកម្ពុជាមានគណបក្សនយោបាយរាប់សិប។ វាជាឋានសួគ៌លោកិយនៃបក្សនយោបាយហើយវាក៏ជាឋានសួគ៌ នៃអង្គការក្រៅរដ្ឋាភិបាលដែរ ។

ក្នុងពិធីនោះ សម្តេចតេជោ ក៏បានថ្លែងទៅដល់អង្គការសហប្រជាជាតិ (អ.ស.ប) ផងដែរទាក់ទិនទៅនឹងការគាំទ្រខ្មែរក្រហមឲ្យគ្រប់គ្រងអាសនៈកម្ពុជានៅអ.ស.ប អំឡុងឆ្នាំ១៩៧៩ ដល់ឆ្នាំ ១៩៩១។ សម្តេចចាត់ទុកថាការគាំទ្រនោះជារឿងដ៏អាមាស់មួយរបស់អ.ស.ប។ សម្តេចតេជោមានប្រសាសន៍ថា៖ « ២៣ ខែតុលា កិច្ចព្រមព្រៀងទីក្រុងប៉ារីសខិតជិតមកដល់ហើយ។ ខ្ញុំគិតថា រាប់ទាំងអ.ស.ប ជាការគួរឲ្យអាមាស់ណាស់ ដែលបានបន្តការគាំទ្ររបបប្រល័យពូជសាសន៍ប៉ុលពតឲ្យអង្គុយនៅ អ.ស.ប តាំងពីឆ្នាំ ១៩៧៩ រហូតមកទល់ឆ្នាំ១៩៩១ នៅមុនពេលដែលក្រុមប្រឹក្សាជាតិជាន់ខ្ពស់ចូលទៅកាន់កាប់អាសនៈនៅទីនោះ ។ វាជាការចំអកនៃលទ្ធិប្រជាធិបតេយ្យនិងសិទ្ធិមនុស្ស ដែលគេស្រែកក្តែងៗ ហើយពួកគេមិនទទួលស្គាល់ការពិត ។ ប៉ុន្តែឥឡូវពីការដែលពួកគេមិនទទួលស្គាល់ទៅជាការទទួលស្គាល់ហួសហេតុនិង ទាមទារឲ្យមានការកាត់ទោសមនុស្សមិនត្រឹមតែមេក្លោងប៉ុន្មាននាក់ទេ ក៏ប៉ុន្តែគេចង់ពង្រីកនូវវិសាលភាពនៃការកាត់ទោស ដែលអាចនាំទៅដល់អស្ថិរភាពប្រទេសនេះទៀតផង»។

ទាក់ទងនឹងគ្រាប់បែកគីមីរបស់អាមេរិក នៅខេត្តស្វាយរៀង សម្តេចតេជោមានប្រសាសន៍ថា៖ ឥឡូវអាវុធគីមីបានរកឃើញនៅច្រើនទីតាំងក្នុងខេត្តស្វាយរៀង។ ដំបូងយើងគិតថាមានតែពីរទីតាំងប៉ុណ្ណោះទេ តែឥឡូវយើងរកឃើញមានប្រាំបួនទីតាំងអាវុធគីមី។ ដូចនេះសុំឲ្យរដ្ឋមន្ត្រីក្រសួងសុខាភិបាល ត្រូវធ្វើការស្រាវជ្រាវនៅក្នុងតំបន់នោះ ព្រោះយើងទើបតែរកឃើញនៅប៉ុន្មានខែនេះទេ ។ ដូចនេះយើងបានរស់នៅជាមួយអាវុធគីមីនេះរយៈពេលរាប់សិបឆ្នាំមកហើយ។ ជាង៤០ឆ្នាំមកហើយបើរាប់តាំងពីគេទម្លាក់ ។ ដូចនេះតើសុខភាពរបស់ប្រជាជននៅតំបន់នេះយ៉ាងម៉េច?

សម្តេចតេជោបានបន្តថា អាវុធគីមីនេះមិនមែនមានតែនៅខេត្តស្វាយរៀងនោះទេ វាអាចមាននៅតំបន់មួយចំនួនទៀតដូចជាតំបន់មេមត់ (ខេត្តត្បូងឃ្មុំ)និង កន្លែងដទៃទៀត ព្រោះកាលពីឆ្នាំ១៩៧០ គេប្រើអាវុធគីមីនេះទម្លាក់មកលើកម្ពុជា ដើម្បីឲ្យស្លឹកឈើជ្រុះស្រួលមើលពួកយៀកកុង និងទ័ពតស៊ូ ។ សម្តេចតេជោបន្ថែមថា គេអាចធ្វើទៅរួចដោយមិនបានគិតអំពីសិទ្ធិមនុស្សទេ។ ឥឡូវយើងគ្រាន់តែប្រើច្បាប់ដើម្បីការពារជាតិ ការពារប្រជាជន ដើម្បីការពារសន្តិសុខជាតិគេថាយើងរំលោភសិទ្ធិមនុស្ស បំបិទសេរីភាព ។ សម្តេចតេជោបានលើកជាសំណួរថា នៅពេលគេលើកដៃ សម្លាប់យើងបាញ់យើង, ទម្លាក់គ្រាប់បែក លើក្បាលរបស់យើង តើគេមានគិតអំពីសិទ្ធិរបស់ប្រជាជនកម្ពុជាទេ? សូមមិត្តបរទេសយល់អំពីសភាពការណ៍របស់កម្ពុជា។ អតីតកាលឈឺចាប់មួយនេះបង្ហាញថា អស់លោកអ្នកមិនបានគោរពយើងខ្ញុំទេ។ អស់លោកបានគាំទ្រ ប៉ុល ពតនៅឯអ.ស.ប។ អស់លោកមិនបានគិតពីសិទ្ធិមនុស្សទេ។ ប៉ុន្តែនៅពេលដែលយើង ខ្ញុំអនុវត្តត្រឹមច្បាប់ដើម្បីគ្រប់គ្រងរដ្ឋមួយប្រកបដោយសន្តិភាព ឯករាជ្យ អស់លោកបែរជាថា នេះជាដំណើរការបំផ្លាញប្រជាធិបតេយ្យ ។ តើប្រជាធិបតេយ្យទាល់តែមានការស្លាប់

មនុស្សទើបហៅថា ប្រជាធិបតេយ្យឬ? សម្ដេចតេជោក៏បានអំពាវនាវឲ្យប្រជាពលរដ្ឋកម្ពុជាក្រោកឈរឡើងរួមគ្នាដើម្បីការពារសន្តិភាពរបស់ប្រទេស។ សន្តិភាពនោះហើយដែលធានាដល់ការអភិវឌ្ឍសម្រាប់យើង ទៅថ្ងៃអនាគត ។

✵ ព្រឹកថ្ងៃទី១៤ ខែតុលា សម្ដេចតេជោនាយករដ្ឋមន្ត្រីកម្ពុជាបានអញ្ជើញជាអធិបតីភាពដ៏ខ្ពង់ខ្ពស់នៅក្នុងពិធីជួបជាមួយសិស្សប្រឡងបាក់ឌុបឆ្នាំ២០១៧ ទូទាំងប្រទេសទទួលនិទ្ទេស អេ(A) ចំនួនជាង៤០០នាក់នៅវិមានសន្តិភាពនៃទីស្ដីការនាយករដ្ឋមន្ត្រី។ ក្នុងឱកាសនោះ សម្ដេចបានរំលឹកទៅដល់ព្រះមហាវីរក្សត្រព្រះបរមរតនកោដ្ឋនិង កិច្ចព្រមព្រៀងទីក្រុងប៉ារីស។

សម្ដេចតេជោបញ្ជាក់ថា ព្រះរាជបូជនីយកិច្ចរបស់ព្រះករុណាសម្ដេចឪ សម្ដេចតា សម្ដេចតាទួតនៃយើង ព្រះអង្គបានបូជាពេញមួយជីវិតរបស់ព្រះអង្គ ដើម្បី ឯករាជ្យ សេរីភាពនិង ការបង្រួបបង្រួមជាតិរបស់កម្ពុជា។ ប្រសិនបើគ្មានព្រះរាជបូជនីយកិច្ចនេះទេ យើងដាក់សញ្ញាសួរថាតើអនាគតកម្ពុជាមកដល់ពេលនេះវាយ៉ាងម៉េច ? ជាពិសេសវត្តមានរបស់ព្រះអង្គក្នុងការតស៊ូទាមទារឯករាជ្យពីបារាំង ៩ វិច្ឆិកា ឆ្នាំ១៩៥៣ ដែលពេលនោះជាកាលបរិច្ឆេទចុងក្រោយនៃការចាកចេញរបស់បារាំងពីប្រទេសកម្ពុជា» ។ នៅសល់តែប៉ុន្មានថ្ងៃទៀតប៉ុណ្ណោះខួប២៤ ឆ្នាំកិច្ចព្រមព្រៀងទីក្រុងបារីសថ្ងៃ ២៣ តុលា ។ យើងចោទសួរថា បើគ្មានវត្តមានរបស់ព្រះអង្គទេកិច្ចព្រមព្រៀងទីក្រុងប៉ារីសមានឬអត់ ? នៅក្នុងតំណាក់កាលនេះតួអង្គពីរដ៏សំខាន់គឺ បើគ្មានវត្តមានរបស់ព្រះអង្គ ក៏គ្មានវត្តមានកិច្ចព្រមព្រៀងទីក្រុងប៉ារីស ហើយបើមិនមានវត្តមាន ហ៊ុន សែន ក៏គ្មានវត្តមានកិច្ចព្រមព្រៀងទីក្រុងប៉ារីសដែរ ។ គេអាចបោះបង់ចោលការចរចាជាមួយក្រុមខ្មែរក្រហម និងក្រុមរបស់លោក សឺន សាន បាន តែមិនអាចបោះបង់ចោលការចរចារវាងសម្ដេចព្រះ នរោត្តម សីហនុ និងមិនអាចបោះបង់ចោលការចរចាជាមួយនាយករដ្ឋមន្ត្រី ហ៊ុន សែន បានឡើយ ។ ជំនួប សីហនុ ហ៊ុន សែន ហ្វេរអង់ តាឌឺន័រ ថ្ងៃទី ២ ធ្នូ ១៩៨៧ គឺជាចរន្តសំខាន់បំផុតឆ្ពោះមកកាន់តំណាក់កាលនៃការចរចាស្វែងរកសន្តិភាពសម្រាប់កម្ពុជា។

✵ ព្រឹកថ្ងៃទី ១៨ ខែតុលា **សម្ដេចតេជោ ហ៊ុន សែន** បានអញ្ជើញជួប នៅសំណេះសំណាលជាមួយកម្មករ កម្មការិនីរោងចក្រ ចំនួន ១០ នៅតំបន់កំបូល ខណ្ឌពោធិសែនជ័យ រាជធានីភ្នំពេញ ។ នៅទីនោះសម្ដេចតេជោបានថ្លែងជា ថ្មីម្ដងទៀតទាក់ទងទៅនឹងប្រជាធិបតេយ្យ និងសង្គ្រាមនៅកម្ពុជាដែលបង្កដោយសហរដ្ឋអាមេរិក។

សម្ដេចតេជោបានចោទជាសំណួរទៅកាន់អាមេរិកថា នៅពេលគាំទ្រឲ្យមានរដ្ឋប្រហារទម្លាក់អតីតព្រះមហាក្សត្រខ្មែរ សម្ដេចព្រះ នរោត្តម សីហនុ ពួកអ្នកមានបានគិតពីឆន្ទៈរបស់ប្រជារាស្ត្រ ដែលបានបោះឆ្នោតសម្រាប់តំណែងព្រះប្រមុខរដ្ឋរបស់ សម្ដេចព្រះ នរោត្តម សីហនុដែរឬទេ? តើពួកអ្នកបានគិតអំពីឆន្ទៈរាស្ត្រខ្មែរឬទេ? ពួកអ្នកអត់បានគិតអំពីឆន្ទៈរបស់រាស្ត្រទេ។ អ្នកគិតតែអំពីបញ្ហាថា សម្ដេចព្រះ នរោត្តម សីហនុ ដឹកនាំផ្ដាច់ការឬធ្វើនេះធ្វើនោះក្នុងពេលដែលព្រះអង្គមិនបានធ្វើអ្វីខុសនោះ។ ដើម្បីបម្រើឲ្យ



*សម្ដេចតេជោ ហ៊ុន សែន អញ្ជើញបើកការដ្ឋានសាងសង់ស្ពានបេតុងឆ្លងកាត់ទន្លេសាបថ្ងៃទី២៣ ខែតុលា ឆ្នាំ២០១៧*

សង្គ្រាមនៅវៀតណាមអ្នកត្រូវកាន់កាប់កម្ពុជា ហើយដោយសារសម្ដេចព្រះ នរោត្តម សីហនុ មិនធ្វើតាមបំណងរបស់ពួកអ្នកៗក៏ចាប់ផ្ដើមផ្ដួលរំលំសម្ដេចព្រះនរោត្តម សីហនុ ។

សម្ដេចតេជោក៏បានចោទសួរទៀតថា ចំពោះការទម្លាក់អតីតប្រធានាធិបតី និច សុន ថាតើបានសុំការសម្រេចពីរាស្ត្រឬទេ ? រឿងមួយទៀតខ្ញុំចង់ចង្អុលទៅមហាអំណាចដែលហៅថា បិតាប្រជា-ធិបតេយ្យ និងសិទ្ធិមនុស្ស គឺសហរដ្ឋអាមេរិកតែម្ដង។ នៅត្រង់ថាកាលពេលលោក និច សុន មានរឿងអាស្រូវហើយគេទម្លាក់លោក និច សុន ចេញពីតំណែង ហេតុអ្វីបានជាគ្មានអ្នកណាធ្វើអត្ថាធិប្បាយអំពីឆន្ទៈរាស្ត្រដែលបោះឆ្នោតឲ្យ លោក និចសុន ធ្វើប្រធានាធិបតី ? ខ្ញុំមិនចង់វាយប្រហារ វាយបកដោយទ្រឹស្ដីណាមួយទេ ។ ក៏ប៉ុន្តែហួសហេតុពេកក៏សុំផ្ញើសារទៅសម្រាប់អ្នកទាំងឡាយ ដែលបកស្រាយថា ការផ្ដន្ទាទោសចំពោះមេបក្សប្រឆាំងដែលប្រព្រឹត្តអំពើក្បត់ជាតិ និងបក្សនយោបាយដែលប្រព្រឹត្តជាប្រព័ន្ធនៃអំពើក្បត់ជាតិ ដែលអាចនឹងត្រូវរំលាយដោយតុលាការថា ក្បត់ឆន្ទៈរាស្ត្រ»។ តើនេះវាជាឡូស៊ិករបស់មនុស្សឆ្កួត ហើយគិតតែពីបកស្រាយយកត្រូវ ? ចំពោះគណបក្សប្រឆាំងវិញ សម្ដេចតេជោបានចោទសួរថា « កន្លងទៅនៅកម្ពុជា នៅពេលដែលអ្នកបានស្រែកថា ហ៊ុន សែន អើយចុះចេញទៅ អ្នកបានគិតអំពីឆន្ទៈរាស្ត្រ ដែលបានបោះឆ្នោតដោយសំឡេងភាគច្រើនលើសលប់ ឲ្យគណបក្សប្រជាជនកម្ពុជាឲ្យ ហ៊ុន សែន ធ្វើជានាយករដ្ឋមន្ត្រីឬទេ ? នេះជាចំណុចដែលអ្នកត្រូវគិត ហើយសូមអ្នកកុំគេចវេសថា រឿងនឹងជារឿងចាស់។ តែរឿងចាស់និងរឿងថ្មីវាដូចគ្នា ។ កុំធ្វើជាឡូស៊ិករបស់ពួកឆ្កួត »។

សម្ដេចតេជោ ក៏បានបង្ហើបអំពីភស្តុតាងថ្មីទៀតពាក់ព័ន្ធ នឹងអំពើក្បត់ជាតិរបស់លោក សម រង្ស៊ី បើទោះបីសម្ដេចមិនបានបញ្ចេញ ឈ្មោះអ្នកនិយាយក៏ដោយ ។ សម្ដេចតេជោថ្លែងថាសម្ដេចបានឃើញឃ្លីបថ្មីមួយទៀត ដែលនិយាយអំពីការអំពាវនាវឲ្យកងកម្លាំងប្រដាប់អាវុធចេញមក ដើម្បីបង្វែរចុងកាណុងផ្ដួលរំលំរដ្ឋាភិបាល ហ៊ុន សែន ។ ឃ្លីបនេះគេបាននិយាយតាំងពីថ្ងៃទី ៤ ខែមិថុនាឆ្នាំ ២០១១ នៅទីក្រុងឡូវែល រដ្ឋម៉ាសាឈូសេតសហរដ្ឋអាមេរិក ។ សម្ដេចតេជោបានបន្តថា ឃ្លីបនេះថ្មីត្បិតតែវាចាស់ តែវាបានផ្សាភ្ជាប់គ្នា។ គេបាននិយាយថា « របប ហ៊ុន សែន

ផិតដួលរលំហើយ ការបះបោរ យើងត្រូវការរៀបចំការណែនាំ។ យើងត្រូវការការឧបត្ថម្ភ ដើម្បីឲ្យការបះបោរផ្ទុះឡើងនិងកងកម្លាំងបែរចុងកាណុង ផ្តួលរំលំរបបហ៊ុនសែនផ្តាច់ការ»។

ពាក់ព័ន្ធនឹងឃ្លីបថ្មីនេះ សម្តេចតេជោបានលើកជាសំណួរថា តើនៅទីនេះវាជាអ្វី? ហើយកន្លងទៅ ហ៊ុន សែន អើយចុះចេញទៅ ហើយបង្កើតចលនា ដែលធ្វើឲ្យមានការស្លាប់មនុស្សនៅផ្លូវវែងស្រែងវាជាអ្វី ? តើនេះជាទង្វើគោរពឆន្ទៈរាស្ត្រដែរឬ ? ឬក៏ជាទង្វើកុប្បកម្មផ្តួលរំលំក្រោមការបង្គាប់បញ្ជារបស់បរទេស ដើម្បីបង្កើតនូវសង្គ្រាមឡើងវិញនៅកម្ពុជា? អ្នកបានធ្វើរួចមកហើយ។ អ្នកបានចាញ់តែអ្នកមិនទាន់បោះបង់ចោលនូវឧបាយកលនេះទេ ។

សម្តេចតេជោបានបង្ហើបថា កន្លងមកយើងបានបន្លាយខ្សែវែងដើម្បីស្ទូចយកត្រីធំនេះជារឿងចាំបាច់នៃការស្រាវជ្រាវ ។ សួរថានិយាយតាំងពីយូរមកហើយហេតុអ្វីទើបចាប់? វានៅត្រង់ថាតើការនិយាយនិង ភស្តុតាង វាស៊ីសង្វាក់គ្នាដែរឬអត់ ? សម្តេចបន្ថែមថា ដល់វាស៊ីសង្វាក់គ្នាហើយវាមិនមែនតែបុគ្គលម្នាក់ទេ បក្សទាំងមូលដែលពាក់ព័ន្ធចាំបាច់ត្រូវរំលាយដោយតុលាការ។ តែវាជាសមត្ថកិច្ចរបស់តុលាការដែលត្រូវសម្រេចនៅពេលខាងមុខ ។

✵ ព្រឹកថ្ងៃទី២២ ខែតុលា **សម្តេចតេជោ ហ៊ុន សែន** បានបន្តជួបសំណេះសំណាលជាមួយតំណាងកម្មករ និយោជិត ជាងបួនពាន់នាក់ នៅសាលមហោស្រពកោះពេជ្រ ។ ក្នុងឱកាសនោះ សម្តេចតេជោបានថ្លែងថា នៅពេលដែលគណបក្សសង្គ្រោះជាតិត្រូវរំលាយ មេឃុំ ចៅសង្កាត់រួមទាំងជំទប់ ឬសមាជិកក្រុមប្រឹក្សារបស់សង្គ្រោះជាតិនៅតែរក្សាតំណែងដដែល ប្រសិនបើពួកគេលាឈប់ពីគណបក្សដើម និងព្រមមករួមរស់ជាមួយគណបក្សប្រជាជនកម្ពុជា ។

សម្តេចតេជោបានហៅការទទួលយកមេឃុំ ចៅសង្កាត់ ជំទប់ ឬសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ នេះថា ជាការអនុវត្តនយោបាយឈ្នះឈ្នះ ដែលសម្តេចធ្លាប់បានធ្វើជាមួយខ្មែរក្រហម។ សម្តេចតេជោបានបញ្ជាក់ថា «ឥឡូវខ្ញុំសូមផ្តាំមេឃុំ-ចៅសង្កាត់ របស់គណបក្សសង្គ្រោះជាតិ ឬជំទប់ ឬសមាជិករបស់សង្គ្រោះជាតិ បើអ្នកចង់រក្សាជាចៅសង្កាត់ជាមេឃុំតទៅទៀត អ្នកប្តូរជីវភាពមកចូលគណបក្សប្រជាជនកម្ពុជាទៅ។ គណបក្សរបស់អ្នករលាយហើយ។ អ្នកមិនអាចនៅធ្វើមេឃុំ ចៅសង្កាត់ ឬជំទប់ ឬសមាជិកក្រុមប្រឹក្សាបានទៀតទេ ក៏ប៉ុន្តែនៅពេលបក្សរលាយអ្នកចង់ទៅតាមបក្សក៏ចង់ទៅ ប៉ុន្តែបើអ្នកចង់នៅធ្វើមេឃុំ អ្នកប្រកាសចាកចេញពីគណបក្សនឹង ហើយសូមចូលគណបក្ស ប្រជាជន។ អីចឹងយើងរៀបចំបញ្ជីឈ្មោះឡើងវិញ ដាក់ក្នុងកូតាជាប់ជាចៅសង្កាត់ ឬមេឃុំ នៅនឹងតែម្តងវាមិនស្រួល។ ឥឡូវសង្គ្រោះបក្សឬសង្គ្រោះខ្លួនឯង...»។

✵ ព្រឹកថ្ងៃទី២៣ ខែតុលា សម្តេចតេជោនាយករដ្ឋមន្ត្រីកម្ពុជាបានអញ្ជើញជាអធិបតីភាពដ៏ខ្ពង់ខ្ពស់ក្នុងពិធីបើកការដ្ឋានសាងសង់ស្ពានបេតុងឆ្លងទន្លេសាប ភ្ជាប់ពីផ្លូវជាតិលេខ៥ ក្នុងភូមិសាស្ត្រខណ្ឌឫស្សីកែវ ទៅតំបន់អភិវឌ្ឍន៍ជ្រោយចង្វា និងភ្ជាប់ទៅផ្លូវជាតិលេខ ៦អា ក្នុងខណ្ឌជ្រោយចង្វា រាជធានីភ្នំពេញ ។ ក្នុងឱកាសនោះ សម្តេចបានរំលឹកទៅដល់កិច្ចព្រមព្រៀងទីក្រុងប៉ារីស ២៣ តុលា ឆ្នាំ១៩៩១ នោះ សម្តេចបញ្ជាក់ថា ដោយសារតែគេមិនគោរពកិច្ចព្រមព្រៀងក្រុងប៉ារីសនេះហើយ ទើបអង្គការចាត់តាំងនយោបាយនិងយោធារបស់ខ្មែរក្រហមត្រូវបានរំលាយ។ ដោយសារតែគេមិនគោរពកិច្ចព្រមព្រៀងក្រុងប៉ារីសនេះ ហើយបានជាមានគណបក្សនយោបាយមួយ នឹងអាចត្រូវរំលាយនៅពេលខាងមុខ ។

ទាក់ទិនទៅនឹងកាតព្វកិច្ចរបស់រាជរដ្ឋាភិបាល សម្តេចតេជោមានប្រសាសន៍ថា «កុំថាខ្ញុំកម្ចាត់ដៃគូនយោបាយឱ្យសោះ ព្រោះអ្នកតាំងខ្លួនជាសត្រូវរបស់ខ្ញុំ ហើយអ្នកមិនមែនគ្រាន់តែបំផ្លាញខ្ញុំទេ។ បើសិនអ្នកបំផ្លាញខ្ញុំ អ្នកក៏បំផ្លាញរាជរដ្ឋាភិបាលស្របច្បាប់មួយ ព្រោះខ្ញុំជានាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលស្របច្បាប់គេថាប្រឆាំងតែ ហ៊ុន សែន។ ចុះ ហ៊ុន សែន តំណាងឲ្យមនុស្សប៉ុន្មានទៅដែលបោះឆ្នោតឲ្យគណបក្សប្រជាជនកម្ពុជា? ហ៊ុន សែន កំពុងតែតំណាងឲ្យរដ្ឋអធិបតេយ្យមួយ ដែលត្រូវដឹកនាំអនុវត្តទាំងគោល-នយោបាយក្នុងប្រទេស និងក្រៅប្រទេស មិនអាចឲ្យអ្នកឯងមកផ្តួលរំលំបានលេងៗទេ »។

សម្តេចតេជោបានបន្ថែមទៀតថា «ខ្ញុំធ្លាប់បាននិយាយហើយដើម្បីការពារសេចក្តីសុខសាន្តរបស់ប្រជាជន ធានាសន្តិភាព ឱ្យប្រជាជន មិនឲ្យប្រជាជនធ្លាក់ទៅក្នុងសេចក្តីស្លាប់ យើងហ៊ានកម្ចាត់ចោលមនុស្សមួយចំនួនបើសិនជាចាំបាច់ ។ ដើម្បីការពារសមិទ្ធផលកិច្ចព្រមព្រៀង ២៣ តុលា, ការពារសមិទ្ធផលនៃនយោបាយឈ្នះឈ្នះ, ការពារសមិទ្ធផលសង្គមជាតិ ដែលយើងកសាងបានដោយលំបាករហូតមកដល់ពេលនេះ យើងប្តេជ្ញាអនុវត្តច្បាប់ដើម្បីការពារជាតិ ការពារប្រជាជន ហើយបើមានការតម្រូវកម្លាំងប្រដាប់អាវុធ ត្រូវត្រៀមជាស្រេចដើម្បីឆ្លើយតបជាមួយនឹងសភាពការណ៍ដែលវាកើតឡើង »។

សម្តេចតេជោបានព្រមានថា «សូមមេត្តាកុំមកចង់ផ្តួលរំលំ កុំលេងផ្លូវកាត់ឱ្យសោះ។ អ្នកមិនអាចទៅរួចទេ ហើយអ្នកក៏មិនអាចនឹងគេចវេសពីសំណាញ់ច្បាប់បានដែរ។ អំពើរបស់អ្នកត្រូវតែផ្តន្ទាទោសហើយ ហើយការអនុវត្តផ្លូវច្បាប់ប្រសើរជាងការប្រើប្រាស់កម្លាំងប្រដាប់អាវុធ ដូចដែលមានការញុះញង់ដោយជនក្បត់ ដែលចង់ប្រើប្រាស់ការបះបោរប្រដាប់អាវុធ ។ ការបះបោរប្រដាប់អាវុធ វានឹងនាំទៅដល់ការហូរឈាមនិងស្លាប់ជីវិតមនុស្ស ប៉ុន្តែការអនុវត្តផ្លូវច្បាប់គឺមិនស្លាប់មនុស្សទេ គ្រាន់តែជាប់គុក ព្រោះការជាប់គុកមិនមែនបណ្តាលមកពីគេធ្វើបាបអ្នកឯងទេ មកពីអ្នកឯងធ្វើខុសបានជាជាប់គុក ។ គ្មាននរណាគេទៅចាប់មនុស្សដែលមិនធ្វើខុសទៅដាក់គុកនោះទេ» ។

សម្តេចតេជោបានបន្តថា យើងបានចេញដំណើរពីស្ថានភាពដ៏លំបាក រហូតមកដល់ពេលនេះ យើងទទួលបានប៉ុណ្ណោះចាំបាច់ យើងត្រូវតែរក្សា មិនត្រូវឲ្យជនក្បត់ ក្រោមបញ្ជារបស់បរទេសណាមកបំផ្លិចបំផ្លាញនោះទេ ព្រោះនេះជាសោកនាដកម្មដែលយើងបានពើបប្រទះកាលពីអតីតកាល នៅពេលដែលគេផ្តួលរំលំសម្តេចព្រះនរោត្តម សីហនុ ព្រះប្រមុខរដ្ឋស្របច្បាប់នៃកម្ពុជា៕

# សម័យប្រជុំរដ្ឋសភាពិភាក្សា និងអនុម័តសេចក្តីស្នើវិសោធនកម្មច្បាប់ចំនួន៤ ដើម្បីធានាស្ថិរភាពនយោបាយយូរអង្វែងនៅកម្ពុជា





*សម្តេចអគ្គមហាពញាចក្រី ហេង សំរិន ប្រធានរដ្ឋសភា អញ្ជើញជាអធិបតីភាពដ៏ខ្ពង់ខ្ពស់ដឹកនាំ សម័យប្រជុំរដ្ឋសភា លើកទី៩ នីតិកាលទី៥*

នៅព្រឹកថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៧ **សម្តេចអគ្គមហាពញាចក្រី ហេង សំរិន** ប្រធានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា បានអញ្ជើញជាអធិបតីភាពដ៏ខ្ពង់ខ្ពស់ដឹកនាំ សម័យប្រជុំរដ្ឋសភា លើកទី៩ នីតិកាលទី៥ ដើម្បីពិភាក្សា និងអនុម័តទៅលើឯកសារមួយចំនួន។

ក្នុងនោះសេចក្តីស្នើវិសោធនកម្មច្បាប់ចំនួន៤ ដែលស្នើឡើងដោយក្រុមអ្នកតំណាងរាស្ត្រហត្ថលេខីចំនួន៤៩រូបក៏ត្រូវបានលើកយកមកធ្វើការពិភាក្សាសំដៅធានាឱ្យមានសង្គតិភាព ជាមួយច្បាប់ស្តីពី គណបក្សនយោបាយ និងធានាស្ថិរភាពនយោបាយឱ្យនៅស្ថិតស្ថេរយូរអង្វែងនៅព្រះរាជាណាចក្រកម្ពុជា ។ សម័យប្រជុំរដ្ឋសភាបាន៖ ១-ពិភាក្សា និងអនុម័តសេចក្តីស្នើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ២-ពិភាក្សា និងអនុម័តសេចក្តីស្នើច្បាប់ ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ៣-ពិភាក្សា និងអនុម័តសេចក្តីស្នើច្បាប់ស្តីពី វិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ និង៤-ពិភាក្សា និងអនុម័តសេចក្តីស្នើច្បាប់ស្តីពី វិសោធនកម្មច្បាប់ ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ ។

សមាជិក សមាជិកា រដ្ឋសភា មកពីគណបក្សប្រជាជនកម្ពុជា មានចំនួន៦៧រូបដែលក្នុងនោះក៏មានវត្តមាន**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជាផងដែរ បានអញ្ជើញចូលរួមក្នុងសម័យប្រជុំរដ្ឋសភា និងបានធ្វើការពិភាក្សា និងអនុម័តយល់ព្រម ដោយសំឡេងគាំទ្រចំនួន៦៧ លើ៦៧សម្លេងទៅលើសេចក្តីស្នើរវិសោធនកម្មច្បាប់ទាំង៤នោះ។

វិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្របានកែប្រែមាត្រា១៣៨-ស្ទួនបានកំណត់យ៉ាងច្បាស់ថា "ក្នុងនីតិកាលនៃរដ្ឋសភាប្រសិនបើមាន គណបក្សនយោបាយណាមួយ ប្រកាសបោះបង់ចោលអសនៈ ឬត្រូវលុបឈ្មោះចេញពីបញ្ជីគណបក្សនយោបាយឬត្រូវរំលាយស្របតាមច្បាប់ស្តីពីគណបក្សនយោបាយ បញ្ជីបេក្ខជន និងតំណាងរាស្ត្រទាំងអស់នៃគណបក្សនយោបាយនោះ លែងមានសុពលភាព និងលែងមានគុណសម្បត្តិតទៅទៀតហើយ។ ក្នុងករណីខាងលើនេះ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវធ្វើការបែងចែកអាសនៈដែលនៅទំនេរនោះ ក្នុងរយៈពេលយ៉ាងយូរ ៧ថ្ងៃ ទៅឱ្យគណបក្សនានា ដែលបានចូលរួមក្នុងការបោះឆ្នោត ក្នុងរាជធានី-ខេត្តជាមួយ ដោយមិនគិតបញ្ចូលគណបក្សនយោបាយ ដែលបោះបង់ចោលអាសនៈ ឬដែលត្រូវលុបឈ្មោះចេញពីបញ្ជីគណបក្សនយោបាយ ឬដែលត្រូវរំលាយស្របតាមច្បាប់ស្តីពីគណបក្សនយោបាយ និងគណបក្សនយោបាយមានអាសនៈក្នុងរដ្ឋសភា ដែលដឹកនាំរាជរដ្ឋាភិបាល..." ។

ឯកឧត្តមបណ្ឌិតរដ្ឋ **ជាម យៀប** តំណាងរាស្ត្រក្រុមហត្ថលេខីទាំង ៤៩រូប បានថ្លែងថា សេចក្តីស្នើវិសោធនកម្មច្បាប់ទាំង ៤នេះ គ្មានអ្វីពាក់ព័ន្ធទៅនឹងចេតនាចង់បំផ្លិចបំផ្លាញបុគ្គល ឬគណបក្សនយោបាយណាមួយនោះឡើយ ប៉ុន្តែដើម្បីឲ្យមានសង្គតិភាពជាមួយច្បាប់ស្តីពីគណបក្សនយោបាយ និងវិសោធនកម្មច្បាប់ស្តីពីគណបក្សនយោបាយ ដែលធ្វើឡើងជាបន្តបន្ទាប់ និងបទដ្ឋានទាំងឡាយដែលនៅជាធរមាន។

ឯកឧត្តម បានបន្ថែមថា ចំពោះការស្នើសុំធ្វើវិសោធនកម្មច្បាប់ទាំង ៤នេះ គឺសំដៅរៀបចំការបែងចែកអាសនៈរដ្ឋសភា ព្រឹទ្ធសភា ក្រុមប្រឹក្សាឃុំ សង្កាត់ និងក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ក្រោយពេលគណបក្សនយោបាយណាមួយ ដែលបានចូលរួមប្រកួតប្រជែងបោះឆ្នោតសកល ឬអសកល ហើយបានប្រព្រឹត្តបទល្មើស ធ្ងន់ធ្ងរ ត្រូវបានតុលាការ ឬសមត្ថកិច្ចរំលាយ និងរំសាយគណបក្សនោះចោលជាស្ថាពរ៕

# សម្ដេចវិបុលសេនាភក្ដី សាយ ឈុំ ផ្ដល់ដំបូន្មានឲ្យយុវជនត្រូវចេះប្រើឱកាសមាស ឱកាសពេជ្រ ដែលកម្ពុជាមានសព្វថ្ងៃ





*សម្ដេចវិបុលសេនាភក្ដី សាយ ឈុំ ប្រធានព្រឹទ្ធសភាអនុញ្ញាតឲ្យគណៈប្រតិភូយុវជន នៃសមាគមនាវាយុវជនអាស៊ីអគ្នេយ៍កម្ពុជាចំនួន ៣៣នាក់ ចូលជួបសម្ដែងការគួរសម*

**សម្ដេចវិបុលសេនាភក្ដី សាយ ឈុំ** ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា បានមានប្រសាសន៍ថា «យុវជនទាំងអស់ដែលកើតក្នុងសម័យនេះ ពិតជាមានសំណាងខ្លាំងណាស់ ដែលបានរស់នៅ និងសិក្សារៀនសូត្រពេញលេញក្នុងសង្គមមួយប្រកបដោយសុខសន្តិភាព និងការរីកចម្រើន ជាពិសេសមានការគាំទ្រការផ្ដល់ឱកាស និងការផ្ដល់តម្លៃយ៉ាងខ្លាំងដល់យុវជនដែលជាសសរទ្រូងរបស់ជាតិទាំងក្នុងពេលបច្ចុប្បន្ន និងអនាគត ពីសំណាក់រាជរដ្ឋាភិបាល និងសង្គមជាតិទាំងមូល»។

ក្នុងពេលអនុញ្ញាតឲ្យគណៈប្រតិភូយុវជន នៃសមាគមនាវាយុវជនអាស៊ីអាគ្នេយ៍កម្ពុជាចំនួន ៣៣នាក់ ចូលជួបសម្ដែងការគួរសម នាព្រឹកថ្ងៃទី១២ ខែតុលា ឆ្នាំ២០១៧ នៅវិមានព្រឹទ្ធសភា មុនពេលទៅចូលរួមក្នុងកម្មវិធី នាវាយុវជនអាស៊ីអាគ្នេយ៍ និងជប៉ុន លើកទី៤៤ ឆ្នាំ២០១៧ សម្ដេចវិបុលសេនាភក្ដីក៏បានកោតសរសើរ និងលើកទឹកចិត្តដល់ក្រសួងអប់រំយុវជន និងកីឡា ក៏ដូចជាសមាគមនាវាយុវជនអាស៊ីអាគ្នេយ៍កម្ពុជា ដែលបានខិតខំរៀបចំកម្មវិធីនេះឡើង ដើម្បីផ្ដល់ឱកាសដល់យុវជនកម្ពុជា បានពង្រីកនូវចំណេះដឹងរបស់ខ្លួន និងស្វែងយល់អំពីតួនាទីដ៏សំខាន់ នៃការចូលរួមរបស់យុវជនក្នុងការអភិវឌ្ឍសង្គមជាតិ ជាពិសេសផ្ដល់នូវការចែករំលែកបទពិសោធន៍នៃការអភិវឌ្ឍធនធានមនុស្ស និងការចូលរួមក្នុងសកម្មភាពរបស់សង្គមជាមួយនឹងបណ្ដាយុវជននៃប្រទេសជប៉ុន និងយុវជនមកពីប្រទេសអាស៊ានផ្សេងទៀត។ សម្ដេចភក្ដីបានផ្ដល់ដំបូន្មានដល់យុវជនថាក្មួយៗត្រូវចេះប្រើប្រាស់ឱកាសមាស ឱកាសពេជ្រដែលកម្ពុជាមានសព្វថ្ងៃនេះ ដើម្បីបង្កើតឱកាសសម្រាប់ខ្លួនឯង សម្រាប់ក្រុមគ្រួសារ សម្រាប់សហគមន៍និងសម្រាប់ជាតិរបស់យើង។

សម្ដេចប្រធានព្រឹទ្ធសភា បានបញ្ជាក់ថា ប្រទេសជាតិយើងកំពុងបោះជំហានទៅមុខយ៉ាងរឹងមាំលើមាគ៌ាសន្តិភាព ប្រជាធិបតេយ្យ សហប្រតិបត្តិការ និងអភិវឌ្ឍន៍។ រាជរដ្ឋាភិបាល បានខិតខំប្រឹងប្រែងណាស់ដើម្បីការពារឯករាជ្យជាតិ អធិបតេយ្យជាតិ និងបូរណភាពទឹកដីឲ្យបានគត់មត់ដូចដែលរដ្ឋធម្មនុញ្ញបានកំណត់។ សម្ដេចភក្ដីបានគូសបញ្ជាក់ថា ប្រជាជនយើងកំពុងសប្បាយរីករាយ ដោយបានទទួលនូវមនុញ្ញផលនៃសន្តិភាព និងការអភិវឌ្ឍហើយមានការប្ដេជ្ញាចិត្តខ្ពស់ណាស់ ដើម្បីបន្តកសាង និងអភិវឌ្ឍប្រទេសជាតិឲ្យឈានទៅកាន់ភាពសម្បូររុងរឿង ដូចបណ្ដាប្រទេសនៅក្នុងតំបន់ និងលើពិភពលោក ដែលមានការអភិវឌ្ឍ មានសេចក្ដីស្រឡាញ់ ហើយមិនមានការកើតឡើងវិញនូវសង្គ្រាមរបបប្រល័យពូជសាសន៍ និងការបែកបាក់ផ្ទៃក្នុងជាតិដូចកាលពីអតីតកាលនោះឡើយ។

**សម្ដេចភក្ដី សាយ ឈុំ** បានផ្ដាំផ្ញើដល់ក្មួយៗជាប្រតិភូយុវជនទាំងអស់ បន្តនូវការប្ដេជ្ញាចិត្ត និងឆន្ទៈមុតមាំ ចូលរួមចំណែកឱ្យបានកាន់តែសកម្មបន្ថែមទៀត ដើម្បីបុព្វហេតុ សន្តិភាព ស្ថិរភាព ការអភិវឌ្ឍនិងភាពសុខសាន្តសម្បូរណ៍រុងរឿងរបស់ប្រទេសកម្ពុជា។ ជាពិសេស ប្រតិភូយុវជនទាំងអស់ត្រូវចេះស្រឡាញ់យោគយល់អធ្យាស្រ័យ សាមគ្គីគ្នា និងធ្វើការងារជាក្រុមឲ្យបានល្អដើម្បីនាំនូវកិត្តិយសជូនប្រទេសជាតិកម្ពុជាដូចសុភាសិតថា នៅផ្ទះម្ដាយទីទៃ នៅព្រៃម្ដាយតែមួយ និងជូនពរដល់ប្រតិភូយុវជនទាំងអស់ទទួលបានសុខភាពល្អ កម្លាំងមាំមួន ប្រាជ្ញាឈ្លាសវៃ អញ្ជើញចូលរួមក្នុងកម្មវិធីនាវាយុវជនអាស៊ាន-ជប៉ុន ប្រកបដោយជោគជ័យ ៕

# សម្តេចក្រឡាហោម ស ខេង សុំឲ្យលុបបំបាត់ចោលទស្សនៈមើលស្រាលតួនាទីរបស់ស្ត្រី





*សម្តេចក្រឡាហោម ស ខេង អញ្ជើញជាអធិបតីក្នុងកិច្ចប្រជុំបូកសរុបលទ្ធផលនៃការអនុវត្តយុទ្ធសាស្ត្រ បញ្ជ្រាបយេនឌ័រ ២០១១-២០១៥ និងប្រកាសផ្សព្វផ្សាយផែនការយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រ ២០១៨-២០២៣*

**សម្តេចក្រឡាហោម ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃបាន អញ្ជើញជាអធិបតីក្នុងកិច្ចប្រជុំបូកសរុបលទ្ធផលនៃការអនុវត្តយុទ្ធសាស្ត្រ បញ្ជ្រាបយេនឌ័រ ២០១១-២០១៥ និងប្រកាសផ្សព្វផ្សាយផែនការយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រ ២០១៨-២០២៣ កាលពីព្រឹកថ្ងៃទី១៩ ខែតុលា ឆ្នាំ២០១៧ នៅទីស្តីការក្រសួងមហាផ្ទៃ ។

ក្នុងឱកាសនោះ សម្តេចក្រឡាហោមបានមានប្រសាសន៍ថា៖ ការលើកកម្ពស់សមភាពយេនឌ័រ ផ្អែកលើតួនាទី និងការទទួលខុសត្រូវរបស់ក្រសួងមហាផ្ទៃ ពោលគឺការថែរក្សាការពារសន្តិសុខ សុវត្ថិភាព និងសណ្តាប់ធ្នាប់សង្គមដែលជាមូលដ្ឋានគ្រឹះ នៃការអភិវឌ្ឍគ្រប់វិស័យប្រកបដោយចីរភាព ។សម្តេចក្រឡាហោមបញ្ជាក់ថា "ក្រុមការងារ យេនឌ័រក្រសួងមហាផ្ទៃ បានដើរតួនាទីយ៉ាងសំខាន់ក្នុងការប្រមូលផ្តុំ និងចងក្រងបណ្តាញសាខាជាក្រុមការងារយេនឌ័រតាមបណ្តាថ្នាក់ អគ្គនាយកដ្ឋានទាំងផ្នែករដ្ឋបាលស៊ីវិល កងកម្លាំងនគរបាលជាតិ និងផ្នែកខាងពន្ធនាគារ ដែលជាវិស័យធំទាំងបីរបស់ក្រសួងមហាផ្ទៃ និងមានភារកិច្ចចាំបាច់ក្នុងការកំណត់ បទដ្ឋាន និងគោលការណ៍នានា ក្នុងការលើកកម្ពស់សមធម៌ និងសមាសភាពយេនឌ័រ តាមរយៈការបញ្ជ្រាបទស្សនៈយេនឌ័រក្នុងការរៀបចំច្បាប់ គោលនយោបាយនានារបស់ក្រសួងមហាផ្ទៃ។ យើងមិនអាចមើលរំលងសមត្ថភាពរបស់ស្ត្រីក្នុងការបំពេញភារកិច្ចក្នុងអង្គភាព ស្ថាប័នបានឡើយ។ យើងត្រូវតែលុបបំបាត់ចោលទស្សនៈមើលស្រាលតួនាទីរបស់ស្ត្រី" ។

លោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃមានប្រសាសន៍ឲ្យដឹងថា នៅក្នុងតួនាទីជាសមាជិកសភាចំនួនស្ត្រីកើនឡើងជិត ៤ដង ចាប់តាំងពីពេលយើងបានធ្វើការបោះឆ្នោត ចំនួនស្ត្រីកើនពីចំនួន ៥,៦ % រហូតទៅដល់២០ % ។ នៅក្នុងជួរមន្ត្រីរាជការផ្នែកស៊ីវិលមានការកើនឡើងពី ៣៣ % ទៅដល់ ៣៧% ហើយក៏មានដាក់បញ្ចូលនិងតំឡើងឋានៈតួនាទីស្ត្រីនៅក្នុងការដឹកនាំគ្រប់កម្រិត បើទោះបីជាមិនទាន់មានច្រើនក៏ប៉ុន្តែយើងបានធ្វើពីមិនមានទៅមាន ហើយការដែលមាននេះទៀតក៏កំពុងតែត្រូវបានពង្រឹងគុណភាព ដោយសារតែស្ត្រីមានបទពិសោធន៍ ជាមួយការងារដែលបងប្អូនស្រីបានអនុវត្ត ហើយបានរៀនសូត្របន្ថែមទៀត។ ស្ត្រីជាច្រើនបាននឹងកំពុងតែធ្វើការងារប្រកបដោយប្រសិទ្ធភាព។ លោកជំទាវ **ជូ ប៊ុនអេង** បានបញ្ជាក់ថា ស្ត្រីបច្ចុប្បន្ននេះ បាននឹងកំពុងតែកសាងសមត្ថភាពផ្ទាល់ខ្លួន ដោយបានខិតខំរៀនសូត្រមានចំណេះដឹងខ្ពស់ ហើយក៏មានឆន្ទៈនៅក្នុងការចូលបម្រើក្នុងជួរ នៃមន្ត្រីសាធារណៈ ឬមួយក៏ផ្នែកពាក់ព័ន្ធផ្សេងៗ និងសង្ឃឹមថា ស្ត្រីទាំងនោះ នឹងរួមចំណែកធ្វើឲ្យមានកំណើន នៃការចូលរួម ក៏ដូចជាការទទួលបានឋានៈតួនាទីនៅក្នុងការដឹកនាំសង្គមកាន់តែច្រើនឡើងថែមទៀតនៅពេលអនាគត៕

# សកម្មភាពសមាជិករដ្ឋសភា_ព្រឹទ្ធសភា_រាជរដ្ឋាភិបាល និងមន្ត្រីគណបក្ស




ព្រឹកថ្ងៃទី១៩ ខែតុលា ឆ្នាំ២០១៧ នៅក្នុងភូមិត្រពាំងស្វាយ ឃុំបល្ល័ង្គ ស្រុកបារាយណ៍ ខេត្តកំពង់ធំ ឯកឧត្តមបណ្ឌិត **ខួន ញឹល** សមាជិកគណៈអចិន្ត្រៃយ៍នៃគណៈកម្មាធិការកណ្តាលគណ - បក្សប្រជាជនកម្ពុជា អនុប្រធានទី២ រដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា និងជាប្រធានក្រុមការងារគណបក្សថ្នាក់កណ្តាលចុះជួយខេត្តកំពង់ធំ បានអញ្ជើញជាអធិបតីកិច្ចប្រជុំជាមួយគណៈអចិន្ត្រៃយ៍គណៈកម្មាធិការគណបក្សប្រជាជនកម្ពុជា ខេត្តកំពង់ធំ និងអស់លោកប្រធានគណបក្សស្រុក-ក្រុង ទាំង៨ ដើម្បីត្រួតពិនិត្យលទ្ធផលការងារ កន្លងមក និងពិនិត្យពិភាក្សាសេចក្តីរាយការណ៍របស់គណៈអចិន្ត្រៃយ៍បក្សខេត្ត គណបក្សស្រុក-ក្រុងទាំង៨។

ថ្ងៃទី១៣ ខែតុលា ឆ្នាំ២០១៧ **សម្តេចពិជ័យសេនា ទៀ បាញ់** សមាជិកគណៈអចិន្ត្រៃយ៍គណៈកម្មាធិការកណ្តាលគណបក្សប្រជាជនកម្ពុជា ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ និងជាប្រធានអាជ្ញាធរជាតិអាវុធគីមី បានអញ្ជើញចុះពិនិត្យកិច្ចប្រតិបត្តិការបោសសំអាតគ្រាប់បែកអាវុធគីមី និងត្រួតពិនិត្យទីតាំងជាកន្លែងរុករកឃើញថ្មីៗ និងបានជួបសំណេះសំណាលជាមួយប្រជាពលរដ្ឋទាំង៥ភូមិក្នុងឃុំគគីរ ស្រុករមាសហែក ខេត្តស្វាយរៀងចំនួន៨៨៥គ្រួសារ ដែលរងផលប៉ះពាល់និងរងការគំរាមកំហែងដោយសារជាតិ គីមីទាំងនោះ។





នៅថ្ងៃទី១០ ខែតុលា ឆ្នាំ២០១៧ លោកជំទាវ **ម៉ែន សំអន** សមាជិកាគណៈអចិន្ត្រៃយ៍ គណៈកម្មាធិការកណ្តាលគណបក្សប្រជាជនកម្ពុជា ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួង ទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច តំណាងដ៏ខ្ពង់ខ្ពស់**សម្តេចតេជោ ហ៊ុន សែន** បានអញ្ជើញជាអធិបតីក្នុងពិធីបុណ្យពុទ្ធសាសនា នៅមជ្ឈមណ្ឌលពិព័ណ៌កោះពេជ្រ រាជធានីភ្នំពេញ ។ លោកជំទាវបានថ្លែងថា កម្ពុជាបច្ចុប្បន្ន ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់ **សម្តេចតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានដឹកនាំប្រទេសពីបាតដៃទទេរហូតដល់មាន ការអភិវឌ្ឍលើគ្រប់វិស័យទាំងពុទ្ធចក្រ និងអាណាចក្រ ក្នុងនោះវិស័យព្រះពុទ្ធសាសនា ក៏មានការរីកចម្រើនគួរឲ្យកត់សម្គាល់ផងដែរ។

ថ្ងៃទី ១០ ខែតុលា ឆ្នាំ២០១៧ ឯកឧត្តម **ប៊ិន ឈិន** សមាជិកគណៈអចិន្ត្រៃយ៍ គណៈកម្មាធិការកណ្តាលគណបក្សប្រជាជនកម្ពុជា ឧបនាយករដ្ឋមន្ត្រីប្រចាំការ រដ្ឋមន្ត្រីស្តីទីនៃទីស្តីការគណៈរដ្ឋមន្ត្រី និងជាប្រធានក្រុមការងារថ្នាក់ជាតិចុះជួយមូលដ្ឋានខេត្តតាកែវ បានអញ្ជើញជាអធិបតីក្នុងពិធីខួបលើកទី២០ឆ្នាំ នៃមន្ទីរពេទ្យភ្នែក ខេត្តតាកែវ និងទិវាសុខភាពភ្នែកពិភពលោក ដែលប្រារព្ធធ្វើឡើងនៅក្នុងបរិវេណមន្ទីរពេទ្យភ្នែកក្នុងក្រុង ដូនកែវ ខេត្តតាកែវ ។



# សកម្មភាពសមាជិករដ្ឋសភា_ព្រឹទ្ធសភា_រាជរដ្ឋាភិបាល និងមន្ត្រីគណបក្ស



ថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៧ ឯកឧត្តម **ទេព ងន** សមាជិកគណៈអចិន្ត្រៃយ៍គណៈកម្មាធិការកណ្ដាលគណបក្សប្រជាជនកម្ពុជា អនុប្រធានទី២ព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា និងជាប្រធានគណៈប្រតិភូសភាជាតិកម្ពុជា បានឡើងថ្លែងក្នុងមហាសន្និបាតអន្តរសភា លើកទី១៣៧ ស្ដីពីការលើកកម្ពស់ ពហុវប្បធម៌ និងសន្តិភាពតាមរយៈការសន្ទនាអន្តរជំនឿ និងអន្តរជាតិនៅវិមាន Tavrichesky ក្នុងទីក្រុង Saint Petersbur នៅសហព័ន្ធរុស្ស៊ី។ សភាកម្ពុជាបានផ្ដោតទៅលើទិសដៅសំខាន់ចំនួន៦ដូចជា៖ ១. លើកកម្ពស់នីតិរដ្ឋ យុត្តិធម៌សង្គម និងភាពស្មើគ្នាចំពោះមុខច្បាប់ ២. បង្កើនវប្បធម៌សន្ទនា វប្បធម៌ចែករំលែក និងវប្បធម៌ចូលរួម ៣. បង្កើនទំនាក់ទំនងរវាង អង្គការនីតិប្បញ្ញត្តិ នីតិប្រតិបត្តិអង្គការតុលាការថ្នាក់ក្រោមជាតិ អង្គការក្រៅរដ្ឋាភិបាល និងសមាគម ៤. ទប់ស្កាត់ឧបាយកលនយោបាយទុច្ចរិត ដែលអុចអាលការរើសអើងពូជសាសន៍ ការស្អប់ជនបរទេស និងភាពជ្រុលនិយមខាងនយោបាយ ៥. ទប់ស្កាត់ការជ្រៀតជ្រែកចូលកិច្ចការផ្ទៃក្នុងកម្ពុជាពីមជ្ឈដ្ឋាន អមិត្តដែលប្រើប្រាស់ប្រព័ន្ធឃោសនា បណ្ដាញសង្គម និងវេទិកានានា ៦. ជំរុញដំណើរសមាហរណកម្មកម្ពុជាទៅក្នុងក្របខណ្ឌតំបន់ និងពិភពលោក ។

ថ្ងៃទី៣ ខែតុលា ឆ្នាំ២០១៧ ឯកឧត្តម **ថោង ខុន** សមាជិកគណៈកម្មាធិការកណ្ដាលគណបក្សប្រជាជនកម្ពុជា រដ្ឋមន្ត្រីក្រសួងទេសចរណ៍ បានអញ្ជើញបញ្ចុះបឋមសិលាសាងសង់អគារសិក្សាបណ្ដុះបណ្ដាលវិជ្ជាជីវៈបច្ចេកវិទ្យាព័ត៌មាន ទេសចរណ៍ និងកសិកម្មកម្រិតបឋមដែលមានឈ្មោះថា «សាលាបណ្ដុះបណ្ដាវិជ្ជាជីវៈស្រុកបារាយណ៍» ក្នុងខេត្តកំពង់ធំ។ សាលាបណ្ដុះបណ្ដាវិជ្ជាជីវៈដែលមានកម្ពស់ ២ជាន់ នេះ សាងសង់ឡើងដោយប្រើប្រាស់ថវិកាជិត៦ ម៉ឺន ដុល្លារអាមេរិក អាចទទួលសិស្សឲ្យចូលរៀនបាន ៤៥នាក់ក្នុង ១ជាន់សម្រាប់ បណ្ដុះបណ្ដាលលើជំនាញសេវាកម្មទេសចរណ៍ ព័ត៌មានវិទ្យា និងជំនាញកសិកម្ម កម្រិតបឋម។





ថ្ងៃទី១៥ ខែតុលា ឆ្នាំ២០១៧ ឯកឧត្តម **ស៊ុយ សែម** សមាជិកគណៈកម្មាធិការកណ្ដាលគណបក្សប្រជាជនកម្ពុជា រដ្ឋមន្ត្រីក្រសួងរ៉ែ និងថាមពលបានអញ្ជើញជួបសំណេះសំណាល និងប្រគល់រង្វាន់លើកទឹកចិត្តជូនសិស្សានុសិស្សដែលបានប្រឡងជាប់បាក់ឌុបទូទាំងស្រុកបាកាន ខេត្តពោធិ៍សាត់ចំនួន១៤២នាក់។ ក្នុងស្រុកបាកានទាំងមូលមានសិស្សដែលទទួលបាននិទ្ទេសA ចំនួនមួយនាក់ និទ្ទេស B ចំនួន ២៤នាក់ និទ្ទេស C ចំនួន ៥២ នាក់ និទ្ទេស D ចំនួន ៣៧ នាក់ និងនិទ្ទេស E ចំនួន ១៣៦នាក់។

ថ្ងៃទី១៥ ខែតុលា ឯកឧត្តម **អ៊ិត សំហេង** សមាជិកគណៈកម្មាធិការកណ្ដាលគណបក្សប្រជាជនកម្ពុជា រដ្ឋមន្ត្រីក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ បានអញ្ជើញចុះជួបសំណេះសំណាល និងសួរសុខទុក្ខជាមួយពលករខ្មែរ ដែលកំពុងបម្រើការងារក្នុងរោងចក្រផលិតសាច់មាន់ GFPTស្ថិតក្នុងខេត្តឈុនប៊ុរី ប្រទេសថៃ។ នេះជាការចុះជួបលើកទី២ហើយ ដែលលើកទី១ បានធ្វើឡើងនៅខេត្តសមុទ្របាកាន។





នៅថ្ងៃទី១ ខែតុលា ឆ្នាំ២០១៧ ឯកឧត្តមបណ្ឌិត **ម៉ែន ស៊ីម៉ន** សមាជិកគណៈកម្មាធិការកណ្ដាលគណបក្សប្រជាជនកម្ពុជា ទីប្រឹក្សាផ្ទាល់**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និងជាអនុប្រធានទី១ក្រុមការងារថ្នាក់ កណ្ដាលចុះជួយខេត្តកំពត បានអញ្ជើញជួបសំណេះសំណាលជាមួយសិស្សជ័យលាភីប្រឡងសញ្ញាបត្រសិក្សាទុតិយភូមិឆ្នាំសិក្សា ២០១៦-២០១៧ នៅខេត្តកំពត។ ក្នុងឱកាសនោះ ឯកឧត្តមបានផ្ដល់ម៉ូតូម្នាក់ៗគ្រឿងដល់សិស្សដែលទទួលបាននិទ្ទេស A។

# សកម្មភាពសមាជិករដ្ឋសភា_ព្រឹទ្ធសភា_រាជរដ្ឋាភិបាល និងមន្ត្រីគណបក្ស



ថ្ងៃទី១២ ខែតុលា ឆ្នាំ២០១៧ ឯកឧត្តមវេជ្ជបណ្ឌិត **ម៉ម ប៊ុនហេង** សមាជិកគណៈកម្មាធិការកណ្ដាលគណបក្សប្រជាជនកម្ពុជា រដ្ឋមន្ត្រីក្រសួងសុខាភិបាល បានដឹកនាំក្រុមការងារចុះទៅដល់ឃុំគគីរ ស្រុករមាសហែក ខេត្តស្វាយរៀង ទីកដីដ៏ជូរចត់របស់ប្រជារាស្ត្រខ្មែរ ដែលទទួលរងឥទ្ធិពលអាក្រក់ពីសំណល់សង្គ្រាមដ៏ឈឺចាប់ បន្សល់ដោយសហរដ្ឋអាមេរិក កាលពីសម័យសង្គ្រាម ដើម្បីពិនិត្យមើលស្ថានភាពសុខភាពពលរដ្ឋ ដែលរងគ្រោះដោយសារចំហាយគីមីចេញពីគ្រាប់ប្រល័យលោកទាំងនោះ។



ថ្ងៃទី ០៧ ខែតុលា ឆ្នាំ ២០១៧ ឯកឧត្តម **លឹម គានហោ** សមាជិកគណៈកម្មាធិការកណ្ដាលគណបក្សប្រជាជនកម្ពុជា រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយមបានអញ្ជើញចុះពិនិត្យស្ថានភាពទឹកនៅខេត្តបន្ទាយមានជ័យ។ឯកឧត្តមបានធ្វើការណែនាំដល់ក្រុម ការងារបច្ចេកទេសរបស់ក្រសួង និងមន្ទីរធនធានទឹក និងឧតុនិយមខេត្តបន្ទាយមានជ័យ ត្រូវតែបន្តយកចិត្តទុកដាក់តាម ដាន និងធ្វើការបង្ហូរទឹកឱ្យបានទាន់ពេលវេលា បើទោះបីជាពេលនេះជំនន់ទឹកភ្លៀងនៅក្នុងស្រុកម៉ាឡៃ ក៏ដូចជានៅក្រុងប៉ោយប៉ែត បានស្រកផុត ទៅហើយក្តី ប៉ុន្តែភ្លៀងអាចនឹងនៅតែបន្តធ្លាក់ ។

ថ្ងៃទី១៧ តុលា ឯកឧត្តម **វេង សាខុន** សមាជិកគណៈកម្មាធិការកណ្ដាលគណបក្សប្រជាជនកម្ពុជា រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានអញ្ជើញជាអធិបតីក្នុងទិវាស្បៀងអាហារពិភពលោកឆ្នាំ២០១៧ ក្រោមប្រធានបទ ផ្លាស់ប្តូរអនាគតនៃការធ្វើចំណាកស្រុកតាមរយៈការវិនិយោគលើសន្តិសុខស្បៀង និងអភិវឌ្ឍន៍ជនបទ ។ ទិវានេះបានប្រារព្ធនៅឃុំទឹកជ្រៅ ស្រុកតំបែរ ខេត្តត្បូងឃ្មុំ។ ឯកឧត្តម ក៏បានជួបសំណេះសំណាលជាមួយប្រជាពលរដ្ឋនៅទីនោះ ផង។





នៅថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១៧ លោកជំទាវ **បាន ស្រីមុំ** អ្នកតំណាងរាស្ត្រមណ្ឌលប៉ៃលិន បានអញ្ជើញជាអធិបតីក្នុងពិធីដាំកូនឈើ និងផ្តល់សម្ភារៈសិក្សា ដល់លោកគ្រូ អ្នកគ្រូ សិស្សានុសិស្សនៃវិទ្យាល័យ **ហ៊ុន សែន** ក្រុងទេពនិម្មិត្តប៉ៃលិន ក្រោមប្រធានបទ "ក្តីសង្ឃឹម" រៀបចំដោយកម្មសិក្សាការីមន្ត្រីជាន់ខ្ពស់ បន្ទប់សម្ភុបុរៈ វេនព្រឹក នៃសាលាភូមិន្ទរដ្ឋបាល សហការជាមួយ ស.ស.យ.ក ខេត្តប៉ៃលិន ដើម្បីបណ្តុះគំនិតឆ្នៃប្រឌិត ការផ្តួចផ្តើមថ្មី ផ្លាស់ប្តូរទស្សនៈ និងបទពិសោធរបស់សិក្ខាកាម។ ពិធីនេះមានការអញ្ជើញចូលរួមពីអាជ្ញាធរខេត្ត ក្រុមប្រឹក្សាខេត្ត មន្ទីរអប់រំយុវជន និងកីឡាខេត្ត កម្មសិក្សាការីមន្ត្រីជាន់ខ្ពស់ បន្ទប់សម្ភុបុរៈ វេនព្រឹក នៃសាលាភូមិន្ទរដ្ឋបាល សហភាព សហព័ន្ធ យុវជនកម្ពុជាខេត្ត លោកគ្រូ អ្នកគ្រូ សិស្សានុសិស្សសរុបប្រមាណ ៣០០នាក់។

ថ្ងៃទី១៦ខែតុលា ឯកឧត្តម **ស ថាវី** សមាជិកគណៈកម្មាធិការកណ្ដាលគណបក្សប្រជាជនកម្ពុជា អភិបាលនៃគណៈអភិបាលខេត្តឧត្តរមានជ័យបានអញ្ជើញចូលរួមវេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់នៅសាលាក្រុងសំរោង។ក្នុងឱកាសនោះឯកឧត្តមបានសំណេះសំណាលជាមួយប្រជាពលរដ្ឋដោយបញ្ជាក់អំពីអ្វីដែលប្រមុខរាជរដ្ឋាភិបាលបានយកចិត្តទុកដាក់ក្នុងការដោះស្រាយការពិបាកជូនប្រជាជន។



# សកម្មភាពរបស់ក្រុមការងារយុវជនគណបក្ស



*នៅថ្ងៃទី១៤-១៥ ខែតុលា ឆ្នាំ២០១៧នេះ ក្រុមគ្រូឧទ្ទេស នៃក្រុមការងារយុវជនគណបក្សថ្នាក់កណ្តាល បានមកចែករំលែកចំណេះដឹង និងបទពិសោធន៍ជូនបងប្អូនក្រុមសកម្មជនយុវជនគណបក្ស នៅតាមបណ្តាស្រុកទាំង៨ និងបណ្តាមន្ទីរជុំវិញខេត្តព្រះវិហារ។ ពិធីបិទវគ្គបញ្ច្រាបកម្មវិធីអប់រំនយោបាយ និងបង្កើនសមត្ថភាពដល់ក្រុមការងារយុវជនគណបក្សខេត្ត ក្រុងស្រុក និងក្រុមសកម្មជនគណបក្សខេត្តព្រះវិហារ ធ្វើឡើងនាព្រឹកថ្ងៃ ទី១៥ ខែតុលា ឆ្នាំ២០១៧ ក្រោមអធិបតីភាព ឯកឧត្តម នាយឧត្តមសេនីយ៍ **មាស សុភា** ប្រធានក្រុមការងារថ្នាក់ជាតិចុះជួយខេត្ត និងឯកឧត្តម **អ៊ុន ចាន់ដា** ប្រធានគណបក្សខេត្ត ជាសមាជិកក្រុមការងារយុវជនគណបក្សថ្នាក់កណ្តាល រួមជាមួយថ្នាក់ដឹកនាំសមាជិកសមាជិកាជាច្រើនរូបទៀត។*



នៅសៀលថ្ងៃទី០៣ ខែតុលា ឆ្នាំ២០១៧ ពិធីសំណេះសំណាលក្រោមអធិបតីភាពឯកឧត្តមបណ្ឌិត **គន់ គីម** សមាជិកគណៈអចិន្ត្រៃយ៍គណៈកម្មាធិការកណ្តាលគណបក្ស និងជាប្រធានក្រុមការងារថ្នាក់កណ្តាលចុះជួយខេត្តឧត្តរមានជ័យ ដោយមានការចូលរួមពី ឯកឧត្តម **លៀម សុជា** សមាជិកក្រុមការងារយុវជនគណបក្សថ្នាក់កណ្តាល និងជាប្រធានក្រុមការងារយុវជនគណបក្សខេត្តឧត្តរមានជ័យ ក្រុមការងារយុវជនគណបក្ស និងសសយកខេត្ត ក្រុង ស្រុក ឃុំ សង្កាត់ ចំនួន៨២រូប។ ឯកឧត្តមបណ្ឌិត **គន់ គីម** ក៏បានឧបត្ថម្ភថវិកាជូនយុវជនក្នុងម្នាក់ៗ ចំនួន ២០ ដុល្លារ និងបានឧបត្ថម្ភទូរស័ព្ទ ស្មាតហ្វូន ចំនួន ០៦គ្រឿង ដល់យុវជនដែលគ្មានទូរស័ព្ទស្មាតហ្វូន។



*ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០១៧ ឯកឧត្តម **កែ ប៊ុនខៀង** ប្រធានក្រុមការងារយុវជនគណបក្សថ្នាក់កណ្តាល និង ឯកឧត្តម **គង់ ម៉ូរ៉ា** សមាជិកក្រុមការងារយុវជនគណបក្សថ្នាក់កណ្តាលឯកឧត្តម **ឈឹម ម៉ា** អ្នកតំណាងរាស្ត្រមណ្ឌលសៀមរាប បានអញ្ជើញជាអធិបតីភាពក្នុងពិធីបើកវគ្គបំប៉នការងារចាត់តាំង និងបានធ្វើបទឧទ្ទេសនាម ជូនវគ្គដែលក្នុងនោះមានសមាសភាពសិក្ខាកាមមកពី ក្រុមការងារយុវជនគណបក្សខេត្ត-ស្រុក-ឃុំ មន្ត្រីគណបក្សស្រុក-ឃុំ និងក្រុមការងារចុះជួយគណបក្សឃុំ នៅស្រុកពួក ខេត្តសៀមរាប ដែលមានសមាជិកជាយុវជនចូលរួមចំនួន ២០២នាក់។*



គណៈប្រតិភូដែលដឹកនាំដោយ ឯកឧត្តម **ហ៊ុន ម៉ាណែត** អនុប្រធានក្រុមការងារយុវជនគណបក្សថ្នាក់កណ្តាល និងជាប្រធានក្រុមការងាររៀបចំអង្គការចាត់តាំងយុវជននៅក្រៅប្រទេស ឯកឧត្តម **ហួត ហាក់** សមាជិកក្រុមការងារយុវជនគណបក្សគណបក្សថ្នាក់កណ្តាល និងជាប្រធានក្រុមការងាររៀបចំអង្គការចាត់តាំងយុវជននៅទ្វីបអឺរ៉ុប ព្រមទាំងប្រធានក្រុមការងារតាមបណ្តាប្រទេសផ្សេងៗ និងសមាជិកសមាជិកា សរុប ៩៦ រូប បានទៅបំពេញបេសកកម្មចាប់ ពីថ្ងៃទី២០ ខែកញ្ញា ដល់ថ្ងៃទី០២ ខែតុលា ឆ្នាំ២០១៧ នៅទ្វីបអឺរ៉ុប ក្រុមការងារបាន៖

- ពិធីប្រកាសបញ្ចូលសមាជិកគណបក្សនៅតំបន់មេឌីទែរ៉ាណេ,ប្រទេសអង់គ្លេស, ប្រទេសអាល្លឺម៉ង់, ប្រទេស ហូឡង់
- ប្រកាសទទួលស្គាល់ក្រុមការងារយុវជនគណបក្សប្រជាជនកម្ពុជានៅទីក្រុងទូលូស សាធារណរដ្ឋបារាំង, ប្រទេសអាល្លឺម៉ង់, ប្រទេសហូឡង់ និងប្រកាសទទួលស្គាល់សាខាយុវជនប្រចាំប្រទេស ឆែក
- ជួបផ្ទាល់ជាមួយបងប្អូនខ្មែរ និងពិសាអាហារសាមគ្គីមហាគ្រួសារខ្មែរនៅអាល្លឺម៉ង់ ស្វីស អង់គ្លេស បែលហ្ស៊ិក និងសាធារណៈរដ្ឋបារាំង ។
- បានចូលជួបសម្តែងការគួរសមនិងពិភាក្សាការងារជាមួយ ឯកឧត្តម Michel Herbillon សមាជិកសភា អនុប្រធានគណកម្មការកិច្ចការអន្តរជាតិ និងជាប្រធានក្រុមមិត្តភាពកម្ពុជា-បារាំង របស់រដ្ឋសភាបារាំង។ លោក តាន់ ប៊ុន ហួង (Buon Huong TAN ) តំណាងរាស្ត្រ បារាំង ដើមកំណើតខ្មែរ នៅទីក្រុង ប៉ារីស ប្រទេសបារាំង (០១-១០-២០១៧)៕



*ថ្ងៃទី០៤ ខែតុលា ឆ្នាំ២០១៧ នៅមន្ទីរគណបក្សរាជធានី បានប្រារព្ធពិធីបិទវគ្គអប់រំនយោបាយជំនាន់ទី២១ ក្រោមអធិបតីភាព ឯកឧត្តម **ប៉ា សុជាតិវង្ស** ប្រធានគណបក្សរាជធានីភ្នំពេញ និងជាប្រធានក្រុមការងារយុវជនគណបក្សរាជធានីភ្នំពេញ ដោយមានសិក្ខាកាម ចូលរួមចំនួន ៦៩ នាក់ដើម្បីក្លាយជា យុវជនបន្តវេន ប្រកបដោយគុណភាព និងប្រសិទ្ធភាពខ្ពស់ មានសុជីវធម៌ សីលធម៌ គុណធម៌ និងបុព្វហេតុស្នេហាជាតិ ព្រមទាំង បូរណភាពទឹកដី យុវជនត្រូវការរៀនសូត្រ ដុសខាត់ សំលៀង និងការអនុវត្តសមត្ថភាព ដែលទាំងអស់នេះជារឿងសំខាន់ណាស់ក្នុងនាមជាសមាជិកគណបក្សប្រជាជនកម្ពុជា ៕*

# សកម្មភាពរបស់ក្រុមការងារយុវជនគណបក្ស



ថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០១៧ នាស្នាក់ការគណបក្សក្រុងប៉ោយប៉ែត ឯកឧត្តម **សួន បវរ** សមាជិកក្រុមការងារយុវជនគណបក្សថ្នាក់កណ្តាល និងជាប្រធានគណៈកម្មាធិការគណបក្សខេត្តបន្ទាយមានជ័យ បានអញ្ជើញជាអធិបតីក្នុងពិធីប្រកាសក្រុមការងារចុះជួយ ភូមិ សង្កាត់ និងក្រុងប៉ោយប៉ែត។ ឯកឧត្តមបានស្នើឲ្យក្រុមការងារទាំងអស់ ខិតខំដោះស្រាយសំណូមពររបស់ប្រជាពលរដ្ឋ និងចុះដល់មូលដ្ឋានឲ្យបាន ញឹកញាប់ ។



*ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០១៧ ឯកឧត្តម **តុន សារពៅជ្រ** សមាជិកក្រុមការងារយុវជនថ្នាក់កណ្តាល និងជាប្រធានក្រុមការងារយុវជនគណបក្សខេត្តកំពត ឯកឧត្តម **នៃ គង់** សមាជិកគណៈអចិន្ត្រៃយ៍គណៈកម្មាធិការគណបក្សខេត្ត អភិបាលរងនៃគណៈអភិបាលខេត្តកំពត និងជាអនុប្រធានក្រុមការងារយុវជនគណបក្សខេត្តកំពត លោកជំទាវ **យ៉យ នីតា** អនុរដ្ឋលេខាធិការក្រសួងកិច្ចការនារី និងជាអនុប្រធានក្រុមការងារយុវជនគណបក្សខេត្ត និងក្រុមការងារយុវជនគណបក្សខេត្តកំពត បានជួបសំណេះសំណាលជាមួយក្រុមការងារយុវជនគណបក្សក្រុង ក្នុងនោះមាន ៥សង្កាត់ និងភូមិ១៥ ដើម្បីត្រួតពិនិត្យកំលាំង រចនាសម្ព័ន្ធយុវជន ត្រៀមបណ្តុះបណ្តាលយុវជន ពង្រឹងយុវជនអោយមានភាពក្លាហាន ហ៊ានតស៊ូមតិ សំរាប់ការបោះឆ្នោតនាពេលខាងមុខ។*



ថ្ងៃទី១១ ខែតុលា ឆ្នាំ២០១៧ ឯកឧត្តម **យស ផានីត្តា** សមាជិកក្រុមការងារយុវជនថ្នាក់កណ្តាល និងក្រុមគ្រូឧទ្ទេសរបស់ក្រុមការងារយុវជនគណបក្សថ្នាក់កណ្តាល បានចូលរួមធ្វើបទបង្ហាញស្តីពីកម្ពុជាអតីតកាល បច្ចុប្បន្ន និងអនាគត ដោយឯកឧត្តម **ហ៊ាង ស៊ីណេ** អនុរដ្ឋលេខាធិការក្រសួងអប់រំយុវជន និងកីឡា ជូនដល់សមាជិក សមាជិកា ក្រុមប្រឹក្សាយុវជនកម្ពុជាមកពី២៥ រាជធានី-ខេត្ត នៅខេត្តសៀមរាប ក្នុងកម្មវិធី ទស្សនកិច្ចសិក្សាយុវជន២០១៧ ។



*ថ្ងៃទី០៧ ខែតុលា ឆ្នាំ២០១៧ ឯកឧត្តម **ហេង សុខណា** ប្រធានក្រុមការងារយុវជនខេត្តស្វាយរៀង និងក្រុមការងារ បានជួបសំណេះសំណាល ជាមួយ ឪពុក ម្តាយ សិស្ស និងសិស្ស ប្រលងជាប់ បាក់ឌុប និទ្ទេស B.C.D.E ចំនួយ២៩រូប។ ក្នុងនោះ ក្រុមការងារបានឧបត្ថម្ភ សម្ភារៈ សិក្សា, ថវិកា និងបានអាហាររូបករណ៏មួយចំនួនផងដែរ។*



រសៀលថ្ងៃទី១៤ ខែតុលា ឆ្នាំ២០១៧ ឯកឧត្តម **ខួន រាសី** សមាជិកក្រុមការងារយុវជនថ្នាក់កណ្តាល បានរៀបចំពិធីសំណេះសំណាលជាមួយក្រុមការងារសមាជិកគណបក្ស និងប្រគល់សម្ភារៈដែលបានស្នើសុំ ជូនភូមិពីរដែលមានការខ្វះខាតឧបករណ៍ប្រើប្រាស់ និងផ្តល់ប្រាក់ឧបត្ថម្ភដល់សមាជិកបក្ស ហើយនៅពេលបញ្ចប់កម្មវិធីមានអាហារសាមគ្គីផងដែរ។



*ពលរដ្ឋខ្មែររស់នៅខេត្ត British Columbia និងខេត្ត Alberta ប្រទេសកាណាដា បានរៃអង្គាសថវិកាបាន៤.៥០០ដុល្លារ ដើម្បីឧបត្ថម្ភដល់មន្ទីរពេទ្យគន្ធបុប្ផា ហើយនៅព្រឹកថ្ងៃទី០៧ ខែតុលា ឆ្នាំ២០១៧ នេះ ក្រុមការងាររៀបចំការអង្គការចាត់តាំងយុវជនគណបក្សប្រចាំនៅប្រទេសកាណាដា ក៏បាននាំយកថវិកាដែលបានមកពីការរៃអង្គាសប្រគល់ជូនថ្នាក់ដឹកនាំមន្ទីរពេទ្យ ដោយឯកឧត្តម **ឱុយ រី** ឯកអគ្គរាជទូតនៃកម្ពុជា ប្រចាំនៅអង្គការសហប្រជាជាតិ និងប្រចាំប្រទេសកាណាដា ។*

# សមិទ្ធផលសំខាន់ៗមួយចំនួននៃវិស័យសេដ្ឋកិច្ច

### ចំណូលពន្ធដារខែកញ្ញានិងរយៈពេល ៩ខែ

- អគ្គនាយកដ្ឋានពន្ធដារនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបានប្រកាសឲ្យដឹងថា ក្នុងខែកញ្ញា កន្លងទៅនេះ ប្រមូលចំណូលពន្ធ-អាករបានចំនួន ៥២៩,៩២ពាន់លានរៀល ឬប្រមាណ១៣២,៤៨លានដុល្លារអាមេរិក។ សម្រាប់រយៈពេល ៩ខែឆ្នាំ២០១៧ ចំណូលពន្ធអាករ ដែលប្រមូលបានសរុបមានចំនួន ៦.១៨៦,២០ ពាន់លានរៀលឬប្រមាណ១.៥៤៦,៥៥លានដុល្លារស្មើនឹង៩០,១៥% នៃផែនការ។

តួលេខខាងលើប្រសិនបើធៀបរយៈពេលដូចគ្នានៃឆ្នាំ២០១៦ ឃើញថាការប្រមូលចំណូលពន្ធ-អាករសម្រាប់រយៈពេល ៩ខែឆ្នាំនេះកើនឡើងចំនួន ១.៤២១ ពាន់លានរៀលឬប្រមាណ៣៥៥,២៩លានដុល្លារស្មើនឹងអត្រាកំណើន ២៩,៨២%។

### ការនាំចេញអង្ករ

- ក្នុងរយៈពេល៩ខែ ដើមឆ្នាំនេះ កម្ពុជាបាននាំចេញអង្ករចំនួន ៤២១.៩០០តោន កើនឡើង ១៦,៧% ធៀបនឹងរយៈពេលដូចគ្នាឆ្នាំមុន ។ ក្នុងនោះការនាំចេញទៅប្រទេសចិនមានចំនួន ១២៤.៧០០តោន ប្រទេសបារាំងមាន ៥៣.៩០០តោន ប្រទេសប៉ូឡូញ ៣៥.៤០០តោន ។

### ការនាំចេញកៅស៊ូ

- រយៈពេល៩ខែ ឆ្នាំ២០១៧ កម្ពុជាប្រមូលផលជ័រកៅស៊ូបានចំនួន ១១៥.៨៤៣ តោន ក្នុងនោះបាននាំចេញជ័រកៅស៊ូចំនួន ១១៤.៩៩១តោន ដោយទទួលបានទឹកប្រាក់ចំនួន ១៩២.២៦៤.៩៥២ដុល្លារ ដែលតម្លៃជាមធ្យម ១.៦៨២ដុល្លារ ក្នុងមួយតោន ។ ផ្ទៃដីកៅស៊ូរបស់កម្ពុជាសរុបមានចំនួន ៤៣២.០៩៦ហិកតា ក្នុងនោះ ផ្ទៃដីចៀរជ័រមានចំនួន ១៦៣.១៣០ហិកតា ស្មើនឹង ៣៧,៧៧% និងផ្ទៃដីថែទាំមានចំនួន ២៦៨.៩៦៦ហិកតា ស្មើនឹង ៦២,២៣% ។ នៅឆ្នាំ២០១៦កន្លងទៅ កម្ពុជានាំចេញជ័រកៅស៊ូបានជាង ១៤ម៉ឺនតោន ទទួលបានទឹកប្រាក់ជាង ១៨០លានដុល្លារ ។

### ការនាំចេញវិស័យជលផល

- រយៈពេល ៨ខែឆ្នាំ២០១៧ កម្ពុជាបាននាំចេញផល នេសាទ ៩ ៩០០តោន កើនបាន ១០០តោន បើប្រៀបធៀបនិងរយៈពេលដូចគ្នាឆ្នាំមុន ការនាំចេញផលនេសាទស្រស់មាន ចំនួន ៦ ៣៥០ តោន ស្មើនឹង ៤២,៣៣% នៃផែនការ ចំណែកផលនេសាទកែច្នៃមានចំនួន ៣ ៥៥០ តោនស្មើនឹង ៧១% នៃផែនការ ចំពោះការនេសាទសមុទ្រទទួលបាន ៧ ៦២២៥តោន និងការចិញ្ចឹមត្រីក្តាម បង្កៀរ ទទួលបាន ១ ៣៦៨៦៣តោន ចំណូលបានពីការនាំចេញ មានចំនួន ១ ៣៣៤លានរៀល ស្មើនឹង ៤៤,៤៩% នៃផែនការ ។

### គម្រោងដែលក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុអនុម័តក្នុងរយៈពេល៧ឆ្នាំចុងក្រោយ

ក្នុងរយៈពេល ៧ឆ្នាំចុងក្រោយនេះ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានផ្តល់អាជ្ញាប័ណ្ណ វិនិយោគក្នុងវិស័យសំណង់ចំនួន ២១៣ គម្រោង ក្នុងនោះបុរីចំនួន ១៣២គម្រោង និងគម្រោងខុនដូ និងគម្រោងផ្សេងៗជាច្រើនទៀត ដែលមានទុនវិនិយោគសរុបចំនួន៣ ៣៧៥លានដុល្លារ អាមេរិក។ ក្នុងនេះវិស័យសំណង់បានរួមចំណែក ១ភាគ១០នៃផលទុនជាតិសរុប និងបានបង្កើតសកម្មភាពការងារជាច្រើន។

ចំណែកសមាគមអ្នកអភិវឌ្ឍន៍លំនៅដ្ឋានកម្ពុជា បានប្រកាសឲ្យដឹងកាលពីដើមខែតុលាដែរថា សមាគមមានសមាជិកចំនួនជាង ៤០ក្រុមហ៊ុនដែលជាក្រុមហ៊ុនវិនិយោគធំៗ។

យោងតាមទិន្នន័យរបស់ក្រសួង រៀបចំដែនដីនគរូបនីយកម្ម និងសំណង់បានឲ្យដឹងថា ទុនវិនិយោគក្នុងវិស័យសំណង់ក្នុងរយៈពេល ៧ខែឆ្នាំនេះ មានទំហំទឹកប្រាក់ជាង ៥ពាន់លានដុល្លារអាមេរិក។

### វិស័យមីក្រូហិរញ្ញវត្ថុ

យោងតាមការបញ្ជាក់ធនាគារជាតិនៃកម្ពុជា កាលពីដើមខែតុលាបានឲ្យដឹងថា គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុកម្ពុជាមានភាពរីកចម្រើនខ្លាំង។ គិតត្រឹមដំណាច់ខែសីហា ២០១៧ កន្លងទៅនេះ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុនៅកម្ពុជាមានចំនួន ៧៦ និងប្រតិបត្តិករឥណទានជនបទចំនួន២៨៦ មានបណ្តាញប្រតិបត្តិការនៅទូទាំងផ្ទៃប្រទេស និងមានរហូតដល់ថ្នាក់មូលដ្ឋានឃុំ។ ទំហំទឹកប្រាក់សរុបមានចំនួនប្រមាណ១៨,៨០ ទ្រីលានរៀល ប្រមាណ ៣,៩០ ប៊ីលានដុល្លារអាមេរិក, ១ប៊ីលានស្មើ នឹង១០០០លាន ផ្តល់ដល់អតិថិជនខ្ចីប្រាក់ ចំនួន ១,៨ លាននាក់ និងប្រាក់បញ្ញើសរុបមាន ៧,៧០ទ្រីលានរៀល (ប្រមាណ ១,៩០ប៊ីលានដុល្លារអាមេរិក) ទទួលបានពីអ្នកផ្ញើរប្រាក់ជាង ១,៧លាននាក់។



# វិស័យប្រេងកាតនឹងរួមចំណែកពន្លឿនកំណើនសេដ្ឋកិច្ចកម្ពុជា



ការចុះហត្ថលេខាលើកិច្ចព្រមព្រៀង សម្រាប់ការអភិវឌ្ឍប្រេងនៅប្លុក A កាលពី ថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១៧ កន្លងទៅនេះ រវាងរាជរដ្ឋាភិបាលកម្ពុជា តំណាងដោយឯកឧត្តមបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ទេសរដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងឯកឧត្តម **ស៊ុយ សែម** រដ្ឋមន្ត្រីក្រសួងរ៉ែ និងថាមពល ជាមួយក្រុមហ៊ុន Kris Energy តំណាងដោយលោក Kelvin Tang នាយកប្រតិបត្តិក្រុមហ៊ុន Kris Energy Group និងជាប្រធានក្រុមហ៊ុន KrisEnergy ( Cambodia ) គឺជាសក្ខីភាពថ្មីមួយទៀត ឆ្លុះបញ្ចាំងឲ្យឃើញនូវសមិទ្ធផលរបស់រាជរដ្ឋាភិបាលកម្ពុជា ក្រោមការដឹកនាំដោយ**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា។ គម្រោងប្រេងកាតប្លុក A នេះគឺជាគម្រោងប្រេងកាតទី១ ដែលបើកសករាជអោយកម្ពុជាក្លាយជាប្រទេសផលិតប្រេង និងឈានទៅធ្វើការរុករកដ៏ខ្លាំងក្លាថែមទៀត លើប្លុកប្រេងកាត ដែលនៅទំនេរ ចំនួន ៥ ប្លុកទៀត ក្នុងចំណោមប្លុកប្រេងកាតចំនួន ៦ នៅដែនសមុទ្រ និង ១៨ប្លុកនៅដែនគោក។

រាជរដ្ឋាភិបាលនឹងបង្កលក្ខណៈងាយស្រួលសព្វបែបយ៉ាង ក្នុងការចេញលិខិតបទដ្ឋានពាក់ព័ន្ធ នឹងគម្រោងវិនិយោគប្រេងកាតប្លុក A នេះតាមការព្រមព្រៀងដោយអនុលោមតាមច្បាប់ និងរបបលើកទឹកចិត្តជាធរមាន ដើម្បីធ្វើអោយគម្រោងវិនិយោគប្រេង និងឧស្ម័ន ក្នុងប្លុក A ទទួលបានជោគជ័យតាមការគ្រោងទុក។ ដូចគ្នានេះដែរ ភាគីក្រុមហ៊ុនក៏ត្រូវបំពេញកាតព្វកិច្ចពាក់ព័ន្ធនានាដូចមានចែងក្នុងកញ្ចប់កិច្ចព្រមព្រៀងប្រេងប្លុក A ។ ប្រតិបត្តិការដោយរលូន និង ជោគជ័យរបស់ក្រុមហ៊ុន Kris Energy ក្នុងដំណាក់កាលទី១ នៃប្លុក A នឹងបើកផ្លូវពន្លឿនសន្ទុះសម្រាប់ផែនការស្វែងរុករកវាយតម្លៃនិងអភិវឌ្ឍន៍ធនធានប្រេងកាតនៅដំណាក់កាលទី២ និង ទី ៣ នៅប្លុក A ទាំងមូល បន្តទៀត ក៏ដូចជាការចរចា និងរៀបចំកិច្ចព្រមព្រៀងទៅលើប្លុកផ្សេងទៀត ។ ជាមួយនឹងការចុះកិច្ចព្រមព្រៀងនេះ ក្រុមហ៊ុន KrisEnergy បានអះអាងថា នឹងធ្វើឲ្យប្រទេសកម្ពុជា ក្លាយជាប្រទេសផលិតប្រេងកាតដូចបំណង ហើយតំណក់ប្រេងកាត លើកដំបូងរបស់កម្ពុជា នឹងលេចរូបរាងឡើងជាផ្លូវការនៅដើមឆ្នាំ២០១៩ ពោលគឺមានរយៈពេល ២៤ខែទៀតគិតចាប់ពីពេលនេះទៅ។

កញ្ចប់កិច្ចព្រមព្រៀង សម្រាប់ការអភិវឌ្ឍន៍អណ្តូងប្រេងកាត់នៅប្លុក A ដែនសមុទ្រកម្ពុជា ដែល ទើបចុះហត្ថលេខានេះ រាជរដ្ឋាភិបាលកម្ពុជាអនុញ្ញាតឲ្យក្រុមហ៊ុន KrisEnergy ធ្វើផលិតកម្មលើកទី១របស់ខ្លួន គឺជំហាន 1A និង 1B នៃដំណាក់កាលទី១ នៃប្លុក A ដែលមានផ្ទៃ ក្រឡា១៩៨គីឡូម៉ែត្រការ៉េ នៃប្លុក A ទាំងមូលទំហំ ៣.០៨៣គីឡូម៉ែត្រការ៉េ ស្ថិតនៅក្នុងអាងសមុទ្រកម្ពុជា ក្នុងតំបន់ឈូងសមុទ្រថៃ ដែលមានជម្រៅទឹកចន្លោះពី៥០ ម៉ែត្រ ទៅ ៨០ម៉ែត្រ។

តាមការប៉ាន់ស្មានបរិមាណ ធនធានប្រេងកាត ដែលក្រុមហ៊ុន KrisEnergy ធ្វើ ប្រតិបត្តិការដំណាក់កាលដំបូង 1A និង 1B អាចមានលើសពី ៣០លានបារ៉ែល ដែលមាន រយៈពេលផលិត ៩ឆ្នាំ និងអាចធ្វើឲ្យមានលទ្ធភាពពាណិជ្ជកម្មគ្រប់គ្រាន់ ដើម្បីជំរុញឲ្យកម្ពុជាក្លាយជាប្រទេសផលិតប្រេងឆៅមួយ នៅពេលអនាគត។ លោក Kelvin Tang នាយកប្រតិបត្តិក្រុមហ៊ុន KrisEnergy បានថ្លែងបញ្ជាក់ថា អណ្តូង ប្រេង អប្សរា នឹងក្លាយជាអណ្តូងប្រេងដែលផ្តល់តំណក់ប្រេងទី១ នៅកម្ពុជា។ ក្រុមហ៊ុន KrisEnergy អះអាងថា បន្ទាប់ពីចុះហត្ថលេខានេះ យើងនឹងប្រកាសសេចក្តីសម្រេចចុងក្រោយលើការវិនិយោគហើយនឹងបន្ត ដើម្បីឲ្យសម្រេចបាននូវតំណក់ប្រេងដំបូង គឺក្នុងឆ្នាំ២០១៩ ។

ឯកឧត្តមទេសរដ្ឋមន្ត្រី **អូន ព័ន្ធមុនីរ័ត្ន** រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានថ្លែងថា ចំណូលដែលនឹងទទួលបានពីវិស័យប្រេងកាតនេះ នឹងរួមចំណែកជំរុញដល់ការអភិវឌ្ឍសង្គមសេដ្ឋកិច្ច ដោយផ្តោតលើវិស័យអាទិភាពចម្បង៤ គឺ ផ្លូវ ទឹក ភ្លើង និងមនុស្ស។ ឯកឧត្តម **អូន ព័ន្ធមុនីរ័ត្ន** បានថ្លែងថា «កម្ពុជាមានទិសដៅច្បាស់លាស់ គឺមិនបណ្តោយខ្លួនឲ្យក្លាយជាប្រទេសដែលពឹងផ្អែកលើចំណូលប្រេង និងឧស្ម័នជាចរន្តដង្ហើមស្លាប់រស់នៃសេដ្ឋកិច្ចទេ ប៉ុន្តែនឹងប្រើប្រាស់ចំណូលនេះរួមចំណែកក្នុងការកែទម្រង់រចនាសម្ព័ន្ធសេដ្ឋកិច្ច ដើម្បីធានាចីរភាព កំណើនក្នុងរយៈពេលមធ្យម និងវែង»។

ឯកឧត្តម **ម៉េង សក្តិធារ៉ា** រដ្ឋលេខាធិការក្រសួងរ៉ែ និងថាម-ពល បានថ្លែងថា នៅក្នុងប្លុក A មានអនុតំបន់ ឬអណ្តូងប្រេងកាតចំនួន ៧កន្លែងទៀត ប៉ុន្តែគម្រោងដំបូង គឺចាប់ផ្តើមនៅអណ្តូងមួយឈ្មោះថា អប្សរា មុនគេសិន។ ក្រោយពេលក្រុមហ៊ុនបូមប្រេងឆៅនោះបានហើយ គេនឹងនាំចេញទៅលក់ក្នុងទីផ្សារអន្តរជាតិ។ ឯកឧត្តម **ម៉េង សក្តិធារ៉ា** បន្តថា បច្ចុប្បន្នកម្ពុជាមិនទាន់មានលទ្ធភាព ចម្រាញ់ប្រេងឆៅ ដោយខ្លួនឯងបានទេ ប៉ុន្តែមានក្រុមហ៊ុនចិនមួយបាន និងកំពុងសាងសង់រោងចក្រចម្រាញ់ប្រេងកាតនៅកម្ពុជាដែរ ប្រហែលជានៅឆ្នាំ២០២០ ទើបបញ្ចប់ដំណើរការសាងសង់។ ដល់ពេលនោះ រាជរដ្ឋាភិបាលកម្ពុជា នឹងគិតគូរបន្តទៀត ព្រោះរោងចក្រនេះ មិនមែនចម្រាញ់តែប្រេង ដែលបូមក្នុងស្រុកទេ គោលដៅរបស់គេ គឺនាំប្រេងឆៅពីក្រៅស្រុក មកចម្រាញ់ជាផលិតផលសម្រេងចុងក្រោយនៅកម្ពុជា។ ក្រោយពេលកម្ពុជា

មានសមត្ថភាពចម្រាញ់ប្រេងបាន ហើយ កម្ពុជានឹងមិនចាំបាច់នាំចូលប្រេងពីខាងក្រៅ១០០% ទៀតទេ។ ពេលនោះកម្ពុជា នឹងរក្សាបានសន្តិសុខ ថាមពលដោយខ្លួនឯង។

រោងចក្រចម្រាញ់ប្រេងកាត ដែលគ្រោងចំណាយថវិកាសម្រាប់ការសាងសង់ ក្នុងដំណាក់កាលទី១ មានរហូតទៅដល់ ៦២០ លានដុល្លារ មានសមត្ថភាពផលិតបាន ២លានតោន ក្នុងមួយឆ្នាំ បានបើកការដ្ឋានសាងសង់កាលពីថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០១៧ ស្ថិតនៅក្នុងភូមិសាស្រ្តភូមិព្រៃកទាល់ ឃុំទឹកថ្លា ស្រុកព្រៃនប់ ខេត្តព្រះសីហនុ ។ យោងតាមរបាយការណ៍របស់ក្រសួងរ៉ែ និង ថាមពល បានឲ្យដឹងថា ការងារសាងសង់រោងចក្រចម្រាញ់ប្រេងកាតធំមួយនេះ ត្រូវបានប្រគល់ជូនក្រុមហ៊ុនចិនដើម្បីអនុវត្ត មានឈ្មោះថា «SINO GREAT WALL INTERNATIONAL ENGINEERING Co,.Ltd។ ក្រោយក្រុមហ៊ុនផលិតបានថាមពល មិនត្រឹមតែផ្គត់ផ្គង់សម្រាប់ទីផ្សារក្នុងស្រុកនោះទេ ប៉ុន្តែនឹងត្រូវលក់ផ្គត់ផ្គង់ សម្រាប់ទីផ្សារអន្តរជាតិទៀតផង ដែលផលិតផលចេញពីរោងចក្រនេះមាន ប្រេងសាំង ប្រេងម៉ាស៊ូត និងហ្គាស ។ របាយការណ៍របស់ក្រសួងបានបង្ហាញទៀតថា ដំណើរការសាងសង់រោងចក្រក្នុងដំណាក់កាលទី១ នឹងបញ្ចប់នាពាក់កណ្តាលឆ្នាំ២០១៩ ហើយដំណាក់កាលទី២ នឹងចាប់ផ្តើមសាងសង់នៅឆ្នាំ២០២២ ជាមួយទុនវិនិយោគ ១ពាន់លានដុល្លារ មានសមត្ថភាពផលិតបាន ៣លានតោនក្នុងមួយឆ្នាំ សម្រាប់ផ្គត់ផ្គង់ទីផ្សារក្នុងស្រុក និង អន្តរជាតិ។

បើយោងតាមលទ្ធផលនៃការសិក្សា ដែលបង្ហាញដោយក្រសួងរ៉ែបានបញ្ជាក់ថា នៅឆ្នាំ ២០១៥ កម្ពុជាបានប្រើប្រាស់ប្រេងឥន្ធនៈ ១,៨លានតោន កើនឡើង ៦.៧% បើប្រៀបធៀប នឹងឆ្នាំ២០១៤ ក្នុងនោះប្រេងម៉ាស៊ូតកើន ៨,៣% ប្រេងសាំងកើន ៥,៦% និងឧស្ម័នឥន្ធនៈកើន ៦% ដែលឆ្លុះបញ្ចាំងឲ្យឃើញថា តម្រូវការប្រើប្រាស់ប្រេងឥន្ធនៈ នឹងបន្តកើនឡើងនៅឆ្នាំ បន្ទាប់ទៀត ជាមួយនឹងកំណើនសេដ្ឋកិច្ចរបស់ប្រទេសកម្ពុជា ។ របាយការណ៍ដដែលនេះក៏បានបញ្ជាក់ផងដែរថា បច្ចុប្បន្នកម្ពុជានាំចូលប្រេង និងឧស្ម័នឥន្ធនៈពីបរទេស ១០០% តាមរយៈក្រុមហ៊ុនក្នុងស្រុក និងអន្តរជាតិ ចំនួន១៤ ដើម្បីលក់ និង ចែកចាយទូទាំងប្រទេស។

គួរបញ្ជាក់ថា នៅប្រទេសកម្ពុជាបានរកឃើញ តំបន់មានប្រេងកាតនៅបាតសមុទ្ររបស់ខ្លួន ចំនួន៦ កន្លែង និងមួយកន្លែងទៀតស្ថិតនៅលើតំបន់ត្រួតស៊ីគ្នាជាមួយប្រទេសថៃ។ តំបន់ចំនួន៦កន្លែងរបស់ប្រទេសកម្ពុជា ត្រូវបានបែងចែកជាតំបន់ ឬប្លុក A, B, C, D, E, និងF ។ កន្លងមក រាជរដ្ឋាភិបាលកម្ពុជាបានអនុញ្ញាតឲ្យក្រុមហ៊ុនសហរដ្ឋអាមេរិកមួយឈ្មោះ Chevron Oversea Petroleum (Cambodia) Ltd. ធ្វើការរុករកប្រេង និងឧស្ម័ននៅក្នុងតំបន់A ក្នុងដែនសមុទ្រកម្ពុជា។ ក្រុមហ៊ុនរបស់អាមេរិកមួយនេះបានប្រទះឃើញមានរណ្តៅប្រេង ដែលដាក់ឈ្មោះផ្សេងៗគ្នាដូចជា៖ រណ្តៅទី១ មានឈ្មោះថា ពិស្ណុការត្រូវបាន រកឃើញនៅខែតុលា ឆ្នាំ២០០៤ មានជម្រៅ ១១.៨៧៤ ហ្វីតស្មើនឹងជាង ៣.៦១៩ ម៉ែត្រ រណ្តៅទី២ ឈ្មោះថា សុវណ្ណភូមិ រក ឃើញនៅខែវិច្ឆិកា ឆ្នាំ២០០៤ មានជម្រៅ១២.២៣២ ហ្វីតស្មើនឹង ជាង ៣.៧២៨ ម៉ែត្រ រណ្តៅទី៣ ឈ្មោះ សេរីសម្បត្តិ រកឃើញនៅខែធ្នូ ឆ្នាំ២០០៤ មានជម្រៅ១១.៧១២ហ្វីត ស្មើ នឹងជាង ៣.៥៦៩ម៉ែត្រ និងរណ្តៅទី៤ ឈ្មោះថា វិមានអាកាសរកឃើញនៅខែធ្នូ ឆ្នាំ២០០៤ មានជម្រៅ១១.៦៦០ ហ្វីត ស្មើនឹងជាង ៣.៥៥៣ម៉ែត្រ។

តាមរបាយការណ៍ ពីអគ្គនាយកដ្ឋានប្រេងកាត បានឲ្យដឹងថា ក្នុងរយៈពេលកន្លងមក និងបច្ចុប្បន្នមានក្រុមហ៊ុនជាច្រើន កំពុងធ្វើប្រតិបត្តិការរុករកប្រេង និងឧស្ម័នក្នុងដែនទឹក និងដែនគោកនៃប្រទេសកម្ពុជា ដែលមានដូចជា៖ ទី១. ក្រុមហ៊ុន Chevron របស់សហរដ្ឋអាមេរិក បានចំណាយថវិកាសរុបចំនួន ១៨០ លានដុល្លារអាមេរិក សម្រាប់ប្រតិបត្តិការរុករកប្រេងនៅប្លុក A ហើយចុងក្រោយបានលក់ទៅឲ្យក្រុមហ៊ុន Kris Energy ទី២. ក្រុមហ៊ុនចម្រុះមានក្រុមហ៊ុន PTTEPI និងដៃគូពីរទៀត គឺក្រុមហ៊ុន RPL និងក្រុមហ៊ុន SPC បានចំណាយទុន ៥០ លាន ដុល្លារអាមេរិក សម្រាប់ប្រតិបត្តិការរុករកនៅប្លុក B ទី៣. ក្រុមហ៊ុន Polytec Petroleum (Cambodia) Corporation របស់ប្រទេសចិនធ្វើប្រតិបត្តិការរុករកនៅប្លុកC ទី៤. ក្រុមហ៊ុន CPHL(Cambodia) Company Ltd ធ្វើប្រតិបត្តិការរុករកនៅប្លុកD ទី៥. ក្រុមហ៊ុន MED-CO International PetroleumLtd របស់ប្រទេសឥណ្ឌូណេស៊ីធ្វើប្រតិបត្តិការរុករកនៅប្លុក E ទី៦. ក្រុមហ៊ុន CNOOC របស់ចិនធ្វើប្រតិបត្តិការរុករកនៅប្លុក F ដោយប្រើទុនអស់ប្រហែល ៣០ លានដុល្លារ អាមេរិក ទី៧ .ក្រុមហ៊ុន Medco Cambodia Tonle Sap Co., Ltd របស់ឥណ្ឌូណេស៊ី ធ្វើប្រតិបត្តិការរុករកនៅប្លុក១២ ដែលជាប្លុកនៅលើដែនគោក ទី៨. ក្រុម ហ៊ុន PVEP OVERSEAS របស់វៀតណាមធ្វើប្រតិបត្តិការរុករកនៅប្លុក១៥ ដែលជាប្លុកនៅលើដែនគោក និងទី៩. ក្រុមហ៊ុន JOG-MEC ធ្វើប្រតិបត្តិការរុករកនៅប្លុក១៧ ដែលជាប្លុកនៅលើដែនគោក ។

ឯកឧត្តម **ស៊ុយ សែម** រដ្ឋមន្រ្តីក្រសួងរ៉ែ និងថាមពល ថ្លែងថា ស្របតាមគោលនយោបាយកំណែទម្រង់ស៊ីជម្រៅរបស់រាជរដ្ឋាភិបាល សម្រាប់អាណត្តិឆ្នាំ ២០១៣-២០១៨នេះ ក្រសួងរ៉ែ និងថាមពល មានបេសកកម្មយ៉ាងធំធេង ក្នុងការបង្កើតសមិទ្ធផលថ្មីៗថែមទៀត ក្នុងវិស័យ សេដ្ឋកិច្ច និងអភិវឌ្ឍសង្គម តាមរយៈការជំរុញប្រើប្រាស់ឲ្យអស់លទ្ធភាពសក្តានុពលរបស់វិស័យឧស្សាហកម្មនិស្សារណកម្ម ដូចជា ការធ្វើអាជីវកម្ម ផលិតកម្មរ៉ែ ប្រេងកាត និងឧស្ម័ន ការពួតផ្តុំកម្លាំងគ្នារវាងវិស័យថាមពល រ៉ែ ប្រេងកាត និងឧស្ម័ន ព្រមទាំងការអភិវឌ្ឍវិស័យអគ្គិសនីជនបទ ការជំរុញពិពិធកម្មប្រភពថាមពល និងការពង្រីកវិសាលភាពគ្របដណ្តប់នៃសេវាផ្គត់ផ្គង់អគ្គិសនី មានថ្លៃសមរម្យឲ្យបានដល់ប្រជាជនយើងទាំងអស់គ្នា៕



# បង្កើនកិច្ចគាំពារបរិស្ថាន គ្រប់គ្រងធនធានធម្មជាតិ និងការអភិវឌ្ឍដោយចីរភាព



*ឯកឧត្តម **សាយ សំអាល់** រដ្ឋមន្ត្រីក្រសួងបរិស្ថាន អញ្ជើញចុះពិនិត្យរមណីយដ្ឋានព្រះមុនីវង្សបូកគោ*



*ទេសភាពនៃធម្មជាតិដ៏ស្រស់បំព្រងក្នុងតំបន់អភិរក្សព្រៃឈើធម្មជាតិ ក្នុងខេត្តមណ្ឌលគិរី*

ក្នុងរយៈពេលកន្លងមកនេះ ក្រសួងបរិស្ថានបានខិតខំយ៉ាងខ្លាំងក្នុងការកែសម្រួលរចនាសម្ព័ន្ធ គ្រប់គ្រងកសាងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត កសាង និងអភិវឌ្ឍធនធានមនុស្ស ជំរុញការលើកកម្ពស់ការយល់ដឹងជា សាធារណៈអំពីបរិស្ថាន និងធនធានធម្មជាតិ ពង្រឹងការអនុវត្តច្បាប់ អភិវឌ្ឍសហគមន៍មូលដ្ឋាន រៀបចំយុទ្ធសាស្ត្រ និងផែនការសកម្មភាពបរិស្ថានជាតិ និងរៀបចំ «ក្រមបរិស្ថាន និងធនធានធម្មជាតិ» ។ ក្រោមការដឹកនាំរបស់រាជរដ្ឋាភិបាលកម្ពុជា ដែលមាន**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ជាប្រមុខ ក្រសួងបរិស្ថាន បានកំណត់យក «ការធ្វើទំនើបកម្មស្ថាប័ន និងកំណែទម្រង់វិស័យបរិស្ថាន» ជាគោលដៅយុទ្ធសាស្ត្រសម្រាប់ធានា និរន្តរភាព និងប្រសិទ្ធភាពការងាររបស់ក្រសួងក្នុងក្របខណ្ឌនៃកិច្ចគាំពារបរិស្ថាន ការអភិរក្សជីវៈចម្រុះ ការគ្រប់គ្រងធនធានធម្មជាតិ និងការអភិវឌ្ឍដោយចីរភាព ។

អាស្រ័យដោយកិច្ចប្រឹងប្រែងនេះ ក្រសួងបរិស្ថានបានរៀបចំឲ្យមានវេទិកាថ្នាក់ជាតិស្ដីពី «ការការពារ និងអភិរក្សធនធានធម្មជាតិ» ក្នុងមួយឆ្នាំម្ដងក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់**សម្ដេចតេជោ ហ៊ុន សែន** និងវេទិកាពិគ្រោះយោបល់ស្ដីពី «**ការការពារ និងអភិរក្សធនធានធម្មជាតិ**» ក្នុងមួយឆ្នាំ ៣ដង ដឹកនាំដោយក្រសួងបរិស្ថាន ដើម្បីពិនិត្យពិភាក្សាការងារ និងដោះស្រាយបញ្ហារួមគ្នាពាក់ព័ន្ធនឹងវិស័យបរិស្ថាន និងធនធានធម្មជាតិ ។ ក្រសួងបានបង្កើតតំបន់ការពារធម្មជាតិថ្មីចំនួន ២៣កន្លែង (១៣កន្លែង ផ្ទេរពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ) បន្ថែមទៀត និងរបៀងអភិរក្សជីវៈចម្រុះឧត្តរ និងរបៀងអភិរក្សជីវៈចម្រុះជួរភ្នំក្រវាញ ដែលធ្វើឲ្យប្រព័ន្ធតំបន់ការពារធម្មជាតិកើនឡើងដល់ចំនួន ៤៩ កន្លែង គ្របដណ្ដប់លើផ្ទៃដីសរុបប្រមាណ ៧,៥លានហិកតា ស្មើនឹង ៤១% នៃផ្ទៃដីប្រទេសកម្ពុជា ។ ជាមួយគ្នានេះ ក្រសួងបរិស្ថានបានរៀបចំ និងអនុវត្តគម្រោងរេដបូកជាមួយអង្គការដៃគូរួមមាន អង្គការសមាគមអភិរក្សសត្វព្រៃ (WCS) នៅដែនជម្រកសត្វព្រៃ «កែវសីមា» អង្គការអភិរក្សអន្តរជាតិ (CI) នៅដែនជម្រកសត្វព្រៃ «ព្រៃឡង់» និងអង្គការសម្ព័ន្ធសត្វព្រៃ (WA) នៅឧទ្យានជាតិជួរភ្នំក្រវាញខាងត្បូង និងដែនជម្រក សត្វព្រៃតាតៃ ដើម្បីកៀរគរធនធានថវិកា និងបច្ចេកទេសសម្រាប់ពង្រឹងការការពារ និងអភិរក្សធនធានធម្មជាតិ និងលើកស្ទួយជីវភាពសហគមន៍មូលដ្ឋាន ។ ក្រសួង ក៏បាននិងកំពុងសិក្សាសក្ដានុពលបេតិកភ័ណ្ឌធម្មជាតិ និងទេសចរណ៍ធម្មជាតិសំខាន់ៗ ដើម្បីរៀបចំបង្កើត តំបន់បេតិកភ័ណ្ឌធម្មជាតិ និងរបៀងទេសចរណ៍ធម្មជាតិក្នុងទិសដៅជំរុញការអភិវឌ្ឍទេសចរណ៍ធម្មជាតិបន្ថែមទៀត សំដៅបង្កើនចំណូល ជូនសហគមន៍មូលដ្ឋាន និងថវិកាជាតិក៏ដូចជារួមចំណែកដល់ការការពារ និងអភិរក្សធនធានធម្មជាតិ ។ ជាមួយគ្នានេះក៏បានធ្វើការកំណត់តំបន់គ្រប់គ្រងក្នុងតំបន់ការពារធម្មជាតិរួមមាន «តំបន់ស្នូល តំបន់អភិរក្ស តំបន់ប្រើប្រាស់ដោយចីរភាព និងតំបន់សហគមន៍» បោះបង្គោលកំណត់ព្រំតំបន់ការពារធម្មជាតិ រៀបចំផែនការគ្រប់គ្រងតំបន់ការពារធម្មជាតិ ទប់ស្កាត់បទល្មើសធនធានធម្មជាតិ ដោះស្រាយទំនាស់ដីធ្លី សហការចុះបញ្ជីដីធ្លី និងរៀបចំផែនទីសម្រាប់ការគ្រប់គ្រង និងប្រើប្រាស់ដីធ្លីដូចជា ដីលំនៅដ្ឋាន ដីសមូហភាព ជនជាតិដើមភាគតិច សម្បទានដីសេដ្ឋកិច្ច សម្បទានដីសង្គមកិច្ច និងតំបន់ការពារធម្មជាតិថ្មីៗបន្ថែមទៀត ។ ជោគជ័យគួរឲ្យកត់សម្គាល់មួយទៀតនោះគឺ ក្រសួងបរិស្ថានបានត្រួតពិនិត្យវាយតម្លៃ គម្រោងវិនិយោគអភិវឌ្ឍន៍សម្បទាន ដីសេដ្ឋកិច្ចដោយបាននិរាករណ៍គម្រោងវិនិយោគអភិវឌ្ឍន៍ចំនួន ២៧គម្រោង បានកាត់បន្ថយរយៈពេលជួលពី ៩៩ឆ្នាំ ឬ ៧០ឆ្នាំ មកនៅត្រឹម ៥០ឆ្នាំ ។ ផ្ទេរគម្រោងវិនិ យោគអភិវឌ្ឍន៍សម្បទានដីសេដ្ឋកិច្ច ដំណាំកសិឧស្សាហកម្មចំនួន ៧៣កន្លែងទៅឲ្យក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។ ចំណែកតំបន់

ព្រៃការពារ តំបន់អភិរក្សព្រៃឈើ និងព្រៃផ្ដល់ផលចំនួន ១៨ កន្លែង ត្រូវបានផ្ទេរមកក្រសួងបរិស្ថានគ្រប់គ្រងវិញ ។ បង្កើតសហគមន៍តំបន់ការពារធម្មជាតិសរុបចំនួន ១៥០សហគមន៍ ដែលមានប្រជាជនសរុបចំនួន ៣២.០២៨គ្រួសារ រស់នៅក្នុងភូមិ ២៤៣ ភូមិលើផ្ទៃដី ១៩៣ពាន់ហិកតា និងបានលើកកម្ពស់ជីវភាពសហគមន៍ តាមរយៈការបង្កើតជម្រើសមុខរបរថ្មីក្នុងវិស័យកសិកម្ម និងចិញ្ចឹមសត្វ ការកែច្នៃផល និងអនុផលព្រៃឈើ និងទេសចរណ៍ធម្មជាតិ ដើម្បីកាត់បន្ថយការពឹងអាស្រ័យទាំងស្រុងលើធនធានធម្មជាតិ ។ ត្រួតពិនិត្យ និងវាយតម្លៃគម្រោងវិនិយោគអភិវឌ្ឍន៍ទេសចរណ៍ធម្មជាតិជាប្រចាំ ដើម្បីបង្កើនប្រសិទ្ធភាពនៃការអនុវត្តគម្រោង ក៏ដូចជាការកាត់បន្ថយទំនាស់ដីធ្លី ។ ជាក់ស្ដែងការចុះបញ្ជីដីរដ្ឋសម្រាប់គម្រោងវិនិយោគអភិវឌ្ឍន៍ទេសចរណ៍ធម្មជាតិចំនួន៦ត្រូវបានបញ្ចប់ និងគម្រោង៩ទៀតកំពុងដំណើរការ ។ ធ្វើបច្ចុប្បន្នភាពផែនទីតំបន់ការពារធម្មជាតិទូទាំងប្រទេស ក្នុងនោះបានបញ្ចូលផែនទីតំបន់ការពារធម្មជាតិថ្មីចំនួន៨តំបន់ និងរៀបចំឡើងវិញផែនទីតំបន់ការពារធម្មជាតិចំនួន ១៣តំបន់ ដែលបានផ្ទេរពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងកសាងផែនទីរបៀង អភិរក្សជីវៈចម្រុះ ។

នៅក្នុងវេទិកាជាតិលើកទី២ ស្ដីពី «ការការពារ និងអភិរក្សធនធានធម្មជាតិកាលពីពេលកន្លងទៅនេះ **សម្ដេចតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានកោតសរសើរដល់ក្រសួង បរិស្ថាន ក្រសួងស្ថាប័នពាក់ព័ន្ធប្រជាជនតំណាងសហគមន៍ ព្រះសង្ឃ និងអង្គការដៃគូអន្តរជាតិទាំង អស់ដែលបាន ចូលរួមយ៉ាងសកម្មក្នុងការថែរក្សាការពារ និងអភិរក្សធនធានធម្មជាតិ ។ សម្ដេចតេជោបានថ្លែងថា ការការពារ និងអភិរក្សធនធានធម្មជាតិ និងគាំពារដល់ទេសចរណ៍ គឺកម្ពុជាកំណត់ថា ជាទេសចរណ៍វប្បធម៌ដែលចូលរួមចំណែកបង្កើនចំណូល និងមុខរបរប្រជាជនឲ្យកាន់តែប្រសើរ ។ ការរីកចម្រើននេះ ស្របជាមួយកម្ពុជាមាន សុខសន្តិភាព និងមានការអភិវឌ្ឍសេដ្ឋកិច្ចខ្ពស់ផងដែរ ។ **សម្ដេចតេជោ ហ៊ុន សែន** ក៏បានជំរុញឲ្យអាជ្ញាធរ ជាពិសេសរដ្ឋបាលថ្នាក់ក្រោមជាតិចាត់វិធានការឲ្យតឹងរឹងលើការកាប់ព្រៃឈើ ។

ឯកឧត្តម **សាយ សំអាល់** រដ្ឋមន្ត្រីក្រសួងបរិស្ថានបានឲ្យដឹងថា ដើម្បីពង្រឹងប្រសិទ្ធភាពការងារ ក្នុងសមត្ថកិច្ចរដ្ឋបាលការពារ និងអភិរក្សធម្មជាតិ ក្រសួងបរិស្ថានបានផ្ទេរមុខងារគ្រប់គ្រងតំបន់ការ ពារធម្មជាតិ និងសហគមន៍តំបន់ការពារធម្មជាតិទៅឲ្យរដ្ឋបាលថ្នាក់ក្រោមជាតិ ដែលមានមន្ទីរបរិស្ថានជាសេនាធិការ ។ គួរបញ្ជាក់ដែរថា តាមរយៈយុទ្ធនាការរបស់គណៈកម្មការជាតិ ដើម្បីទប់ស្កាត់ និងបង្ក្រាប បទល្មើសធនធានធម្មជាតិយើងឃើញថា បទល្មើសព្រៃឈើទ្រង់ទ្រាយធំនៅទូទាំងប្រទេសត្រូវបានលុប បំបាត់ចោលទាំងស្រុង ។ ដោយឡែកយោងតាមទិន្នន័យរបស់ក្រសួងបរិស្ថានបង្ហាញថា ក្នុងរយៈពេល២ឆ្នាំចុងក្រោយនេះ គឺឆ្នាំ២០១៤-២០១៦ អត្រានៃការបាត់បង់គម្របព្រៃឈើប្រចាំឆ្នាំបានធ្លាក់ចុះមក នៅកម្រិត ០,៣% ប៉ុណ្ណោះ ។ អត្រាថយចុះ នេះ គឺដោយសារតែប្រសិទ្ធភាពនៃការអនុវត្តកំណែទម្រង់ លើការការពារ និងគ្រប់គ្រងធនធានធម្មជាតិរបស់ រាជរដ្ឋាភិបាលកម្ពុជា ការដាំព្រៃឈើឡើងវិញនៅតំបន់រេចរឹលមួយចំនួនក៏ដូចជា ការចូលរួមពីសហគមន៍មូលដ្ឋានកម្លាំងប្រដាប់អាវុធ និងអជ្ញាធរមូលដ្ឋានក្នុង ការទប់ស្កាត់ និងបង្ក្រាបបទល្មើសព្រៃឈើ ។

ក្រសួងបរិស្ថាននឹងបន្តភារកិច្ច និងការទទួលខុសត្រូវរបស់ខ្លួន ក៏ដូចជាការសហការជាមួយស្ថាប័ន ដៃគូអភិវឌ្ឍន៍ ភាគីពាក់ព័ន្ធនានា ក្នុងកិច្ចគាំពារបរិស្ថាន ការគ្រប់គ្រងធនធានធម្មជាតិ អភិរក្សជីវៈចម្រុះ និងការអភិវឌ្ឍដោយចីរភាពដើម្បីនិរន្តរភាពបរិស្ថាន និងធនធានធម្មជាតិ ដើម្បីឆ្លើយតបទៅនឹងបញ្ហាប្រឈម ចំពោះមុខ និងតម្រូវការជាក់ស្ដែងក្នុងសង្គមជាតិទាំងពេលបច្ចុប្បន្ន និងតទៅអនាគត ។

ចំពោះទិសដៅទៅមុខទៀតក្រសួងបរិស្ថាននឹងខិតខំតាមដាន និងត្រួតពិនិត្យគុណភាពបរិស្ថាន ( ទឹក ដី និងខ្យល់ ) ដើម្បីជាមូលដ្ឋានក្នុងការវាយតម្លៃពីស្ថានភាពបំពុលបរិស្ថាន និងដាក់ចេញនូវវិធានបង្ការជាមុន ក្នុងគោលដៅធានាសុវត្ថិភាព សុខភាពសាធារណៈ និងគុណភាពបរិស្ថាន ។ ពង្រឹងការត្រួតពិនិត្យសំណល់គ្រោះថ្នាក់ និងការបំពុលគ្រប់ប្រភេទ ចេញពីរោងចក្រ នៅតាមតំបន់សេដ្ឋកិច្ចពិសេស និងតំបន់ឧស្សាហកម្ម សំដៅធានាគុណភាពបរិស្ថាន និងសុវត្ថិភាពប្រព័ន្ធអេកូឡូស៊ី ។ ជំរុញវាល់គម្រោងអភិវឌ្ឍន៍ទាំងឯកជន និងសាធារណៈឲ្យការសិក្សាវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម ដើម្បីកាត់បន្ថយហេតុប៉ះពាល់បរិស្ថាន និងសង្គមឲ្យនៅកម្រិត អប្បបរមា ។ ពង្រឹងការគ្រប់គ្រងតំបន់ការពារធម្មជាតិ និងរបៀងអភិរក្សជីវៈចម្រុះតាមរយៈការពង្រឹងការ អនុវត្តវិធានការច្បាប់ក្នុងការទប់ស្កាត់ និងបង្ក្រាបបទល្មើសធនធានធម្មជាតិ និងការរៀបចំផែនការគ្រប់គ្រងតំបន់ការពារធម្មជាតិ ព្រមទាំងជំរុញការចូលរួមរបស់អ្នកពាក់ព័ន្ធ ជាពិសេសសហគមន៍មូលដ្ឋាន សំដៅធានាប្រសិទ្ធភាពក្នុងការគ្រប់គ្រងធនធានធម្មជាតិ និងការអភិរក្សជីវៈចម្រុះ ។ ពង្រឹងសមត្ថភាពគ្រប់គ្រង និងលើកកម្ពស់ជីវភាពសហគមន៍មូលដ្ឋាន តាមរយៈការប្រើប្រាស់ធនធានធម្មជាតិប្រកបដោយនិរន្តរភាព ការអភិវឌ្ឍទេសចរណ៍ធម្មជាតិ និងការបង្កើត ជម្រើសមុខរបរសមស្រប ដើម្បីកាត់បន្ថយសម្ពាធទៅលើធនធានធម្មជាតិ ។ ជំរុញការចុះបញ្ជីតំបន់ការពារធម្មជាតិ និងសិក្សាស្ថានភាពសក្ដានុពលប្រព័ន្ធអេកូឡូស៊ី និងភាពចាំបាច់នៃមុខងារទីជម្រាល ដើម្បីរៀបចំបង្កើតតំបន់ការពារធម្មជាតិ និងសហគមន៍តំបន់ការពារធម្មជាតិថ្មីៗបន្ថែមទៀត ។ លើកកម្ពស់ការឆ្លើយតបទៅនឹងបញ្ហា នៃការប្រែប្រួលអាកាសធាតុ តាមរយៈការជំរុញការអនុវត្តផែនការសកម្មភាព ឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុនៅតាមវិស័យពាក់ព័ន្ធ ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ។ រៀបចំនឹងអនុវត្តកម្មវិធីអភិវឌ្ឍទីប្រជុំជនបៃតង ដើម្បីធានាការអភិវឌ្ឍទីក្រុងដោយនិរន្តរភាព ។ លើកកម្ពស់ការងារអប់រំ និងផ្សព្វផ្សាយព័ត៌មានបរិស្ថានសំដៅ «ប្រែក្លាយចំណេះដឹងបរិស្ថាន ឲ្យទៅជាការប្រតិបត្តិបរិស្ថាន» ដើម្បីពង្រឹងប្រសិទ្ធភាពគ្រប់គ្រងបរិស្ថាន និងធនធានធម្មជាតិក៏ដូចជាធានាការអភិវឌ្ឍដោយចីរភាព ៕

# ការរីកចម្រើនថ្មីនៅក្នុងវិស័យការងារបានផ្ដល់អត្ថប្រយោជន៍កាន់តែច្រើនដល់កម្មករ និយោជិត



*សម្ដេចតេជោ ហ៊ុន សែន អញ្ជើញចុះពិនិត្យផ្ទាល់ប្រព័ន្ធផលិតកម្មនៅតាមរោងចក្រ*

រាជរដ្ឋាភិបាលកម្ពុជានិតិកាលទី៥ នៃរដ្ឋសភា ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិត របស់**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ដែលបាន និងកំពុងរក្សាបាននូវសន្តិភាព ស្ថិរភាពនយោបាយនោះ បានធ្វើឲ្យសម្រេចជោគជ័យយ៉ាងធំធេង ក្នុងការបន្តជំរុញការអភិវឌ្ឍប្រទេសជាតិ ។ ក្នុងនោះវិស័យការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ ក៏ត្រូវបានយកចិត្តទុកដាក់យ៉ាងខ្លាំងក្នុងការរួមចំណែកលើកកម្ពស់កម្រិតជីវភាព កាត់បន្ថយភាពក្រីក្រ របស់ប្រជាពលរដ្ឋ និងជំរុញកំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព។

តាមរបាយការណ៍របស់ក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈបានឲ្យដឹងថា ក្នុងរយៈពេល ៤ឆ្នាំ គិតចាប់តាំងពី ឆ្នាំ២០១៤ ដល់ ២០១៧ នៅក្នុងការទាក់ទាញវិនិយោគ និងការបង្កើតមុខរបរ និងការងារបានបង្កើត ការងារថ្មីក្នុងស្រុកបានចំនួនប្រមាណ ៦០ មុឺននាក់ និងក្រៅប្រទេសបានចំនួនប្រមាណ ៣២មុឺននាក់ ដែលធ្វើឲ្យប្រជាជន ៩៩,៣%មានការងារធ្វើ និងអត្រាអត់ការងារធ្វើមានតែ០,៧%តែប៉ុណ្ណោះ។ សហគ្រាស គ្រឹះស្ថានក៏បានបន្តកើនឡើងជាលំដាប់។ ជាក់ស្ដែងគិតមកដល់ឆ្នាំ២០១៧ នេះ សហគ្រាសដែលបានចុះបញ្ជីនៅក្រសួងការងារនិង បណ្ដុះបណ្ដាលវិជ្ជាជីវៈ កើនដល់ចំនួន ១១ ១៦៨ គ្រឹះស្ថានមានកម្មករ និយោជិត ចំនួន ១ ១៨៧ ២២៧នាក់ (ស្រី ៨៣១ ១០៤នាក់) ក្នុងនោះ ឧស្សាហកម្មវាយនភណ្ឌកាត់ដេរ និងផលិតស្បែកជើងចំនួន ៧៤ មុឺននាក់ និងបានបង្កើតមុខរបរ និងការងារដល់ប្រជាជនប្រមាណ ៣,៦ លាន នាក់ ។ ក្រសួងបានបន្តពង្រីកកិច្ចសហប្រតិបត្តិការ វិស័យការងារ និងមុខរបរជាមួយប្រទេសនានា ដើម្បីបង្កើតឱកាសការងារជូនប្រជាជននៅក្រៅប្រទេសបានចំនួន ១,២លាននាក់ ក្នុងនោះមានប្រទេសថៃ កូរ៉េ ម៉ាឡេស៊ី ជប៉ុន និងប្រទេសដទៃទៀត ដែលមាន ចំណូលជាតិសរុបបានប្រមាណ ២ពាន់លានដុល្លារក្នុង ១ឆ្នាំព្រមទាំងបានទទួលនូវមុខជំនាញវិជ្ជាជីវៈ និងបានធ្វើសមាហរណកម្មពេលត្រឡប់មកមាតុភូមិវិញ។ ចំពោះប្រាក់ឈ្នួល និងលក្ខខណ្ឌការងារវិញ ក៏ត្រូវយកចិត្តទុកដាក់ដំឡើងប្រាក់ឈ្នួលអប្បបរមា និងអត្ថប្រយោជន៍ផ្សេងៗជារៀងរាល់ឆ្នាំចាប់តាំងពីឆ្នាំ២០១៣បានចំនួន៥លើកជូនកម្មករនិយោជិតផ្នែកវាយនភណ្ឌកាត់ដេរ និងផលិតស្បែកជើង ដោយកើនពី ៨០ ដុល្លារ ក្នុងឆ្នាំ២០១៣ ដល់១៧០ដុល្លារ ក្នុងឆ្នាំ២០១៨ ដោយបូករួមទាំងប្រាក់រង្វាន់ ប្រាក់អត្ថប្រយោជន៍ផ្សេងៗ និងប្រាក់អតីតភាព ធ្វើឲ្យកម្មករនិយោជិតម្នាក់ៗទទួលបានប្រាក់ឈ្នួល ចាប់ពី ១៨៧ ដុល្លារ ទៅ១៩៨ដុល្លារ។ យើងបានបង្កើតច្បាប់ស្ដីពីប្រាក់ឈ្នួលអប្បបរមា ដែលនឹងគ្របដណ្ដប់វិស័យផ្សេងទៀត ជាពិសេសវិស័យកម្មន្តសាល សំណង់ និងសណ្ឋាគារ, បាន ផ្ដល់ប្រាក់ ឈ្នួល ចំនួន១២០% នៃប្រាក់ឈ្នួលប្រចាំខែដល់កម្មការីនីដែលសម្រាល កូនរយៈពេល ៩០ ថ្ងៃ, បានដំឡើងកម្រិតអប្បបរមានៃប្រាក់បៀវត្សជាប់ពន្ធឲ្យឡើងដល់ ១លានរៀល និងលើកលែងពន្ធលើអត្ថប្រយោជន៍បន្ថែមចំនួន២០% លើសោហ៊ុយធ្វើដំណើរ កន្លែងស្នាក់នៅ ប្រាក់ថ្លៃបាយ វិភាគទានបេឡាជាតិរបបសន្តិសុខសង្គម ប្រាក់ឧបត្ថម្ភ ប្រាក់បំណាច់បញ្ចប់កិច្ចសន្យា ឬប្រាក់បំណាច់នៃការបញ្ឈប់លែងឲ្យធ្វើការ។បានពង្រឹងការរៀបចំសេវាថែទាំ សុខភាពកម្រិតបឋម បន្ទប់បំបៅកូន និងទារកដ្ឋាន ព្រមទាំងកន្លែងបរិភោគអាហារនៅតាមរោងចក្រ សហគ្រាស គ្រឹះស្ថាន ។ ឧបត្ថម្ភទុនដល់ម្ចាស់យានយន្តដឹកជញ្ជូនកម្មករនិយោជិត ដើម្បីគោរពទៅតាមបទដ្ឋានបច្ចេកទេសសុវត្ថិភាព ។ អនុញ្ញាតឲ្យកម្មករនិយោជិតជិះរថយន្តក្រុងរបស់រដ្ឋរយៈពេល ២ឆ្នាំនោះ ចាប់អនុវត្តពីថ្ងៃទី២០ ខែសីហា ឆ្នាំ២០១៧ ដល់ថ្ងៃទី២០ ខែសីហា ឆ្នាំ២០១៩។ តភ្ជាប់បណ្ដាញអគ្គិសនី និងទឹកស្អាត ដោយតម្លៃទាបជូនកម្មករនិយោជិត សិស្ស និស្សិត តាមផ្ទះជួល ។ កែទម្រង់ប្រព័ន្ធអធិការកិច្ច ការងារជាតិ ដើម្បីពង្រឹងការអនុវត្តច្បាប់ និងបទដ្ឋានការងារ ធានាសិទ្ធិ និង ផលប្រយោជន៍របស់កម្មករនិយោជិត និងនិយោជក ព្រមទាំងបានបង្កើតមជ្ឈមណ្ឌលទំនាក់ទំនងសាធារណៈតាមបណ្ដាញទូរស័ព្ទ ដោយឥតគិតថ្លៃ (Call Centre) តាមរយៈទូរស័ព្ទលេខ ១២៩៧ ផងដែរ ។

ចំណែកការអភិវឌ្ឍរបបសន្តិសុខសង្គមវិញ បានផ្ដល់របបសន្តិសុខសង្គមផ្នែកហានិភ័យ និងផ្នែកថែទាំសុខភាព ដោយនិយោជកបង់វិភាគទានជំនួសកម្មករនិយោជិត១០០% សម្រាប់កម្មករនិយោជិតផ្នែកឯកជនចំនួន ១ ១៦៦ ៧៣៦នាក់(ស្រីចំនួន ៨១៦ ២៨២) និងបានជួយសង្គ្រោះ ព្យាបាល និងផ្ដល់អត្ថប្រយោជន៍ផ្សេងៗ



*ឯកឧត្តម **អ៊ិត សំហេង** រដ្ឋមន្ត្រីក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ ជួបជាមួយពលករ ពលការិនី បម្រើការងារនៅប្រទេសថៃ*



*វិស័យកាត់ដេរកំពុងមានការរីកចម្រើនខ្លាំងក្នុងប្រទេសកម្ពុជា ដែលពោរពេញដោយសុខសន្តិភាព និងការអភិវឌ្ឍ*

ដោយមិនបាច់បង់ប្រាក់។ រៀបចំផ្ដល់សេវាពិនិត្យសុខភាព និង ព្យាបាលជំងឺដោយឥតគិតថ្លៃដល់កម្មករនិយោជិត ទាំងសេដ្ឋកិច្ចក្នុងប្រព័ន្ធ និងក្រៅប្រព័ន្ធនៅតាមមន្ទីរពេទ្យរដ្ឋ និងបានកសាងអគារបន្ថែមនៅតាមមណ្ឌល សុខភាព និងមន្ទីរពេទ្យបង្អែកដែលមានទីតាំងនៅក្បែរតំបន់រោងចក្រ។ បានដាក់ឲ្យដំណើរការរបបសន្តិសុខសង្គមផ្នែកហានិភ័យការងារសម្រាប់មន្ត្រីសាធារណៈ និងផ្នែកថែទាំសុខភាព សម្រាប់មន្ត្រីសាធារណៈអតីតមន្ត្រីរាជការ និងអតីតយុទ្ធជន និងបានសិក្សារៀបចំដាក់ឲ្យប្រើប្រាស់ដំណើរការរបបប្រាក់សោធនសម្រាប់វិស័យឯកជននៅឆ្នាំ២០១៩។

ឯកឧត្តម **អ៊ិត សំហេង** រដ្ឋមន្ត្រីក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ បានលើកឡើងថា «នៅក្នុងវិស័យការងារនេះ កម្ពុជាក៏ប្រឈមនឹងបញ្ហាមួយចំនួន ដូចជា ការខ្វះខាតធនធានមនុស្សប្រកបដោយគុណភាព និងសមត្ថភាព ដើម្បីឆ្លើយតបទៅនឹងសេចក្ដីត្រូវការនៃការអភិវឌ្ឍសង្គម សេដ្ឋកិច្ច ដែលបញ្ហាទាំងអស់នោះ គឺជាឧបសគ្គសម្រាប់កម្ពុជា ក្នុងការទាក់ទាញវិនិយោគពីបរទេស ក៏ដូចជាការប្រកួតប្រជែងក្នុងវិស័យសេដ្ឋកិច្ចជាមួយប្រទេសក្នុងតំបន់» ។ ដើម្បីឆ្លើយតបទៅនឹងបញ្ហានេះ រាជរដ្ឋាភិបាលបានដាក់ចេញនូវគោលនយោបាយជាតិ ស្ដីពីមុខរបរ និងការងារ ឆ្នាំ២០១៥-២០២៥ និងគោលនយោបាយជាតិ ស្ដីពីការអប់រំបណ្ដុះបណ្ដាលបច្ចេកទេស និងវិជ្ជាជីវៈ ឆ្នាំ២០១៧-២០២៥ ដើម្បីកំណត់គោលដៅជំនាញកម្លាំងពលកម្មសម្រាប់យុវជន ដែលកំពុងសិក្សា ក៏ដូចជាសិស្សដែលបានបោះបង់ការសិក្សា ហើយមិនមានលទ្ធភាពបន្តការបណ្ដុះបណ្ដាលវិជ្ជាជីវៈផ្លូវការ និងដើម្បីកសាងកម្លាំង ពលកម្មដែលប្រកបដោយចំណេះដឹង សមត្ថភាព ជំនាញ ឥរិយាបថការងារ ក្រមសីលធម៌វិជ្ជាជីវៈ និងផលិតភាពការងារខ្ពស់ សម្រាប់ការប្រកួតប្រជែង និងការងារពេញមួយជីវិតសំដៅចូលរួមចំណែកលើកកម្ពស់ជីវភាពរស់នៅ និងសេចក្ដីថ្លៃថ្នូររបស់ប្រជាពលរដ្ឋក្នុងសង្គមក៏ដូចជាការកសាងខឿនសេដ្ឋកិច្ចកម្ពុជា នាពេលបច្ចុប្បន្ន និងអនាគត តាមរយៈគុណភាព និងសមត្ថិភាពនៃកម្លាំងពលកម្ម។

ដើម្បីអនុវត្តឲ្យបានជោគជ័យការងារទាំងអស់នេះ **សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ក៏បានផ្ដល់អនុសាសន៍សំខាន់ៗ ៥ចំណុច ដល់និយោជក និងនិយោជិតដើម្បីធ្វើការរួមគ្នាធានាដល់លក្ខខ័ណ្ឌការងារ និងប្រាក់ចំណូលល្អ។ អនុសាសន៍សំខាន់ៗទាំង ៥ចំណុច ដែលផ្ដល់ដោយសម្ដេចតេជោប្រមុខរាជរដ្ឋាភិបាលកម្ពុជា រួមមាន ១- ត្រូវរួមគ្នាថែរក្សាសន្តិភាព ស្ថិរភាព និងសុវត្ថិភាពសណ្ដាប់ធ្នាប់សង្គមឱ្យបានល្អ ២- រួមគ្នារក្សាការងារ និងបង្កើតការងារថ្មីៗច្រើនថែមទៀត ដោយធ្វើការពង្រីក និងបង្កើនទីផ្សារបន្ថែម៣- រួមគ្នាបង្កើនប្រាក់ចំណូល ដោយការបណ្ដុះបណ្ដាលចំណេះដឹងបន្ថែមដល់កម្មករ។ រាជរដ្ឋាភិបាល នឹងបន្តតម្លើងប្រាក់ខែកម្មករជារៀងរាល់ឆ្នាំ ៤- ផ្ដល់របបគាំពារសន្តិសុខ សង្គម ដល់កម្មករចាប់ពីខែ មករា ២០១៨នេះគឺនិយោជក (ម្ចាស់ក្រុមហ៊ុន) នឹងបង់ថ្លៃរបបសន្តិសុខសង្គម ១00% ដល់កម្មករ កម្មការនី រួមទាំងកម្មករ សំណង់ សណ្ឋាគារ ដឹកជញ្ជូនបើកបរ កសិកម្ម...។ល។ គឺទទួលបានការពិនិត្យព្យាបាលជំងឺ នៅមន្ទីរពេទ្យរដ្ឋដោយឥតគិតថ្លៃតាមរយៈមូលនិធិសមធម៌ និង៥- បន្តផ្ដល់កិច្ចគាំពារ និងយកចិត្តទុកដាក់ចំពោះកម្មករ កម្មការនី ដែលកំពុងធ្វើការនៅក្រៅប្រទេស ដោយធ្វើការសម្របសម្រួលជាមួយប្រទេសដៃគូ ដើម្បីផ្ដល់លក្ខ័ណការងារល្អៗ ព្រមទាំងជួយសម្រួលនូវលិខិតបទដ្ឋាននានាដែលពាក់ព័ន្ធនឹងការងាររបស់កម្មករ។

ទាំងអស់នេះ គឺជាលទ្ធផលផ្លែផ្កាដែលបានបង្ហាញឲ្យឃើញថា ការរីកចម្រើននៅក្នុងវិស័យការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ បាននិងកំពុងធ្វើឲ្យកម្មករ និយោជិតទទួលបាននូវអត្ថប្រយោជន៍កាន់តែច្រើនជាបន្តបន្ទាប់ និងបានរួមចំណែកយ៉ាងសំខាន់នៅក្នុងការអនុវត្តគោលនយោបាយកំណែទម្រង់ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិរបស់រាជរដ្ឋាភិបាល ឲ្យកាន់តែទទួលបានជោគជ័យថែមទៀត ៕

# ប្រទេស៤ នឹងក្លាយទៅជាសិង្ហបុរីទី២ នៅពេលខាងមុខ

លោក Reid Kirchenbauer ជានាយកស្ថាបនិកវេបសាយ InvestAsian ដែលមានជំនាញខាងសេដ្ឋកិច្ច និងការទិញលក់អចលនទ្រព្យបានធ្វើការវិភាគអំពីការវិវត្តខាងសេដ្ឋកិច្ចសង្គម និងនយោបាយ ហើយបានធ្វើការប៉ាន់ប្រមាណថា នៅពេលខាងមុខនេះមានប្រទេសចំនួន៤ នឹងក្លាយទៅ ជាប្រទេសសិង្ហបុរីទី២ ដែលក្នុងនោះក៏មានព្រះរាជាណាចក្រកម្ពុជាយើងផងដែរ ។

លោក Reid Kirchenbauer បានសរសេរថា ជារឿយៗសេដ្ឋកិច្ចនៃប្រទេសសិង្ហបុរី ត្រូវបានគេលើកយកធ្វើជាឧទាហរណ៍នៃគោលនយោបាយប្រកបដោយភាពអនុគ្រោះសម្រាប់វិនិយោគិនហើយដែលបានធ្វើឲ្យកំណើនសេដ្ឋកិច្ចនៃប្រទេសមួយនេះ ហក់ឈានឡើងខ្ពស់យ៉ាងឆាប់រហ័ស ។ យើងទាំងអស់គ្នាសុទ្ធតែបានដឹងហើយអំពីប្រទេសសិង្ហបុរី ដែលមានភាពក្រីក្របានផ្លាស់ប្តូរទៅជាប្រទេសមួយដែលមានបំផុតនៅលើភពផែនដីយើងនេះ ។ ការអភិវឌ្ឍដ៏លឿនគួរឲ្យភ្ញាក់ផ្អើលរបស់សិង្ហបុរី ក្នុងប៉ុន្មានទសវត្សរ៍កន្លងទៅនេះបានធ្វើឲ្យអ្នកវិនិយោគទាំងឡាយស្វះស្វែងរក«សិង្ហបុរីបន្ទាប់» ទៀត ។ ហេតុអ្វីក៏គេមិនបន្តធ្វើការវិនិយោគនៅក្នុងប្រទេសសិង្ហបុរីដដែលនេះ? ជាការពិតណាស់ឱកាសដែលបានមកដល់ហើយនោះវាក៏បានកន្លងហួសទៅ ។ គេលំបាកនឹងធ្វើការវិនិយោគនៅក្នុងប្រទេសមួយ ដែលមានការរីកចម្រើនដល់ដំបូលទៅហើយនោះណាស់ ។ ឥឡូវប្រទេសនេះមានលុយគ្រប់គ្រាន់ហើយ ហើយគេក៏មិនសូវត្រូវការលុយអ្នកទៀតទេ ។ ការលើកទឹកចិត្ត និងជម្រើសនានាសម្រាប់អ្នកវិនិយោគទាំងឡាយមានតិចតួចណាស់ បើទោះបីជាអ្នកនាំយកលុយរាប់លាន ដុល្លារទៅកាន់ ទីនោះក៏ដោយ ។ ជាមួយគ្នានេះ យើងក៏ត្រូវចោទសួរថា ហេតុអ្វីក៏ចាំបាច់ធ្វើការវិនិយោគនៅក្នុងប្រទេសមួយ ដែលបានឆ្លងកាត់ដំណាក់កាលអភិវឌ្ឍន៍ដ៏ធំធេង ហើយដែលវាមិនដូចកាលពី ២០ឆ្នាំមុននោះ? គ្រប់ៗគ្នាបានឃើញបញ្ហាទាំងអស់នេះ ហើយយើងកំពុងសម្លឹងទៅរកប្រទេសណាផ្សេងទៀត ដែលនឹងត្រូវក្លាយទៅជាសិង្ហបុរីបន្ទាប់ ។ ទីក្រុងហុងកុង និងប្រទេសអារ៉ាប់រួមអេមិរ៉ាតមិនត្រូវបានយកមកពិភាក្សានៅក្នុង អត្ថបទនេះទេ ពីព្រោះពួកគេបានទទួលជោគជ័យដូចជា សិង្ហបុរីរួចទៅហើយ ។

មុនពេលសម្លឹងទៅរកប្រទេសសិង្ហបុរី បន្ទាប់យើងត្រូវពិនិត្យមើលនូវលក្ខណៈសម្បត្តិ និងលក្ខខណ្ឌមួយចំនួន ដែលធ្វើឲ្យប្រទេសសិង្ហបុរីទទួលបានជោគជ័យធំធេងបែបនេះ ។ មានកត្តាសំខាន់ៗជាច្រើនដែលធ្វើឲ្យ មានប្រព័ន្ធរដ្ឋាភិបាលប្រកបដោយប្រសិទ្ធភាព ។ វាមិនចាំបាច់ទេនូវតម្រូវការខាងសេរីភាព ( សិង្ហបុរីជាប្រទេស ដែលស្ថិតនៅក្នុងលំដាប់ទាបខាងសេរីភាពនៃសារព័ត៌មាន ) ប៉ុន្តែត្រូវផ្តោតការយកចិត្តទុកដាក់ទៅលើកំណើន សេដ្ឋកិច្ច និងសុខមាលភាពប្រជាជន ។ សិង្ហបុរីមិនមែនជាប្រទេសដែលប្រកាន់យករបបប្រជាធិបតេយ្យពេញលេញនោះទេ ។ មានអ្នកខ្លះបានលើកជាយោបល់ថា ប្រទេសមួយនេះដែលមិនមានការប្រកួតប្រជែងខ្លាំងរវាងគណបក្សនយោបាយបានធ្វើឲ្យរដ្ឋាភិបាលរបស់ខ្លួន ងាយបត់បែន និងប្រកបដោយប្រសិទ្ធភាព ។ ហេតុនេះហើយសិង្ហបុរីបន្ទាប់ត្រូវតែស្វាហាប់ និងមានតម្លាភាព ឯបញ្ហាប្រជាធិបតេយ្យដូចជាមិនចាំបាច់ទេ ។ ឯបញ្ហាប្រឈមខ្លះទៀត គឺត្រូវពិនិត្យទៅលើទីតាំងជាយុទ្ធសាស្ត្ររបស់ប្រទេសនោះ ។ ប្រទេសមួយមិនអាចផ្លាស់ប្តូរទីតាំងរបស់ខ្លួននៅលើផែនដីនេះបានទេដូចជា ប្រទេសឡាវ និងម៉ុងហ្គោលី ដោយសារគ្មានភូមិសាស្ត្រជាប់ សមុទ្រទើបធ្វើឲ្យជួបការលំបាក ។

ប្រទេសសិង្ហបុរីមានទីតាំងជាប់ច្រកសមុទ្រម៉ាឡាកាជាផ្លូវនាវាដ៏មានសារៈសំខាន់ ។ ជាក់ស្តែងនាវា ដឹកប្រេងរបស់ចិនប្រមាណ ៨០% ត្រូវធ្វើដំណើរតាមច្រកនេះចេញមកពីមជ្ឈឹមបូព៌ា ។ អាស្រ័យដោយភូមិសាស្ត្របែបនេះ ធ្វើឲ្យកំពង់ផែប្រទេសសិង្ហបុរីក្លាយទៅជាកំពង់ផែដ៏មមាញឹកជាងគេលំដាប់ទី២ ក្នុងពិភពលោក ។ ប្រទេសសិង្ហបុរីបន្ទាប់ក៏ត្រូវតែមានគោលនយោបាយបើកចំហរ និងទាក់ទាញវិនិយោគិនបរទេសហើយប្រទេស មួយមិនអាចរីកចម្រើនលូតលាស់ជាមួយគោលនយោបាយគាំពារនិយមបានទេ ។

**ប្រទេស៤ ដែលនឹងក្លាយទៅជាសិង្ហបុរីបន្ទាប់គឺះ**

**១- ម៉ាឡេស៊ីះ** ម៉ាឡេស៊ីជាប្រទេសក្បែរខាងជាប់នឹងសិង្ហបុរីប៉ែកខាងជើង គឺជាប្រទេសមួយស្ថិតក្នុងជម្រើសដំបូងគេ ។ ប្រទេសទាំងពីរមានភាពស្រដៀងគ្នាខ្លាំងណាស់ ហើយកន្លងមកសិង្ហបុរីក៏ជាផ្នែកមួយនៃ ប្រទេសម៉ាឡេស៊ីរហូតមកដល់ឆ្នាំ១៩៦៥ ទើបផ្តាច់ខ្លួនចេញ ។ នៅក្នុងបរិបទនៃការអភិវឌ្ឍសេដ្ឋកិច្ច សិង្ហបុរី ដែលផ្តាច់ខ្លួនចេញពីម៉ាឡេស៊ី ក៏នៅតែបែងចែកនូវផលប្រយោជន៍ទាំងឡាយជាមួយគ្នាដែរ ។ ស្ថិតនៅលើទី តាំងភូមិសាស្ត្រអនុគ្រោះ ព្រំដែនទាំងអស់នៃប្រទេសម៉ាឡេស៊ី ស្ទើរតែហ៊ុំព័ទ្ធទាំងស្រុងដោយច្រកសមុទ្រម៉ាឡាកា ។ វាផ្តល់នូវសក្តានុពលដូចគ្នាទៅនឹងសិង្ហបុរីដែរ គឺម៉ាឡេស៊ី បានក្លាយជាមជ្ឈមណ្ឌលសម្រាប់នាវាចរណ៍ និងពាណិជ្ជកម្ម ។ ប្រទេសម៉ាឡេស៊ីក៏បង្ករភាពងាយស្រួលសម្រាប់វិនិយោគិនបរទេស ។ ជាប្រទេសមួយក្នុងចំណោមប្រទេសតិចតួចបំផុតនៅអាស៊ី ដែលជនបរទេសអាចទិញដីបាន ។ អ្វីដែលត្រូវដោះស្រាយ គឺការលប់បំបាត់អំពើពុករលួយ និងបង្កើនប្រសិទ្ធភាពដឹកនាំរបស់រដ្ឋាភិបាល ។ នៅមានបញ្ហាញ៉ាំញីខ្លះទៀត គឺប្រទេសនេះមានជនជាតិ និងសាសនាច្រើនចំរុះគ្នាបើធៀបទៅនឹងសិង្ហបុរី ។

ប្រទេសម៉ាឡេស៊ី ស្ថិតនៅភូមិភាគអាស៊ីអាគ្នេយ៍ ដោយមានព្រំប្រទល់ជាប់នឹងប្រទេសថៃ សឹង្ហបុរី និងប្រទេស ឥណ្ឌូនេស៊ី មានផ្ទៃដីសរុប ៣៣០.៨០៣គីឡូម៉ែត្រការ៉េ មានប្រជាជនសរុបចំនួន ៣១.៦១៨.០០០នាក់ (តួលេខឆ្នាំ២០១៧)។

**២- ព្រះរាជាណាចក្រកម្ពុជា:** កម្ពុជាជាប្រទេសមួយដែលក្រីក្រជាងគេនៅក្នុងអាស៊ី ។ ប្រទេសនេះស្ថិត នៅក្នុងចម្ងាយឆ្ងាយដើម្បីក្លាយទៅជាសឹង្ហបុរីបន្ទាប់ ។ ប៉ុន្តែកំណើនសេដ្ឋកិច្ចលឿនខ្ពស់ និងនយោបាយទាក់ទាញរស់រវើករបស់រាជរដ្ឋាភិបាល ចំពោះវិនិយោគិនបរទេស ពិតជាផ្តល់សារៈសំខាន់សម្រាប់ប្រជាជាតិមួយនេះ។ កំណើនសេដ្ឋកិច្ចកម្ពុជាត្រូវបានអ្នកវិភាគប៉ាន់ស្មានថា មានអត្រា ៧%ថេរតទៅមុខទៀត ។ ជាមួយគ្នានេះ ជនបរទេសទទួលបាននូវភាពងាយស្រួលក្នុងការប្រកបរបរជំនួញ និងការទិញលក់អចលនទ្រព្យ ។ មិនត្រឹមតែប៉ុណ្ណឹងទេ ប្រទេសចិនក៏ជាកម្លាំងជួយទ្រទ្រង់កំណើនសេដ្ឋកិច្ចរបស់កម្ពុជាដែរ។ប្រទេសទាំងពីរជាសម្ព័ន្ធមិត្តនឹងគ្នា។ប្រទេសចិនតែងតែបានជួយជាជំនួយហិរញ្ញវត្ថុសម្រាប់ការកសាងផ្លូវថ្នល់ ស្ពាន និងជំនួយដទៃទៀត ។ GDP របស់ចិនមានទំហំ ៥៦០ដង ធំជាង GDP កម្ពុជា ។ ប្រទេសកម្ពុជាមានច្រកចេញចូលទៅកាន់ សមុទ្រ និងមានផ្លូវសម្រាប់ធ្វើលំហូរពាណិជ្ជកម្ម ក៏ដូចជាការរីកចម្រើននៃវិស័យទេសចរណ៍ ដែលកំពុងមានសន្ទុះខ្លាំង ។ នៅមានបញ្ហាប្រឈមខ្លះ ប៉ុន្តែរាជរដ្ឋាភិបាលកម្ពុជាបានធ្វើឲ្យមានការរីកចម្រើនទៅមុខកាន់តែ ច្រើនណាស់ហើយក្នុងការដោះស្រាយបញ្ហាប្រឈមទាំងនេះ ។

ប្រទេសកម្ពុជាមានផ្ទៃដីសរុប ១៨១.០៣៥គីឡូម៉ែត្រការ៉េ មានប្រជាជនសរុប ១៥.៩៥៧.២២៣នាក់ គិតត្រឹមខែកក្កដា ឆ្នាំ២០១៦។

**៣- ហ្សកហ្ស៊ី:** សាធារណរដ្ឋហ្សកហ្ស៊ី គឺជាប្រទេសមួយនៅក្នុងតំបន់អាស៊ីខាងលិច មានព្រំប្រទល់ ជាប់នឹងប្រទេសរុស្ស៊ី និងតួកគី ប៉ុន្តែមិនមែនសហរដ្ឋអាមេរិកទេ។អ្នកខ្លះពិតជាមិនបានចាប់អារម្មណ៍ជាមួយ ហ្សកហ្ស៊ី ប៉ុន្តែប្រទេសដែលគេមិនចាប់អារម្មណ៍មួយនេះ កំពុងមានជាចំណុចខ្លាំងមួយហើយ ។ រដ្ឋាភិបាល ហ្សកហ្ស៊ីមានប្រសិទ្ធភាពការងារខ្ពស់ណាស់ រីឯធនាគារមានភាពងាយស្រួលក្នុងការធ្វើទំនាក់ទំនង ។ គេអាចធ្វើទំនាក់ទំនងការងារជាមួយធនាគារមិនដល់រយៈពេលមួយថ្ងៃផងអាចនឹងសម្រេច។វិនិយោគិនបរទេសដែលចង់ទិញអចលនទ្រព្យ ឬចាប់ផ្តើមបើកក្រុមហ៊ុនមិនចាំបាច់ប្រឈមនឹងលក្ខខណ្ឌលំបាកណាមួយទេ ។ ដោយសារតែភាពងាយស្រួលនេះហើយ ទើបធ្វើឲ្យវិស័យធនាគាររបស់ហ្សកហ្ស៊ីស្ថិតក្នុងលំដាប់ធនាគារដែល ងាយស្រួលទំនាក់ទំនងការងារជាងគេបំផុតក្នុងចំណោមធនាគារ ដែលងាយស្រួលដទៃទៀតនៅក្នុងពិភពលោក ដោយស្ថិតក្នុងលំដាប់ទី១៦ ក្នុងចំណោម១៩០ប្រទេស ។ កំពង់ផែដ៏ធំមួយ កំពុងស្ថិតក្នុងការសាងសង់ រួមជាមួយនឹងបំពង់បង្ហូរប្រេងជាច្រើនចេញពីប្រទេសតួកគី ឆ្លងកាត់ហ្សកហ្ស៊ីឆ្ពោះទៅកាន់បណ្តាប្រទេសអឺរ៉ុប បានរួមចំណែកយ៉ាងខ្លាំងក្នុងការជំរុញល្បឿនសេដ្ឋកិច្ចហ្សកហ្ស៊ី ។ ប៉ុន្តែប្រទេសនេះក៏កំពុងមានបញ្ហាប្រឈមដូចជា តំបន់ South Caucasus តាំងពីយូរយារណាស់មកហើយនៅតែមិនទាន់ស្ថិរភាព ។

ប្រទេសហ្សកហ្ស៊ី មានទីតាំងស្ថិតនៅតំបន់ Eurasia តាមបណ្តោយជួរភ្នំ South Caucasus នៅច្រកកណ្តាលនៃអាស៊ីប៉ែកខាងលិច និងអឺរ៉ុបប៉ែកខាងកើត និងស្ថិតនៅចន្លោះសមុទ្រខ្មៅ និងសមុទ្រ Caspian។ប្រទេសនេះមានផ្ទៃដី ៦៩.៧០០ គីឡូម៉ែត្រការ៉េ និងមានប្រជាជនសរុប ៣.៧២០.៤០០នាក់ (តួលេខឆ្នាំ២០១៦)។

**៤- ប៉ាណាម៉ា:** ភូមិសាស្ត្រដ៏ល្អអស្ចារ្យរបស់ប៉ាណាម៉ា គឺទីតាំងនៃប្រទេសនេះស្ថិតនៅភ្ជាប់រវាងឧបទ្វីប អាមេរិកទាំងពីរជាមួយគ្នា។ ប្រជាជាតិអាមេរិកកណ្តាលមួយនេះ មានភ័ព្វសំណាងខ្លាំងណាស់ ដោយសារតែកត្តាទីតាំងភូមិសាស្ត្រអំណោយផល ពិសេសគឺព្រែកជីករបស់ខ្លួន ។ ប្រសិនបើគ្មានព្រែកជីកប៉ាណាម៉ាទេ រាល់នាវាដឹកទំនិញធំៗ ទាំងអស់ត្រូវតែធ្វើដំណើរតាមផ្លូវវាង ទៅប៉ែកខាងលើនៃតំបន់អាមេរិកខាងត្បូង ដើម្បីទៅកាន់គោលដៅដទៃទៀត ។ ព្រែកជីកនេះ អាចជួយកាត់បន្ថយបានពេលវេលានៃការធ្វើនាវាចរណ៍ប្រមាណ២ អាទិត្យឯណោះ ហើយក៏អាចធ្វើឲ្យកាត់បន្ថយបានការខាតបង់ប្រាក់រាប់ពាន់លានដុល្លារក្នុងមួយឆ្នាំៗ ។ ប៉ាណា ម៉ាស្ថិតក្នុងទីតាំងមួយ នៃបញ្ជីឈ្មោះដែលសកម្មបំផុតក្នុងគោលដៅឆ្ពោះទៅកាន់ឋានៈជាសឹង្ហបុរីបន្ទាប់ ។ ប្រធានាធិបតីប៉ាណាម៉ា ២រូបរួចមកហើយបានធ្វើដំណើរទស្សនកិច្ចផ្លូវរដ្ឋទៅកាន់សឹង្ហបុរី ដើម្បីសិក្សារៀនសូត្រនូវ ជោគជ័យរបស់ប្រទេសនេះ ។ នៅពេលដែលប៉ាណាម៉ាស្ថិតក្នុងបែបផែនស្តង់ដារជាប្រទេសអាមេរិកឡាទីន ប៉ុន្តែបញ្ហាការិយាធិបតេយ្យនៅមានការលំបាកច្រើន បើធៀបទៅនឹងសឹង្ហបុរី ។ ការចាត់ចែងរបរជំនួញក៏ដូច ជាការទំនាក់ទំនងជាមួយរដ្ឋាភិបាលមានការលំបាកខ្លាំង ។ អត្រាពន្ធសាជីវកម្មមានរហូតដល់ទៅ២៥% គឺ ខ្ពស់ជាងបើធៀបទៅនឹងប្រទេសដទៃទៀតដែលត្រូវក្លាយជាសឹង្ហបុរីបន្ទាប់ ។ តើប៉ាណាម៉ាអាចប្រយុទ្ធនឹង អំពើពុករលួយ ការបញ្ចុះអត្រាពន្ធ ការបង្កើនប្រសិទ្ធភាពការងារ ការធ្វើឲ្យប្រសើរឡើងនូវកិត្តិស័ព្ទរបស់ធនាគារបានទេ? ដោះស្រាយបានបញ្ហាបានទាំងអស់នេះ ប្រទេសប៉ាណាម៉ានឹងទទួលបានជោគជ័យយ៉ាងពិតប្រាកដ។

ប្រទេសប៉ាណាម៉ា មាននាមជាផ្លូវការថា សាធារណៈរដ្ឋប៉ាណាម៉ា ស្ថិតនៅអាមេរិកកណ្តាល ខាងលិច ទល់នឹងប្រទេសកូស្តារីកាខាងកើតឈៀងខាងត្បូង ទល់នឹងប្រទេសកូឡុំប៊ី ខាងជើងទល់នឹងសមុទ្រខារីបៀន និងខាងត្បូងទល់មហាសមុទ្រប៉ាស៊ីហ្វិក ។ ប្រទេសនេះមានផ្ទៃដី ៧៥.៤១៧,៣គីឡូម៉ែត្រការ៉េ មានប្រជាជនចំនួន ៤.០៥៣.៣៧៤ (តួលេខខែវិច្ឆិកា ឆ្នាំ២០១៦)៕

(តាមឯកសារបរទេស)



# ប្រវត្តិសិល្បៈ អាយ៉ៃ



**អាយ៉ៃ** ជាទម្រង់សិល្បៈទស្សនីយភាពមួយប្រភេទ ដែលមានប្រជាប្រិយភាពយ៉ាងធំធេងនៅប្រទេសកម្ពុជា។ ទម្រង់សិល្បៈមួយនេះបានឈ្មោះមកពីសិល្បករ ដ៏ល្បីល្បាញម្នាក់ឈ្មោះពូយ៉ៃ។អាយ៉ៃជាទម្រង់សិល្បៈចម្រៀងឆ្លងឆ្លើយ ឬជាប្រភេទសិល្បៈ ច្រៀងដេញប្រាជ្ញាគ្នាដោយចោទសួរ និងឆ្លើយដោះប្រស្នានានាដោយសំនួនវោហាជាកំណាព្យកាព្យឃ្លោងឥតព្រាងទុកនោះឡើយ។ ការច្រៀង គេនិយមច្រៀងស្ត្រីនិងបុរសជាគូចោទឆ្លើយ និងមានលក្ខណៈបញ្ឆិតបញ្ឆៀងលែបខាយ បន្តុះបង្អាប់ ឬសរសើរបញ្ជោរគ្នាទៅវិញទៅមក និងរិះរកអត្ថន័យកំប្លុកកំប្លែងឲ្យបានផ្ទុះសំណើច ។

បើតាមការស្រាវជ្រាវលោកគ្រូ **ម៉េង ហ៊ុន** ដែលជាសាស្ត្រាចារ្យតន្ត្រីករប្រពៃណីដ៏ល្បីល្បាញនៃប្រទេសកម្ពុជា អតីតៈស្វាមីអ្នកនាង **សង្វា ពេជ្រ** អ្នកចម្រៀងអាយ៉ៃដ៏ឆ្នើមនាទ.វឆ្នាំ ៦០ លោកបានមានប្រសាសន៍ថា សិល្បៈអាយ៉ៃមានប្រភពកំណើតចេញពីចម្រៀងប្រប់កៃ គឺចម្រៀងឆ្លងឆ្លើយគ្នា ដែលមានប្រុសម្ខាង ស្រីម្ខាងឈរតម្រៀបគ្នាជាជួរទល់មុខគ្នា ទះដៃព្រមជាចង្វាក់បន្ទរអមជាមួយចម្រៀងតគ្នាទៅវិញទៅមក។ ជាពិសេសគេនិយមលេង ឬសម្ដែងនៅពេលបុណ្យចូលឆ្នាំប្រពៃណីខ្មែរ ។ ចំណោរកាលក្រោយមកចម្រៀងប្រប់កៃនេះ ត្រូវបានសម្រួលដោយគំនិតច្នៃប្រឌិតរបស់បុព្វបុរសសិល្បករខ្មែរ បានបំភ្លៃឲ្យក្លាយទៅជាចម្រៀងទោល ដែលឆ្លងឆ្លើយរវាងស្រីនិងប្រុស និងមានវង់តន្ត្រីភ្លេងការប្រគំជូនបន្ទាប់ពីអ្នកចម្រៀងច្រៀងចប់មួយឃ្លាៗ ដោយពុំមានទះដៃបន្ទរតាមទៀតឡើយ ។ ចំពោះឧបករណ៍តន្ត្រីដែលប្រគំកំដរនោះមាន៖ទ្រខ្សែបី (ទ្រខ្មែរ), ទ្រសោ, ទ្រអ៊ូ, ចាប៉ីដងវែង, តាខេ, ខ្លុយ, ស្គរដៃ, ក្រាប ។ល។

ថ្វីបើបានពង្រីកច្នៃប្រឌិតឲ្យមានវង់តន្ត្រីចូលប្រគំក៏ដោយ ក៏ប្រភេទសិល្បៈនេះនៅនិយមហៅថា ចម្រៀងប្រប់កៃ ឬសិល្បៈប្រប់កៃដដែលដោយ គ្រាន់តែបានកែលម្អបន្តិចម្ដងៗតែប៉ុណ្ណោះ ។ លុះរហូតមកដល់ចុងស.វ.ទី១៩ និងដើមស.វ.ទី២០ (១៨៧៨-១៩៥៨) ទើបមានសិល្បករឆ្នើមមួយរូបឈ្មោះយ៉ៃ (ពូយ៉ៃ) ដែលមានដើមកំណើត នៅភូមិឈើនាងខ្ពស់ ឃុំព្រះពុទ្ធនិព្វាន ស្រុកគងពិសី ខេត្តកំពង់ស្ពឺ ដែលជាសមាជិកម្នាក់ក្នុងក្រុម សម្ដែងសិល្បៈ នៃវង់ភ្លេងធំមួយ នៅភូមិត្រពាំងទា ឃុំពងទឹកស្រុកកណ្ដាលស្ទឹង ខេត្តកណ្ដាល ក៏បានធ្វើឲ្យមានព្រឹត្តិការណ៍ថ្មីសម្រាប់ ទម្រង់សិល្បៈនេះឡើង។ ដោយសារទេពកោសល្យ ប៉ិនប្រសប់របស់ពូយ៉ៃ ដែលជាអ្នកចម្រៀងយ៉ាងពូកែ ប្រាជ្ញាឆ្លាតវាងវៃ សម្លេងពិរោះ ប្រសប់ប្រើសំនួនវោហាឥតព្រាងទុក ចេះសម្ដែងរាំចាក់ត្លុក កំប្លុកកំប្លែងពិសេស ចេះទាំងក្បាច់គុណខ្មែរទៀតផង ក៏បានធ្វើឲ្យទស្សនិកជនទូទៅ ចាប់អារម្មណ៍ លើរូបគាត់យ៉ាងខ្លាំង និងល្បីល្បាញរន្ទឺគ្រប់ទិសទីរហូតមានពិធីបុណ្យទានម្ដងៗ ពួកអ្នកស្រុកតែងតម្រូវឲ្យក្រុមវង់ភ្លេងធំរបស់គាត់ទៅប្រគំ និងសម្ដែងសិល្បៈ ច្រៀងចោទឆ្លើយគ្នាជាបន្តបន្ទាប់។ តាំងពីនោះមក ក្រុមសិល្បៈនោះក៏មានប្រជាប្រិយភាពកាន់តែខ្លាំងឡើងៗ។ ចំពោះទស្សនិកជនផងទាំងឡាយ កាលបើមានកម្មវិធីបុណ្យទានដែលមានសិល្បៈនេះទៅសម្ដែងគេនាំគ្នានិយាយថា ទៅមើលពូយ៉ៃខ្លះទៅមើលតាយ៉ៃ ខ្លះទៀតដែលមានវ័យចំណាស់ក៏និយាយថា ទៅមើលអាយ៉ៃ ឬក៏ពោលប្រាប់កូនចៅថា យប់នេះអាយ៉ៃមកលេងបុណ្យចុងភូមិយើង។ តាំងពីពេលនោះរហូតមកទល់បច្ចុប្បន្ននេះ សិល្បៈមួយប្រភេទនេះ ក៏បានជាប់ឈ្មោះថា **អាយ៉ៃ** ដែលជាកេរដំណែលដូនតាខ្មែរសុទ្ធសាធ ។

មកដល់សព្វថ្ងៃនេះ អាយ៉ៃ នៅតែជាទម្រង់សិល្បៈប្រជាប្រិយមួយបែប ដែលជាទីពេញនិយមនៃសង្គមខ្មែរ ជាសិល្បៈមួយប្រភេទដែលមានលក្ខណៈចរិតសាមញ្ញស៊ីជំរៅទៅ នឹងស្រទាប់មហាជនជាងប្រភេទសិល្បៈដទៃ ។

សិល្បៈអាយ៉ៃ ត្រូវបានសិល្បៈករជំនាន់ក្រោយបំបែកកែច្នៃទាំងបទចម្រៀង និងបទភ្លេងឲ្យមានច្រើនបែប ដើម្បីប្ដូរអារម្មណ៍ដោយមិនច្រៀងតែមួយបែបដដែលនោះឡើយ ។ ឧទាហរណ៍៖ ផ្ដើមដំបូងគេច្រៀងបទ "នមសកា" ដើម្បីជាការគោរពរំលឹក គុណគ្រូបាអាចារ្យ ឬគុណមាតាបិតា។ បន្ទាប់មកទៀតគេច្រៀងបទ "បំពេក្លាយ" សម្រាប់ជាកិច្ចស្វាគមន៍ភ្ញៀវព្រៀងលៀន ដែលបានចូលរួមកំសាន្ត និងអញ្ជើញដៃគូចម្រៀងមកឆ្លងឆ្លើយ ។ បន្តមកទៀតគេច្រៀងបទ "កេនចាវ" សម្រាប់ជាការបន្តុះបង្អាប់លែបខាយដេញដោលគ្នាទៅវិញទៅមក ដើម្បីបានផ្ទុះសំណើច ។ ផុតពីវគ្គនេះគេប្ដូរទៅច្រៀងបទ "ឱលទ្បា" ដែលសម្រាប់ផ្ដើមសំណួរចោទ និងឆ្លើយអំពីផ្លូវលោកផ្លូវធម៌ ឬជាប្រស្នាផ្សេងៗ ។ ផុតពីវគ្គចោទឆ្លើយ និងបានបកស្រាយរួចហើយគឺជាវគ្គដែលគូឆ្លងឆ្លើយត្រូវលាគ្នា និងគោរពសន្តានញាតិ នោះគ តម្រូវប្ដូរមកច្រៀងបទ "ភំភួង" ឬ បទ "ការ៉េយាន់សា" ។

ទម្រង់សិល្បៈអាយ៉ៃ នេះសិល្បករជំនាន់ក្រោយលោកក៏បានកែច្នៃទៅជាពីរប្រភេទ គឺអាយ៉ៃឆ្លងឆ្លើយនិងអាយ៉ៃរឿង ។ ប្រភេទទីមួយ គឺអាយ៉ៃ ឆ្លងឆ្លើយ ជាទម្រង់ដូចដែលបានរៀបរាប់ខាងលើ។ ប្រភេទទីពីរ គឺអាយ៉ៃរឿង ជាទម្រង់សម្ដែងជាសាច់រឿងមានឈុតឆាកដូចទៅនឹងល្ខោនបាសាក់ ឬល្ខោនយីកេដូច្នោះដែរ គ្រាន់តែថា ខុសប្លែកត្រង់អាយ៉ៃរឿងពុំមានការតុបតែងលម្អឆាក ឬតែងតួស្លៀកពាក់មុខមាត់ឲ្យឆើតរលើបរលោងនោះឡើយ ។ គេត្រូវយកបទចម្រៀងឆ្លងឆ្លើយមកច្រៀង តាមឈុតឆាកនិមួយៗ ។ ម៉្យាងទៀតអ្វីដែលជាចំណុចសំខាន់នោះគឺ អាយ៉ៃរឿងគេ ច្រើនជ្រើសរើសតែរឿងបែបកំប្លុកកំប្លែងមកសម្ដែងឧទាហរណ៍ ដូចជារឿង ព្រេងនិទានខ្លីៗ រឿងអាឡេវ រឿងអាសុខស្លូត អាសុខកាច រឿងកុហកចាញ់អាត្មា រឿងគ្រូកាចសិស្សខូចរឿងតម្លង់៧ សន្តានជាដើម។

បច្ចុប្បន្ន ដោយការយកចិត្តដាក់ខ្ពស់របស់រាជរដ្ឋាភិបាលកម្ពុជាយើង សិល្បៈអាយ៉ៃត្រូវបានដាក់បញ្ចូលក្នុងកម្មវិធីសិក្សា ជាផ្លូវការនៅសកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ ក្រោមការគ្រប់គ្រងផ្ទាល់របស់មហាវិទ្យាល័យសិល្បៈ តូរ្យតន្ត្រី ៕



# ស្រុកឈូក ដែលផ្ដល់នូវភាពកក់ក្ដៅ និងក្ដីសង្ឃឹម



*វេទិកាសាធារណៈ ជួបសំណេះសំណាលស្វែងយល់ពីតម្រូវការរបស់ប្រជាជន ក្នុងឃុំល្បើក ស្រុកឈូក*



*ការស្ដាបនាផ្លូវ សម្រួលការធ្វើចរាចរណ៍ជូនប្រជាជននៅក្នុងស្រុកឈូក*

**ស្រុកឈូក** ស្ថិតនៅក្នុងទឹកដីនៃខេត្ត កំពត ។ ដោយសារលក្ខណៈពិសេសរបស់ស្រុកនេះ ទើបរៀងរាល់រដូវវស្សា ស្រុកឈូកគ្របដណ្ដប់ទៅដោយវាលស្រែ និងព្រៃព្រឹក្សាដ៏ខៀវស្រងាត់ គួរជាទីគយគន់យ៉ាងក្រៃលែង និងគួរឲ្យចង់ទៅកំសាន្ត និងស្នាក់នៅ ដើម្បីទទួលយកនូវសម្ភស្សដ៏ស្រស់ត្រកាលដែលកើតចេញពីធម្មជាតិពិតៗនេះ ។ ស្រុកឈូកស្ថិតនៅប៉ែកខាងកើតទីរួមខេត្ត កំពត ដែលមានព្រំប្រទល់ខាងជើង ទល់នឹងស្រុកជុំគីរី ខេត្តកំពត និង ស្រុកបសេដ្ឋ ខេត្តកំពង់ស្ពឺ ខាងត្បូងទល់នឹងស្រុកដងទង់ និងស្រុកបន្ទាយមាស ខេត្តកំពត ខាងលិចទល់នឹងស្រុក ទឹកឈូ ខេត្តកំពត និងស្រុកកំពង់សិលា ខេត្តព្រះសីហនុ ខាងកើតទល់នឹងស្រុកអង្គរជ័យ ខេត្តកំពត និងស្រុកត្រាំកក់ ខេត្តតាកែវ ។ ស្រុកឈូកចែកចេញជា ១៥ឃុំ មាន ៨០ភូមិ មានផ្ទៃដីសរុប ១.២៩៣គីឡូម៉ែត្រការ៉េ មានចំនួន គ្រួសារសរុប ២៧.៣៧៣គ្រួសារ មានប្រជាជនសរុប ១២០.១១៦នាក់ (ស្រី ៦១.៩៤៦នាក់) អាយុ ១៨ឆ្នាំឡើង មានចំនួន ៧៨.២៥៨នាក់ (ស្រី ៣៩.៣១៨នាក់) ។

លោក **ខៀវ រិទ្ធិភ័ណ្ឌ** ប្រធានគណៈកម្មាធិការគណបក្សស្រុក និងជាអភិបាលនៃគណៈអភិបាលស្រុក បាន មានប្រសាសន៍ថា ការងារសន្តិសុខសណ្ដាប់ធ្នាប់សង្គម គឺជាកិច្ចការដែលមានសារៈសំខាន់បំផុតព្រោះថា បើការងារ នេះធ្វើមិនបានល្អ មូលដ្ឋានភូមិឃុំជួបអសន្តិសុខពេលនោះសតិអារម្មណ៍ប្រជាជនក៏មិននឹងនដែរ ។ អ្វីដែលរឹតតែ ធ្វើឲ្យស្មុគស្មាញទៀតនោះគឺ ប្រជាជនបាត់ការជឿទុកចិត្តមកលើសមត្ថកិច្ចយើងតែម្ដង ។ ដូច្នេះយើងយកចិត្តទុកដាក់ខ្លាំងណាស់លើការងារនេះ ។ ដោយអនុវត្តន៍គោលនយោបាយភូមិ ឃុំមានសុវត្ថិភាព និងអាស្រ័យដោយការដឹក នាំណែនាំជាប់ជាប្រចាំរបស់គណៈអភិបាលខេត្ត ក៏ដូចជាក្រុមការងារចុះជួយស្រុក គណៈបញ្ជាការឯកភាពស្រុក បានខិតខំប្រើប្រាស់នូវវិធានការសរុប មធ្យោបាយសរុប កម្លាំងសរុប ដោយធ្វើយ៉ាងណាអនុវត្តន៍ឲ្យបានម៉ឺងម៉ាត់ គោលនយោបាយភូមិឃុំមានសុវត្ថិភាព ដោយលើកទឹកចិត្ត ឲ្យមានការចូលរួមគាំទ្រពីសំណាក់កម្លាំងមហាជន សំដៅរក្សាឲ្យបានសន្តិសុខសុវត្ថិភាព និងការរស់នៅប្រកបមុខរបរចិញ្ចឹមជីវិតរបស់បងប្អូន ប្រជាជនឲ្យមានលំនឹងទាំងផ្លូវកាយ ទាំងផ្លូវចិត្ត ។ ប្រសិនបើជីវភាពរស់នៅគ្មានលំនឹង និងគ្មានស្ថិរភាពទេនោះ ប្រជាជនយើងមួយចំនួនក៏ងាយ ធ្លាក់ចូលទៅក្នុងការញុះញង់ពីសំណាក់ជនឆ្លៀតឱកាសជាមិនខាន ។

ប្រជាជនទូទាំងស្រុកឈូក មានជីវភាពរស់នៅល្អប្រសើរ ហើយភាគច្រើនជាកសិករ ដោយមានចំនួនប្រមាណ ៩០% រស់នៅពឹងផ្អែកលើវិស័យកសិកម្ម ដែលជាវិស័យចំបងក្នុងការទ្រទ្រង់ជីវភាពរស់នៅ របស់បងប្អូន។ ស្រុកនេះមានផ្ទៃដីស្រែ ១៦.៦០០ ហិកតា ផ្ទៃដីចំការ ៤១៥ហិកតា និងផ្ទៃដីព្រៃ ៩៩.៩២៤ហិកតា ។ បច្ចុប្បន្ននេះ ប្រជាជនកំពុងសស្រាក់សស្រាំ បង្កបង្កើនផលស្រូវវស្សាយ៉ាងមមាញឹក ។ ចំណែកដំណាំរួមផ្សំផ្សេងៗបងប្អូនដាំបាន ១.២០០ហិកតា ដំណាំឧស្សាហកម្មរយៈពេលខ្លីដាំបាន ១៦៩ហិកតា និងដំណាំឧស្សាហកម្មរយៈពេលវែងដូចជា ដំណាំកៅស៊ូដាំបាន ៣៧៥ហិតា និងដំណាំម្រេចបាន ១២១ហិកតា ។ ចំពោះវិស័យអប់រំវិញក្នុងស្រុកឈូក ទាំងមូលមានវិទ្យាល័យចំនួន ៣ កន្លែង ចែកចេញជា ១៤អគារ ស្មើនឹង ៨២ បន្ទប់ មានគ្រូចំនួន ១៧៦នាក់ (ស្រី ៦០ នាក់) និងសិស្សចំនួន ៣.៨៧៤នាក់ (ស្រី ១.៩៣៨នាក់) មានអនុវិទ្យាល័យចំនួន ១២កន្លែង ចែកចេញជា ១៧ អគារ ស្មើនឹង ៧៦បន្ទប់ មានគ្រូ ១៧២នាក់ (ស្រី ៥៨នាក់) និងសិស្សចំនួន ៣.៦៥៥នាក់ (ស្រី ១.៨៥៣ នាក់) សាលាបឋមសិក្សាមានចំនួន ៥០កន្លែង ចែកចេញជា ១០៧អគារ ស្មើនឹង ៤០០បន្ទប់ មានគ្រូចំនួន ៤៤២នាក់ (ស្រី ១៧៣នាក់) និងសិស្សចំនួន ១៦.០៨៧នាក់ (ស្រី ៧.៧៤៦នាក់) និងមត្តេយ្យសិក្សាចំនួន ១ កន្លែង ស្មើនឹង ៥បន្ទប់ និងមានគ្រូចំនួន ៤នាក់ ។ ក្នុងចំណោមអគារសិក្សាទាំងអស់នោះ មានចំនួន ២៩ខ្នង ស្មើ នឹង ១៥១បន្ទប់ ជាអំណោយដ៏ថ្លៃថ្លារបស់**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** និង**សម្ដេចគតិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុន សែន** ។ ដោយឡែកក៏មានអគារសិក្សាខ្លះទៀតជាអំណោយ របស់ក្រុមការងារ និងសប្បុរសជន នានាដែលបានជួយរួមចំណែកយ៉ាងសំខាន់ ដល់ការអភិវឌ្ឍលើវិស័យអប់រំនៅស្រុកឈូក ។ គួររំឭកដែរថា ក្នុងឱកាសសម័យ ប្រឡងមធ្យមសិក្សាទុតិយភូមិ ឆ្នាំសិក្សា២០១៥-២០១៦កន្លងទៅ មាន

បេក្ខជនប្រឡងចំនួន ៤៨៣ នាក់ (ស្រី ២៤៣ នាក់) បានប្រឡងជាប់ ២៩៨នាក់ (ស្រី ១៦៣នាក់) ។ លោក ខៀវ រិទ្ធិភ័ណ្ឌ បានឲ្យដឹងថា ក្នុងសម័យប្រឡងមធ្យមសិក្សាទុតិយភូមិឆ្នាំសិក្សា២០១៦-២០១៧ នាពេលនេះ បានដំណើរការយ៉ាងល្អ ដោយបេក្ខជនទាំងអស់បានប្រុងប្រៀបខ្លួនជាមុន និងត្រៀមលក្ខណៈសម្បត្តិគ្រប់គ្រាន់ដើម្បីប្រឡង និងប្ដេជ្ញាយកឲ្យបាន ជាប់ក្នុងចំនួនច្រើនបំផុត ។ ប្រជាជននៅស្រុកឈូក ភាគច្រើនតែងយកចិត្តទុកដាក់ខ្លាំងណាស់ ក្នុងការបញ្ជូនកូនចៅឲ្យទៅរៀនសូត្រ ក្រេបជញ្ជក់យក ចំណេះដឹង ព្រោះនេះជាឱកាសល្អតែមួយគត់ ដែលប្រទេសយើងកំពុងមានសុខសន្តិភាព ពេញលេញ បង្ករលក្ខណៈសម្បត្តិដ៏វិសេសវិសាលសម្រាប់ពង្រឹងវិស័យអប់រំ និងបណ្ដុះបណ្ដាលធនធានមនុស្ស ដើម្បីរួមចំណែកដល់ការអភិវឌ្ឍមូលដ្ឋានរបស់ខ្លួន និយាយដោយឡែក និងនិយាយជារួមគឺដើម្បី អភិវឌ្ឍប្រទេសជាតិយើងឲ្យកាន់តែមានការរីកចម្រើនតទៅមុខទៀត ។ ចំពោះវិស័យសុខាភិបាលវិញ ស្រុកឈូក គឺជាស្រុកប្រតិបត្តិមួយគ្រប់គ្រងចំនួន ៣ស្រុក មានមន្ទីរពេទ្យបង្អែកចំនួន ២កន្លែង និងមណ្ឌលសុខភាពចំនួន ២៤កន្លែង ព្រមទាំងមានបុគ្គលិកបម្រើការងារចំនួន ២៦៥នាក់ (ស្រី ៥០នាក់) ។ ក្នុងនោះស្រុកឈូកមានមណ្ឌលសុខភាពចំនួន ១២កន្លែង មានបុគ្គលិកបម្រើការងារចំនួន ១៧៨នាក់ (ស្រី ៩៩នាក់) ។ មន្ទីរពេទ្យបង្អែក និងមណ្ឌលសុខភាពបានបម្រើការជាប្រចាំ សម្រាប់ផ្ដល់សេវាសុខភាពជូនប្រជាជន ទូទៅគ្រប់ពេលវេលា ។ ព្រមជាមួយនេះក៏បានចុះទៅដល់ផ្ទះប្រជាជននៅតាមភូមិ ដើម្បីផ្ដល់សេវាពន្យាកំណើត ចាក់វ៉ាក់សាំង ស្ត្រី និងកុមារ និងផ្សព្វផ្សាយអប់រំបង្ការជម្ងឺឆ្លងផ្សេងៗ ។ ជាក់ស្ដែងផ្នែកសុខភាពមាតា និងទារក បានពិគ្រោះនិងពិនិត្យស្ត្រីចំនួន ៨.៣៩២នាក់ និងករណីសម្រាកពេទ្យមានចំនួន ៧៦៧នាក់ ។ អ្វីដែលគួរឲ្យកត់សម្គាល់គឺ ក្នុងឆមាសទី១ ឆ្នាំ ២០១៧ នេះ គ្រប់មណ្ឌលសុខភាពនៅស្រុកឈូកមិនមានអ្នកស្លាប់ទេ ។ ចំពោះវិស័យសាសនាវិញទូទាំងស្រុកឈូក មានវត្តព្រះពុទ្ធសាសនាសរុប ៤៨វត្ត មានព្រះសង្ឃ ៣៥៩ អង្គ គ្រឹះសាសនាមានព្រះវិហារ ២៦កន្លែង និងមាន បរិស័ទចំនួន ២.៦៥៣នាក់ ។ នៅទីនេះមិនដែលមានជម្លោះសាសនាទេ ។ គណៈកម្មាធិការបក្សស្រុក គណៈអភិបាលស្រុក ក៏ដូចជាអាជ្ញាធរ ភូមិឃុំ តែងធ្វើសុខដុមនីយកម្មសាសនា មិនដែលឲ្យមានផលរមាស់អ្វីឡើយ ហើយប្រជាជនមិនថា កាន់សាសនាណាឡើយ តែងតែរួបរួមសាមគ្គីគ្នា ជួយទំនុកបម្រុងគ្នា ជួយយកអសារគ្នាគ្រប់ពេលវេលា ទាំងអស់ ។

នៅលើការងារដឹកនាំវិញ ទាំងគណបក្សស្រុក ទាំងអាជ្ញាធរស្រុកបានយកចិត្តទុកដាក់ខ្លាំងណាស់ទៅលើការរស់នៅ និងសុខទុក្ខរបស់ប្រជាជន ។ ប៉ុន្តែយើងពិតជានៅមានចន្លោះប្រហោងខ្លះដែលនេះជារឿង ជៀសមិនផុតឡើយ ចំពោះការងារដឹកនាំ ប៉ុន្តែគ្មានពេលណាមួយ ដែលយើងធ្វេសប្រហែសមិនធ្វើការកែសម្រួលនោះឡើយ ។ នេះជាការអះអាងរបស់លោក ខៀវ រិទ្ធិភ័ណ្ឌ ។ គាត់បាននិយាយទៀតថា ពួកប្រឆាំងតែងតែបញ្ជ្រាបខ្លួន ចូលត្រង់កន្លែងណាដែលយើងនៅសេសសល់ចំណុចអវិជ្ជមាន ។ ពួកគេចុះទៅនិយាយញុះញង់វាយប្រហារ និងថែមទាំងឃោសនាបំភ្លៃការពិតថែមទៀត ។ ប៉ុន្តែយើងមិនទុកឱកាសឲ្យពួកនេះធ្វើព្យុះធ្វើភ្លៀងបាន នៅក្នុងមូលដ្ឋានរបស់យើងទេ ។ យើងរហ័សរហួនជួសជុល និងកែលម្អចំណុចខ្វះខាតរបស់យើង ។ យើងម្ចាស់ការវាយបកភ្លាមៗ និងធ្វើការបកស្រាយពន្យល់ប្រជាជនឲ្យបានយល់ច្បាស់អំពីការពិត ។ នៅពេលដែលយើងពង្រឹងខ្លាំងការងារនេះ ពួកប្រឆាំងក៏បាក់ស្រុតដែរ ។ ពួកគេលែងភូតកុហកកើត ព្រោះប្រជាជនលែងជឿ ។ ចំណុចខ្វះខាតរបស់យើងក៏ត្រូវបានកែលម្អ បង្កើតបានជំនឿទុកចិត្ត និងទាក់ទាញបានការគាំទ្ររបស់ប្រជាជនមកវិញ។ លោកប្រធានគណៈកម្មាធិការបក្សស្រុក បានមានប្រសាសន៍ជាចុងក្រោយថា ជ័យជម្នះស្ថិតនៅលើយើង ឯមូលហេតុដែលនាំឲ្យមានជ័យជម្នះក៏ដោយសារយើង ។ យើងជាអ្នកកំណត់កត្តាជ័យជម្នះ មិនមែនពួកប្រឆាំងនោះទេ ។ ដូច្នេះយើងត្រូវតែរួបរួមគ្នា ពង្រឹងផ្លូងសាមគ្គីទាំងក្នុងជួរគណបក្ស ក្នុងជួររដ្ឋអំណាច និងក្នុងប្រជាជន ។ ដើម្បីពង្រឹងផ្លូងសាមគ្គីបាន យើងត្រូវយកចិត្តទុកដាក់បំពេញការងារជាសមូហភាព មានតម្លាភាព ស្មោះត្រង់ជាមួយប្រជាជន គោរពស្រឡាញ់ប្រជាជន មិនធ្វើឲ្យប្រជាជនថ្នាំងថ្នាក់ មិនធ្វើឲ្យប្រជាជនខកចិត្ត ។ ស្រុកឈូកកំពុងអនុវត្តការងារនេះយ៉ាងម៉ឺងម៉ាត់ ហើយស្រុកឈូកប្ដេជ្ញាដណ្ដើមយកជ័យជម្នះឲ្យបាន ក្នុងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នៅខែកក្កដា ឆ្នាំ២០១៨ខាងមុខនេះ ៕





*ការងារបង្កបង្កើនផលស្រូវ និងការដាំដំណាំម្រេចមិនត្រឹមតែជួយលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាជនប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងបានជួយបង្កើនសម្រស់ធម្មជាតិដ៏ស្រស់ត្រកាលដល់ស្រុកឈូកទៀតផង*

# មិត្តល្អ ប្អូនពូក

១. ទីមួយគឺបុណ្យ គុណឧត្តម — តាមជួយឧបត្ថម្ភគ្រប់ៗជាតិ
កុសលផ្ដល់ជូន ឥតឃ្លាឃ្លាត — គួរឆ្លៀតសន្សំ កុំជិនណាយ ។
២. បុណ្យជាទេវធម៌ ដ៏ថ្លៃថ្លា — បុណ្យជួយអាត្មា ផុតអបាយ
ចៀសកម្មអប្រិយ ផងទាំងឡាយ — សឹងសុខសប្បាយ ឆ្ងាយទុក្ខា ។
៣. ទីពីរ មិត្តល្អ មហិមា — មានព្រហ្មវិហារ មាតាបិតា
គឺជាគ្រូដើម ផ្ដើមលោកា — ថ្នមថ្នាក់រក្សា ឥតជិនឆ្អន់ ។
៤. អ្នកផ្ដល់កំណើតបង្កើតកាយ — ជម្នះអន្តរាយ ច្រើនអនន្ត
ចិត្តស្នេហ៍ស្មោះពិតឥតស្រាកស្រន់ — ជាព្រះអរហន្តនៃបុត្តំ ។
៥. ឯទីបីគឺ គ្រូបាធ្យាយ — លោកតែងរីករាយជ្រើសសម្រាំង
ចេះចាំតាមក្បួន គម្ពីរក្រាំង — ឥតទុកលាក់បាំងបង្រៀនអស់ ។
៦. ខិតខំទូន្មាន ប្រៀនប្រដៅ — ដ្បិតខ្លាចសិស្សខ្លៅ អសប្បុរស
សាងល្អសុចរិត ចិត្តត្រង់ស្មោះ — ប្រិតប្រឹងរំដោះ អវិជ្ជា ។
៧. បើបានសិស្សស្ដាប់ គ្រាប់ឱវាទ — គ្រូរឹតឱហាត ឥតរួញរា
ឥតគិតហត់នឿយ ស្បើយពុះពារ — ឲ្យសិស្សគ្រប់គ្នា ចេះចាំល្អ ។
៨. រីទីបួនសោត មិត្តកល្យាណ — ស្រឡាញ់រាប់អានចិត្តស្មោះសរ
ដោះទុក្ខធុរៈ គ្រប់គ្រាក្រ — និងរួមត្រេកអរ មិត្តមានបាន ។
៩. មិត្តល្អប្អូនបែប សង្ខេបខ្លី — សូមទោសប្រុសស្រីគ្រប់មជ្ឈដ្ឋាន
ពាក្យពោលពុំសមរម្យប៉ុន្មាន — រំខាន ខន្តី ទុកមោឃៈ ។
១០. រីជនស្គាល់គុណ បុព្វការី — សឹងសុខសួស្ដី ជ័យជោគជាក់
បុណ្យជួយលើកស្ទួយ អភិរក្ស — មិនឲ្យធ្លោយធ្លាក់អាក់អន្តរាយ ។

ដោយលោក. នឹម ណាំ




## ធ្មេញបាក់សក់ស្កូវ

នាយ **ចេក** និងនាង **ចាន់** ជាប្ដីប្រពន្ធរស់នៅជាមួយគ្នា ជាង ១០ឆ្នាំ មកហើយ ដោយមានសុភមង្គលយ៉ាងក្រៃលែង។ ប៉ុន្តែជាចៃដន្យ ថ្ងៃមួយ នាយ **ចេក** ជួបគ្រោះថ្នាក់ចរាចរបាក់ធ្មេញអស់ទាំងពីរជួរ។ លុះពេលចេញពីមន្ទីរពេទ្យនាយ **ចេក** ប្រញាប់ ប្រញាល់ទៅដាក់ធ្មេញឡើងវិញ។ ដាក់រួចមកដល់ផ្ទះស្រាប់តែនាង **ចាន់** ដកដង្ហើមវែងនិយាយៈ

- យើងល្មមចែកផ្លូវគ្នាហើយ !
- អ្ហ៎ាកម៉េចហ្នឹង សុខៗស្រាប់តែចង់លែងលះគ្នា ?
- បងភ្លេចហើយឬ កាលថ្ងៃរៀបការយើងបានសច្ចារួមគ្នានៅមុខព្រះជាម្ចាស់ថា "ពួកយើងនឹងរស់នៅជាមួយគ្នារហូតដល់បាក់ធ្មេញសក់ស្កូវ ។ ពេលនេះថ្វីបើសក់របស់បងមិនទាន់ស្កូវ តែធ្មេញបងបាក់អស់ហើយ នៅជាមួយគ្នាម្ដេចកើតទៀត ។

## គិតគូរម៉ត់ចត់

ម្ដាយចង់ឲ្យកូនស្រីចេះសន្សំសំចៃ និងចាយវាយមានរបៀបក៏ប្រាប់ៈ

- ចាប់ពីពេលនេះតទៅចំណាយទិញអ្វីៗត្រូវតែកត់ត្រាចូលបញ្ជីទោះតិចតួចក៏ដោយ។ ថ្ងៃមួយកូន **ស្រស** ចាប់បញ្ជីបណ្ដើរនិយាយជាមួយម្ដាយបណ្ដើរៈ
- តាំងពីថ្ងៃម៉ែប្រាប់ខ្ញុំ ឲ្យធ្វើបញ្ជីកត់រាល់ការចំណាយតូចធំ ខ្ញុំចេះពិចារណាល្អិតល្អន់មុននឹងទិញអ្វីមួយ។ របស់ណាឈ្មោះវែងពេកពិបាកសរសេរអត់ខ្ញុំទិញ ។



បោះពុម្ពដោយ រោងពុម្ព **អរិយធម៌** ផ្ទះលេខ ៩២, ផ្លូវលេខ ៥៩៤, សង្កាត់បឹងកក់ II ខណ្ឌទួលគោក-ភ្នំពេញ
H/P : 012 990 935 / Tel : 023 885 188 / Fax : 023 885 189 E-mail : ariyathoar@yahoo.com

# អ្នកឧបត្ថម្ភ ទស្សនាវដ្តី ប្រជាជន លេខ ១៩៧

| | | | |
|---|---|---|---|
| ១- | លោកជំទាវ **ម៉ែន សំអន** | *សមាជិកគណៈអចិន្ត្រៃយ៍គណៈកម្មាធិការកណ្តាល ប្រធានគណៈកម្មាធិការគណបក្សក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច* | ៤០០.០០០៛ |
| ២- | ឯ.ឧ **កែ គីមយ៉ាន** | *សមាជិកគណៈអចិន្ត្រៃយ៍គណៈកម្មាធិការកណ្តាល ប្រធានក្រុមការងារចុះខេត្តបន្ទាយមានជ័យ* | ១០០ ដុល្លារ |
| ៣- | ឯ.ឧ **អ៊ុក រ៉ាប៊ុន** | *សមាជិកគណៈអចិន្ត្រៃយ៍គណៈកម្មាធិការកណ្តាល ប្រធានគណៈកម្មាធិការគណបក្សក្រសួងអភិវឌ្ឍន៍ជនបទ* | ១០០ ដុល្លារ |
| ៤- | ឯ.ឧ **ជា ចាន់តូ** | *ប្រធានគណៈកម្មាធិការនៃគណបក្សធនាគារជាតិ* | ៤០០.០០០៛ |
| ៥- | ឯ.ឧ **អូន ព័ន្ធមុនីរ័ត្ន** | *ប្រធានគណៈកម្មាធិការគណបក្សក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ* | ២០០ ដុល្លារ |
| ៦- | ឯ.ឧ **ចេង សាខុន** | *ប្រធានគណៈកម្មាធិការគណបក្សក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ* | ១៥០ ដុល្លារ |
| ៧- | ឯ.ឧ **ចាន់ សូរស័ក្តិ** | *ប្រធានគណៈកម្មាធិការគណបក្សក្រសួងពាណិជ្ជកម្ម* | ១៥០ ដុល្លារ |
| ៨- | ឯ.ឧ **ហ៊ុន ណេង** | *ប្រធានគណៈកម្មការទី ៤ នៃរដ្ឋសភា* | ១០០ ដុល្លារ |
| ៩- | ឯ.ឧ **ថោង ខុន** | *ប្រធានគណៈកម្មាធិការគណបក្សក្រសួងទេសចរណ៍* | ១០០ ដុល្លារ |
| ១០- | ឯ.ឧ **អ៊ិត សំហេង** | *ប្រធានគណៈកម្មាធិការគណបក្សក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ* | ១០០ ដុល្លារ |
| ១១- | ឯ.ឧ **គង់ វិបុល** | *ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកអគ្គនាយកដ្ឋាន នៃអគ្គនាយកដ្ឋានពន្ធដារ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ* | ១០០ ដុល្លារ |
| ១២- | ឯ.ឧ **លន់ លឹមថៃ** | *ប្រធានគណៈកម្មាធិការគណបក្សខេត្តកំពង់ចាម* | ១០០ ដុល្លារ |
| ១៣- | ឯ.ឧ **អ៊ូស្មាន ហាសន្សាន់** | *ប្រធានគណៈចលនាសាសនិកឥស្លាមនៃគណបក្សប្រជាជនកម្ពុជា* | ១០០ ដុល្លារ |
| ១៤- | ឯ.ឧ **សរ ចំរ៉ុង** | *ប្រធានគណៈកម្មាធិការគណបក្សខេត្តក្រចេះ* | ១០០ ដុល្លារ |
| ១៥- | ឯ.ឧ **ចាំ សុជាតិវង្ស** | *ប្រធានគណៈកម្មាធិការគណបក្សរាជធានីភ្នំពេញ* | ១០០ ដុល្លារ |
| ១៦- | ឯ.ឧ **ម៉ែន វិបុល** | *ប្រធានគណៈកម្មាធិការគណបក្សខេត្តស្វាយរៀង* | ១០០ ដុល្លារ |
| ១៧- | ឯ.ឧ **ម៉ម ប៊ុននាង** | *អនុប្រធានគណៈកម្មការទី ១០នៃព្រឹទ្ធសភា* | ១០០ ដុល្លារ |
| ១៨- | ឯ.ឧ **យូ តិរម្យ** | *អនុប្រធានក្រុមការងាររបស់គណៈកម្មាធិការកណ្តាល ចុះជួយរាជធានីភ្នំពេញ* | ១០០ ដុល្លារ |
| ១៩- | **គណៈកម្មាការ ក៧១** | | ៤០០.០០០ ៛ |
| ២០- | **គណៈកម្មាធិការគណបក្សខេត្តបាត់ដំបង** | | ១០០ ដុល្លារ |
| ២១- | **គណៈកម្មាធិការគណបក្សខេត្តសៀមរាប** | | ១០០ ដុល្លារ |
| ២២- | **គណៈកម្មាធិការគណបក្សខេត្តព្រះសីហនុ** | | ១០០ ដុល្លារ |
| ២៣- | **គណៈកម្មាធិការគណបក្សក្រសួងកិច្ចការនារី** | | ៥០ ដុល្លារ |
| ២៤- | **គណៈកម្មាធិការគណបក្សខេត្តបន្ទាយមានជ័យ** | | ៥០ ដុល្លារ |
| ២៥- | **គណៈកម្មាធិការគណបក្សខេត្តកំពត** | | ៥០ ដុល្លារ |
| ២៦- | **គណៈកម្មាធិការគណបក្សក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ** | | ២០០.០០០ ៛ |
| ២៧- | ឯ.ឧ **លឹម គានហោ** | *ប្រធានគណៈកម្មាធិការគណបក្សក្រសួងធនធានទឹក និងឧតុនិយម* | ២០០.០០០ ៛ |
| ២៨- | ឯ.ឧ **ម៉ម ប៊ុនហេង** | *ប្រធានគណៈកម្មាធិការគណបក្សក្រសួងសុខាភិបាល* | ៥០ ដុល្លារ |
| ២៩- | ឯ.ឧ **ថា យ៉ាវ** | *អនុប្រធានគណៈកម្មាធិការគណបក្សធនាគារជាតិនៃកម្ពុជា* | ២១៣.៤៧០៛ |
| ៣០- | ឯ.ឧ **ជូ យិនស៊ីម** | *រដ្ឋលេខាធិការក្រសួងសុខាភិបាល* | ៥០ ដុល្លារ |
| ៣១- | ឯ.ឧ **ប៉ាវ ហាមផាន** | *រដ្ឋលេខាធិការក្រសួងមហាផ្ទៃ* | ៥០ ដុល្លារ |
| ៣២- | ឯ.ឧ **ម៉ៅ ប៊ុនណារិន** | *សមាជិកគណៈកម្មាធិការកណ្តាលគណបក្សប្រជាជនកម្ពុជា* | ២០០.០០០៛ |
| ៣៣- | ឯ.ឧ **សូ ជុងហួរ** | *សមាជិកក្រុមប្រឹក្សាខេត្តព្រះសីហនុ* | ៥០ ដុល្លារ |
| ៣៤- | ឯ.ឧ **ចាយ បូរិន** | *អ្នកតំណាងរាស្ត្រមណ្ឌលកំពង់ចាម* | ៥០ ដុល្លារ |
| ៣៥- | ឯ.ឧ **សួស យ៉ារ៉ា** | *អ្នកតំណាងរាស្ត្រមណ្ឌលព្រះវិហារ* | ៥០ ដុល្លារ |
| ៣៦- | ឯ.ឧ **នរៈ រតនៈវឌ្ឍនោ** | *រដ្ឋលេខាធិការក្រសួងធម្មការ និងសាសនា* | ២០០.០០០ ៛ |
| ៣៧- | ឯ.ឧ **ឃួន វ៉ានិន** | *រដ្ឋលេខាធិការក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា* | ៥០ ដុល្លារ |
| ៣៨- | ឯ.ឧ. **ស្តើង សុខុម** | *អនុរដ្ឋលេខាធិការទីស្តីការក្រសួងទេសចរណ៍* | ២០០.០០០៛ |
| ៣៩- | ឯ.ឧ **សុខ ខេមរិន** | *អនុប្រធានក្រុមការងារចុះស្រុកកញ្ជ្រៀច និងប្រធានក្រុមការងារចុះឃុំកញ្ជ្រៀច* | ៥០ ដុល្លារ |
| ៤០- | ឯ.ឧ **ឆាយ ឫទ្ធិសែន** | *អគ្គនាយកនៃអគ្គនាយកដ្ឋានរៀបចំដែនដីនគូបនីយកម្ម និងសំណង់* | ២០០.០០០៛ |
| ៤១- | ឯ.ឧ. **ប៊ុន លឹមហេង** | *អនុរដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី* | ២០០.០០០៛ |
| ៤២- | ឯ.ឧ **សេង ទៀង** | *អនុរដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី* | ២០០.០០០៛ |
| ៤៣- | ឯ.ឧ **ម៉ែន ស៊ីផាន់** | *សមាជិកព្រឹទ្ធសភា* | ១០០.០០០៛ |
| ៤៤- | ឯ.ឧ **ណៅ ធូក** | *រដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ* | ១០០.០០០៛ |
| ៤៥- | ឯ.ឧ **ប៉ាន ប៊ុនធឿន** | *រដ្ឋលេខាធិការក្រសួងផែនការ* | ១០០.០០០៛ |
| ៤៦- | លោកជំទាវ **ស៊ឹង ស៊ីយុត** | | ១០០.០០០៛ |
| ៤៧- | ឯ.ឧ **គីម ធា** | *ប្រធានក្រុមប្រឹក្សាខេត្តស្វាយរៀង* | ១០០.០០០៛ |
| ៤៨- | ឯ.ឧបណ្ឌិត **មាស ប៉ូ** | *អនុរដ្ឋលេខាធិការក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍* | ១០០.០០០៛ |
| ៤៩- | លោកជំទាវ **និត្យ ចំនួតរីន** | *អនុរដ្ឋលេខាធិការក្រសួងរៀបចំដែនដី នគូបនីយកម្ម និងសំណង់* | ១០០.០០០៛ |
| ៥០- | ឯ.ឧ **ជួន ថេរ៉ាវ៉ាត** | *ទីប្រឹក្សាសម្តេចអគ្គមហាពញាចក្រី* ***ហេង សំរិន*** | ១០០.០០០៛ |
| ៥១- | លោក **គីម ប៊ុណ្ណា** | *សមាជិកអចិន្ត្រៃយ៍នៃគណៈកម្មាធិការគណបក្សខេត្តសៀមរាបប្រធានសាខាគណបក្សមន្ទីរសាធារណការ និងដឹកជញ្ជូន* | ១០០.០០០៛ |
| ៥២- | ឯ.ឧ. ឧកញ៉ា **សន កុសល** | *អនុប្រធានគណបក្សស្រុកកំពង់សិលា* | ២០ ដុល្លារ |
| ៥៣- | ឯ.ឧ **ស៊ឹម ស៊ីថា** | *អគ្គនាយករដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ* | ៨០.០០០៛ |
| ៥៤- | ឯ.ឧ **អ៊ុន ឆាលី** | *សមាជិកក្រុមប្រឹក្សាខេត្តកោះកុង* | ៥០.០០០៛ |
| ៥៥- | ឯ.ឧ **ពត ចាន់នី** | *សមាជិកក្រុមការងារចុះជួយខេត្តកំពង់ចាម* | ៥០.០០០៛ |

## អ្នកឧបត្ថម្ភ ទស្សនាវដ្តី ប្រជាជន លេខ ១៩៧

| | | | | | |
|---|---|---|---|---|---|
| ៥៦- | ឯ.ឧ | ហេង | វណ្ណា | សមាជិកក្រុមការងារគណៈកម្មាធិការកណ្តាលចុះជួយខេត្តព្រះសីហនុ | ៥០.០០០៛ |
| ៥៧- | ឯ.ឧ | ស៊ាង | ចាន់ | សមាជិកក្រុមការងារគណៈកម្មាធិការកណ្តាលចុះជួយខេត្តព្រះសីហនុ | ៥០.០០០៛ |
| ៥៨- | លោកជំទាវ | ស៊ឿ | ចំនួថា | | ៥០.០០០៛ |
| ៥៩- | លោក | ជា | វុទ្ធី | សមាជិកក្រុមការងារគណៈកម្មាធិការកណ្តាលចុះជួយខេត្តព្រះសីហនុ | ៥០.០០០៛ |
| ៦០- | លោក | ទេព | វិសិដ្ឋ | អនុប្រធានគណៈកម្មាធិការត្រួតពិនិត្យ នៃគណៈកម្មាធិការគណបក្សខេត្តព្រះសីហនុ | ៥០.០០០៛ |
| ៦១- | លោក | អ៊ុំ | រាត្រី | អភិបាលរងខេត្តបន្ទាយមានជ័យ | ៥០.០០០៛ |
| ៦២- | លោក | ឆេង | សុភក្រ្ត | សមាជិកក្រុមការងារគណៈកម្មាធិការកណ្តាលចុះជួយខេត្តព្រះសីហនុ | ៥០.០០០៛ |
| ៦៣- | លោក | ហូ | ដារីណា | ប្រធានការិយាល័យរដ្ឋបាល នៃធនាគារជាតិ | ៥០.០០០៛ |
| ៦៤- | ឯ.ឧ | ថៅ | ជេដ្ឋា | រដ្ឋលេខាធិការក្រសួងធនធានទឹក និងឧតុនិយម | ៤០.០០០ ៛ |
| ៦៥- | **គណៈកម្មាធិការគណបក្សប្រជាជនកម្ពុជាប្រចាំគណៈកម្មាធិការសម្របសម្រួលខ្មែរកម្ពុជាក្រោម** | | | | ៤០.០០០៛ |
| ៦៦- | លោក | លី | សារី | អភិបាលរង ខេត្តបន្ទាយមានជ័យ | ៤០.០០០៛ |
| ៦៧- | លោក | គឹម | សុវណ្ណ | ប្រធានមន្ទីរសាធារណការ ខេត្តបន្ទាយមានជ័យ | ៤០.០០០៛ |
| ៦៨- | ឯ.ឧ | ស៊ិន | វុទ្ធី | សមាជិកអចិន្ត្រៃយ៍គណៈកម្មាធិការគណបក្សក្រសួងធនធានទឹក និងឧតុនិយម | ៣០.០០០៛ |
| ៦៩- | ឯ.ឧ | សាំង | សាវ៉ាត | សមាជិកក្រុមប្រឹក្សាខេត្តបន្ទាយមានជ័យ | ៣០.០០០៛ |
| ៧០- | លោក | ម៉ៅ | សុខលីម | អនុប្រធានមជ្ឈមណ្ឌលជាតិស្រាវជ្រាវវេជ្ជសាស្ត្របូរាណក្រសួងសុខាភិបាល សមាជិកក្រុមការងារចុះខណ្ឌសែនសុខ ភ្នំពេញ | ៣០.០០០៛ |
| ៧១- | លោក | ចាន់ | ស៊ីណាត | សមាជិកគណៈកម្មាធិការគណបក្សក្រសួងធនធានទឹក និងឧតុនិយម | ៣០.០០០៛ |
| ៧២- | លោក | ឃូ | ពៅ | អភិបាលស្រុកស្វាយចេក | ៣០.០០០៛ |
| ៧៣- | កញ្ញា | កែវ | សុជាតា | អនុប្រធានលេខាធិការដ្ឋានអមគណៈកម្មការទី ៤ នៃព្រឹទ្ធសភា | ៣០.០០០៛ |
| ៧៤- | លោក | ហង់ | ប៉ូ | ប្រធានក្រុមការងារចុះ ឃុំវវៀង ស្រុកសំរោង ខេត្តតាកែវ | ២០.០០០៛ |
| ៧៥- | លោក | ឈា | ប៊ុនរិទ្ធ | សមាជិកក្រុមការងារចុះខេត្តកណ្តាល | ២០.០០០៛ |
| ៧៦- | លោក | ម៉ៅ | ហាក់ | សមាជិកក្រុមការងារចុះខេត្តកណ្តាល | ២០.០០០៛ |
| ៧៧- | លោក | លឹម | វីរក្ស | សមាជិកគណៈកម្មាធិការគណបក្សក្រសួងធនធានទឹក និងឧតុនិយម | ២០.០០០៛ |
| ៧៨- | លោក | លឹម | ថេង | សមាជិកក្រុមការងារចុះខេត្តកណ្តាល | ២០.០០០៛ |
| ៧៩- | លោក | ឃ្លោក | សំអាង | សមាជិកក្រុមការងារចុះខេត្តកំពង់ចាម | ២០.០០០៛ |
| ៨០- | លោក | ម៉ី | វុឌ្ឍា | មន្ត្រីមន្ទីរគណបក្ស ខេត្តព្រៃវែង | ២០.០០០៛ |
| ៨១- | លោក | អ៊ុត | សំអាន | អគ្គាធិការរងនៃអធិការដ្ឋានក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | ២០.០០០៛ |
| ៨២- | លោក | គួច | ចាន់និត្យ | អាជីវករ ខេត្តបន្ទាយមានជ័យ | ២០.០០០៛ |
| ៨៣- | ឯ.ឧ | សេង | សុមុនី | សមាជិកគណៈអចិន្ត្រៃយ៍គណៈកម្មាធិការគណបក្សក្រសួងធម្មការ និងសាសនា | ១០.០០០៛ |
| ៨៤- | ឯ.ឧ | ប៉ុញ | សច្ចះ | អគ្គនាយកកិច្ចការបច្ចេកទេសនៃក្រសួងធនធានទឹក និងឧតុនិយម | ១០.០០០៛ |
| ៨៥- | លោក | ជួន | វណ្ណរិទ្ធ | សមាជិកក្រុមការងារចុះខេត្តកណ្តាល | ១០.០០០៛ |
| ៨៦- | លោក | ខួន | ពេជ្រ | ប្រធាននាយកដ្ឋានទឹកស្អាត ក្រសួងធនធានទឹក និងឧតុនិយម | ១០.០០០៛ |
| ៨៧- | លោក | ម៉ម | ឬទ្ធស | អនុប្រធាននាយកដ្ឋានរដ្ឋបាល និងធនធានមនុស្សនៃក្រសួងធានធានទឹក និងឧតុនិយម | ១០.០០០៛ |
| ៨៨- | លោក | សៅ | សម្ផស្ស | អនុប្រធាននាយកដ្ឋានហិរញ្ញវត្ថុនៃក្រសួងនៃក្រសួងធានធានទឹក និងឧតុនិយម | ១០.០០០៛ |
| ៨៩- | លោក | ប៉ាវ | មុយថុង | អនុប្រធានគណៈកម្មាធិការសាខាបក្សមជ្ឈមណ្ឌលផ្តល់ឈាមនៃមន្ទីរពេទ្យព្រះអង្គឌួង | ១០.០០០៛ |
| ៩០- | លោក | ឈុន | ប៊ុនឈឿន | សមាជិកក្រុមការងារចុះខេត្តកណ្តាល | ១០.០០០៛ |
| ៩១- | លោក | ថេង | ប៊ុនតេង | សមាជិកក្រុមការងារចុះខេត្តកណ្តាល | ១០.០០០៛ |
| ៩២- | លោក | ស្វាយ | សុគន្ធី | សមាជិកក្រុមការងារចុះខេត្តកណ្តាល | ១០.០០០៛ |
| ៩៣- | លោក | សុខ | ចំណាន | សមាជិកក្រុមការងារចុះខេត្តកណ្តាល | ១០.០០០៛ |
| ៩៤- | លោក | សៅ | សម្ភារ | ប្រធានការិយាល័យបណ្តុះបណ្តាលនៃនាយកដ្ឋានរដ្ឋបាល និងធនធានមនុស្ស នៃក្រសួងធានធានទឹក និងឧតុនិយម | ១០.០០០៛ |
| ៩៥- | លោក | និត | ចរិយា | ប្រធានការិយាល័យគណនេយ្យនាយកដ្ឋានហិរញ្ញវត្ថុ នៃក្រសួងធានធានទឹក និងឧតុនិយម | ១០.០០០៛ |
| ៩៦- | លោក | សែម | សំណាង | ប្រធានការិយាល័យគ្រប់គ្រងប្រព័ន្ធធារាសាស្ត្រនាយកដ្ឋានធារាសាស្ត្រ កសិកម្ម នៃក្រសួងធានធានទឹក និងឧតុនិយម | ១០.០០០៛ |
| ៩៧- | លោក | សុខ | តារា | សមាជិកក្រុមការងារចុះខេត្តកណ្តាល | ១០.០០០៛ |
| ៩៨- | លោក | សូ | ផល្លី | សមាជិកក្រុមការងារចុះខេត្តកណ្តាល | ១០.០០០៛ |
| ៩៩- | លោក | ហួត | ឆាន | សមាជិកក្រុមការងារចុះខេត្តកណ្តាល | ១០.០០០៛ |
| ១០០- | លោក | ទឹម | វុឌ្ឍារី | សមាជិកក្រុមការងារចុះខេត្តកណ្តាល | ១០.០០០៛ |
| ១០១- | លោក | ណុប | រឿមណី | សមាជិកក្រុមការងារចុះខេត្តកណ្តាល | ១០.០០០៛ |
| ១០២- | លោក | សារុន | សម្បត្តិ | សមាជិកក្រុមការងារចុះខេត្តកណ្តាល | ១០.០០០៛ |
| ១០៣- | លោក | សរ | វិចិត្រ | សមាជិកក្រុមការងារចុះខេត្តកណ្តាល | ១០.០០០៛ |
| ១០៤- | លោក | ទូច | សុផល្លា | សមាជិកក្រុមការងារចុះខេត្តកណ្តាល | ១០.០០០៛ |
| ១០៥- | លោក | ជុំ | ឧត្តរ៉ា | សមាជិកក្រុមការងារចុះខេត្តកណ្តាល | ១០.០០០៛ |
| ១០៦- | លោក | ឈ្លាង | ប៊ុយ | សមាជិកក្រុមការងារចុះខេត្តកណ្តាល | ១០.០០០៛ |
| ១០៧- | លោក | ជីវ | ស៊ុនលាង | សមាជិកក្រុមការងារចុះខេត្ត កណ្តាល | ១០.០០០៛ |
| ១០៨- | លោក | យស់ | ធុល | សមាជិកក្រុមការងារចុះស្រុកពោធិរៀង ខេត្តព្រៃវែង | ១០.០០០៛ |
| ១០៩- | លោក | ឡុង | ចន្ថា | សមាជិកក្រុមការងារចុះស្រុកពោធិរៀង ខេត្តព្រៃវែង | ១០.០០០៛ |
| ១១០- | លោក | ឡាច | គីរ៉ាត់ | សមាជិកក្រុមការងារចុះស្រុកបាភ្នំ ខេត្តព្រៃវែង | ១០.០០០៛ |
| ១១១- | លោក | ឈាង | សុវណ្ណារ៉ា | មន្ត្រីមន្ទីរគណបក្ស ខេត្តព្រៃវែង | ១០.០០០៛ |



## ប្លង់មេស្ពានបេតុងឆ្លងទន្លេសាប ភ្ជាប់ពីផ្លូវជាតិលេខ៥ ក្នុងភូមិសាស្ត្រខណ្ឌឫស្សីកែវ ទៅ តំបន់អភិវឌ្ឍន៍ជ្រោយចង្វា និងភ្ជាប់ទៅផ្លូវជាតិលេខ ៦អា ខណ្ឌជ្រោយចង្វា រាជធានីភ្នំពេញ



ដែលបានប្រារព្ធពិធីបើកការដ្ឋានសាងសង់
នៅថ្ងៃទី២៣ ខែតុលា ឆ្នាំ២០១៧





ចែកជូនដោយឥតគិតថ្លៃ